សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## សារណាបញ្ចប់ការសិក្សា

# នីតិវិធីនៃការជួញដូរមូលបត្រកម្មសិទ្ធិ

ស្រាវជ្រាវពីថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០២១ ដល់ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០២០


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **សឿន សុវណ្ណដាលីន**

**សំអឿន ច័ន្ទដាលីណា**

សាស្ត្រាចារ្យណែនាំ

លោក **ឈាង ហ៊ុយ**


ថ្នាក់បរិញ្ញាបត្រ ធនាគារ និងហិរញ្ញវត្ថុ

ជំនាន់ទី ១៤

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំឈ្មោះ **សឿន សុវណ្ណដាលីន** និង **សំអឿន ច័ន្ទដាលីណា** ជានិស្សិតជំនាន់ទី១៤ ជំនាញធនាគារ និងហិរញ្ញវត្ថុនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច និងគ្រប់គ្រងឆ្នាំសិក្សា ២០១៧-២០២១។

សូមគោរពជូនពរ ព្រមទាំងសម្តែងនូវកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅចំពោះ **មាតាបិតា** ជាអ្នកមានគុណ ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ ពុះពារ ថែរក្សា ផ្គត់ផ្គង់ និងអប់រំទូន្មានប្រៀនប្រដៅដល់រូបយើងខ្ញុំរហូតដល់ធំពេញវ័យដើម្បីឲ្យកូនមានឱកាសបានសិក្សារៀនសូត្ររហូតដល់បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។

**ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោក-លោកស្រីព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងលោក-លោកស្រីសាស្ត្រាចារ្យ** ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបង្ហាត់បង្រៀនដល់យើងខ្ញុំអស់ពីកម្លាំងកាយចិត្ត ក្នុងការផ្ទេរចំណេះដឹង និងបទពិសោធន៍ទាក់ទងទងនឹងវិស័យសេដ្ឋកិច្ចដល់យើងខ្ញុំទាំងអស់គ្នា។

សូមថ្លែងអំណរគុណយ៉ាងជ្រាវជ្រៅជូនចំពោះ **លោកសាស្ត្រាចារ្យ ឈាង ហ៊ុយ** ជាសាស្ត្រាចារ្យដឹកនាំក្នុងការសរសេរសារណានេះឡើង ដោយលោកបានខិតខំចំណាយពេលវេលាដ៏មានតម្លៃ ធ្វើការណែនាំពន្យល់បង្ហាញអំពីចំណុចសំខាន់ៗ ផ្តល់មតិយោបល់ល្អៗព្រមទាំងជួយពិនិត្យ និងកែតម្រូវលើចំណុចខ្វះខាតទាំងឡាយសម្រាប់តាក់តែងស្នាដៃនៃសារណារហូតដល់យើងខ្ញុំទទួលបានជោគជ័យជាស្ថាពរ។

**សិស្សច្បង** ដែលបានជួយពន្យល់បន្ថែមទាក់ទងនឹងប្រធានបទ និងផ្តល់ជាមតិក្នុងការសរសេរស្នាដៃនេះ ព្រមទាំងបន្សល់ទុកនូវឯកសារដ៏មានសារៈសំខាន់ចំពោះប្អូនៗជំនាន់ក្រោយយកមកធ្វើជាគំរូ សម្រាប់ការស្រាវជ្រាវបន្តទៀត។

យើងខ្ញុំទាំងពីររូប សូមជូនពរដល់លោកអ្នកមានគុណទាំងអស់ឲ្យជួបតែសំណាងល្អ សុខភាពល្អប្រកបការងារទទួលបានជោគជ័យគ្រប់ភារកិច្ច និងមានសេចក្តីសុខសុភមង្គល និងទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

សូមជម្រាបសួរ និងសួស្តីលោកគ្រូអ្នកគ្រូ ព្រមទាំងសិស្សនិស្សិតទាំងអស់ដែលកំពុងអានសៀវភៅសារណានេះជាទីគោរពរាប់អាន។ សៀវភៅដែលនៅក្នុងដៃលោកអ្នកនេះ គឺជាស្នាដៃនៃការខិតខំស្រាវជ្រាវ និងរៀបរៀងឡើងដោយនិស្សិតថ្នាក់បរិញ្ញាបត្រពីររូប ផ្នែកធនាគារ និងហិរញ្ញវត្ថុ ជំនាន់ទី១៤ ឆ្នាំសិក្សា ២០១៧-២០២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ខ្លឹមសារសំខាន់នៅក្នុងសៀវភៅស្រាវជ្រាវដែលស្តីអំពី «**នីតិវិធីនៃការជួញដូរមូលបត្រកម្មសិទ្ធិ**» នេះគឺមានគោលបំណងជួយឲ្យសិស្ស និស្សិត ពង្រីកចំណេះដឹង និងស្វែងយល់បន្ថែមឲ្យកាន់តែច្បាស់ទៅលើដំណើរការជួញដូរមូលបត្រកម្មសិទ្ធិនៅផ្សារមូលបត្រកម្ពុជា ទាំងទ្រឹស្តី និងការអនុវត្តជាក់ស្តែង ដែលបានមកពីការសិក្សានៅសាកលវិទ្យាល័យរយៈពេលបួនឆ្នាំកន្លងមក។ ការស្រាវជ្រាវនេះនឹងផ្តល់ជាជំនួយមួយដ៏សំខាន់សម្រាប់បង្កើនចំណេះដឹងមួយកម្រិតទៀត សម្រាប់មិត្តអ្នកអានទាំងអស់ឲ្យកាន់តែយល់ច្បាស់ក៏ដូចជាបង្កើនចំណេះដឹងបន្ថែម និងជាទុនមួយសម្រាប់និស្សិតជំនាន់ក្រោយៗទុកជាគំរូឯកសារក្នុងការស្រាវជ្រាវបន្តទៀត។

ទោះជាយ៉ាងនេះក្តី ក្នុងសៀវភៅចងក្រងនេះគឺពិតជាមានកំហុសឆ្គង និងចំណុចខ្វះខាតជាក់ជាមិនខាន ប៉ុន្តែពួកយើងទាំងអស់គ្នាក៏សូមអភ័យទោសចំពោះកំហុសអចេតនារួមទាំងចំណុចខ្វះខាតទាំងនោះផងដែរ ដោយសារចំណេះដឹងយើងខ្ញុំនៅមានកម្រិតនៅឡើយ និងយើងខ្ញុំសូមទទួលនូវពាក្យរិះគន់ក្នុងន័យស្ថាបនាផ្សេងៗពីសំណាក់លោកគ្រូអ្នកគ្រូ សិស្សនិស្សិត និងមហាជនគ្រប់មជ្ឈដ្ឋានទាំងអស់។

# មាតិកា

ទំព័រ


អក្សរកាត់.....v

បញ្ជីតារាង.....vi

បញ្ជីរូបភាព.....vii

បញ្ជីឧបសម្ព័ន្ធ.....viii


## សេចក្តីផ្តើម


១. លំនាំបញ្ហា.....១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ.....២

៣. គោលបំណងនៃការស្រាវជ្រាវ.....៣

៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ.....៣

៥. វិធីសាស្រ្តនៃការស្រាវជ្រាវ.....៣

៥.១ ការប្រមូលទិន្នន័យ.....៣

៥.២ ការវិភាគទិន្នន័យ.....៣

៦. សារៈសំខាន់នៃការស្រាវជ្រាវ.....៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ.....៤


## ជំពូកទី ១

## រំលឹកទ្រឹស្តី


១.១ ទីផ្សារមូលបត្រកម្មសិទ្ធិ.....៥

១.១.១ និយមន័យ.....៥

១.១.២ ប្រវត្តិទីផ្សារមូលបត្រកម្មសិទ្ធិ.....៥

១.២ ប្រភេទនៃមូលបត្រកម្មសិទ្ធិ.....៦

១.២.១ ភាគហ៊ុនធម្មតា.....៧

១.២.២ ភាគហ៊ុនបុរិមា.....៧

១.៣ ប្រភេទទីផ្សារមូលបត្រ.....៨

១.៣.១ ទីផ្សារដំបូង.....៨

១.៣.២ ទីផ្សារបន្ទាប់.....៩

១.៤ អត្ថប្រយោជន៍នៃទីផ្សារមូលបត្រកម្ពុជា ..... ១០
១.៤.១ អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះសេដ្ឋកិច្ចជាតិ ..... ១០
១.៤.២ អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះវិនិយោគិន ..... ១០

## ជំពូកទី ២

## និយ័តករមូលបត្រកម្ពុជា

២.១ ស្ថានភាពទូទៅរបស់និយ័តករមូលបត្រកម្ពុជា ..... ១៣
២.២ ចក្ខុវិស័យ និងបេសកកម្មរបស់ ន.ម.ក ..... ១៤
២.២.១ ចក្ខុវិស័យ ..... ១៤
២.២.២ បេសកកម្ម ..... ១៤
២.៣ គោលដៅ និងគោលបំណងទូទៅ ..... ១៥
២.៤ ទីតាំង និងពត៌មានសម្រាប់ទំនាក់ទំនង ..... ១៥
២.៥ រូបសញ្ញា និងអត្ថន័យនៃរូបសញ្ញារបស់ ន.ម.ក ..... ១៦
២.៥.១ រូបសញ្ញា ..... ១៦
២.៥.២ អត្ថន័យនៃរូបសញ្ញា ..... ១៧
២.៥.៣ ត្រារបស់និយ័តករមូលបត្រកម្ពុជា ..... ១៧
២.៦ ប្រធាន និងសមាជិក ន.ម.ក. ..... ១៨
២.៧ អង្គការចាត់តាំង ..... ១៨

## ជំពូកទី ៣

## ផ្សារមូលបត្រកម្ពុជា

៣.១ ប្រវត្តិផ្សារមូលបត្រកម្ពុជា ..... ២០
៣.២ ទិដ្ឋភាពទូទៅនៃទីផ្សារមូលបត្រនៅកម្ពុជា ..... ២១
៣.៣ នាមករណ៍ និងផ្លាកសញ្ញារបស់ ផ.ម.ក. ..... ២២
៣.៤ ចក្ខុវិស័យ និងបេសកកម្មរបស់ ផ.ម.ក. ..... ២៣
៣.៥ រចនាសម្ព័ន្ធគ្រប់គ្រង និងក្រុមប្រឹក្សាភិបាល ..... ២៣
៣.៦ ពត៌មានសម្រាប់ទំនាក់ទំនង ..... ២៤
៣.៧ តួអង្គចូលរួមក្នុងផ្សារមូលបត្រ ..... ២៥
៣.៧.១ តួអង្គលើទីផ្សារដំបូង ..... ២៥

៣.៧.២ តួអង្គលើទីផ្សារបន្ទាប់ ........ ២៦

## ជំពូកទី ៤
## នីតិវិធីនៃការជួញដូរមូលបត្រកម្មសិទ្ធិ

៤.១ លក្ខខណ្ឌតម្រូវរបស់វិនិយោគិនមុនធ្វើការជួញដូរ ........ ២៧
៤.១.១ ការជ្រើសរើសក្រុមហ៊ុនមូលបត្រ ........ ២៧
៤.១.២ ការបើកគណនីសាច់ប្រាក់ ........ ២៨
៤.១.៣ ការស្នើសុំអត្តសញ្ញាណវិនិយោគិន ........ ២៨
៤.១.៤ ការបើកគណនីជួញដូរ ........ ២៩
៤.២ ដំណើរការប្រតិបត្តិករទីផ្សារ ........ ៣០
៤.២.១ ពេលវេលានៃការជួញដូរ ........ ៣០
៤.២.២ ឯកតាបញ្ជា និងឯកតាគម្លាតថ្លៃ ........ ៣១
៤.២.៣ ដែនកំណត់ថ្លៃប្រចាំថ្ងៃ ........ ៣២
៤.២.៤ អាទិភាពថ្លៃនៃបញ្ជាទិញ-លក់ ........ ៣២
៤.២.៥ វិធីសាស្ត្រជួញដូរ ........ ៣៣
៤.៣ នីតិវិធីនៃការជួញដូរមូលបត្រកម្មសិទ្ធិ ........ ៣៥
៤.៣.១ ការដាក់បញ្ជាជួញដូរ ........ ៣៥
៤.៣.២ មធ្យោបាយ និងពត៌មាននៃការដាក់បញ្ជា ........ ៣៧
៤.៣.៣ យន្តការនៃការជួញដូរ ........ ៣៧
៤.៤ យន្តការនៃការផាត់ទាត់ និងទូទាត់មូលបត្រ ........ ៣៩
៤.៤.១ ការបើកគណនីសាច់ប្រាក់សម្រាប់ការទូទាត់សាច់ប្រាក់ ........ ៣៩
៤.៤.២ ការបើកគណនីសាច់ប្រាក់សម្រាប់ការទូទាត់មូលបត្រ ........ ៤០
៤.៤.៣ ដំណើរការផាត់ទាត់ ........ ៤១
៤.៤.៤ ដំណើរការទូទាត់ ........ ៤១
៤.៥ យន្តការនៃការរក្សាទុកមូលបត្រ ........ ៤៣
៤.៦ ទិន្នន័យសំខាន់នៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ........ ៤៤
៤.៦.១ ទំហំជួញដូរភាគហ៊ុន និងតម្លៃសរុបជាមធ្យមប្រចាំថ្ងៃ ........ ៤៥
៤.៦.២ ការជួញដូរតាមប្រភេទវិនិយោគិន (ក្នុងស្រុក និងបរទេស) ........ ៤៦

៤.៦.៣ ការជួញដូរតាមប្រភេទវិនិយោគិន (រូបវន្តបុគ្គល និងនីតិបុគ្គល) .................................... ៤៧
៤.៦.៤ ការចូលរួមដាក់បញ្ជាទិញ-លក់របស់វិនិយោគិនខ្មែរ និងបរទេស .................................... ៤៨
៤.៧ ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ .................................... ៥០
៤.៧.១ ចំណុចខ្លាំង .................................... ៥០
៤.៧.២ ចំណុចខ្សោយ .................................... ៥១

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១. សេចក្តីសន្និដ្ឋាន .................................... ៥២
២. ការផ្តល់អនុសាសន៍ .................................... ៥២
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# អក្សរកាត់

| | |
|---|---|
| ន.ម.ក. | និយ័តករមូលបត្រកម្ពុជា |
| ផ.ម.ក. | ផ្សារមូលបត្រកម្ពុជា |
| IPO | Initial Public Offering |
| SERC | Securities and Exchange Commission of Cambodia |
| CSX | Cambodia Stock Exchange |

# បញ្ជីតារាង

តារាងទី ៤.១ ឯកតាគម្លាតថ្លៃ
តារាងទី ៤.២ ដែនកំណត់ថ្លៃ
តារាងទី ៤.៣ អាទិភាពនៃបញ្ហាទិញ លក់
តារាងទី ៤.៤ វិធីសាស្ត្រដេញថ្លៃយកថ្លៃតែមួយ
តារាងទី ៤.៥ វិធីសាស្ត្រដេញថ្លៃយកថ្លៃច្រើន

# បញ្ជីរូបភាព


រូបភាពទី ១.១ ដំណើរការនៃការទិញមូលបត្រនៅក្នុងទីផ្សារដំបូង

រូបភាពទី ១.២ ដំណើរការនៃការទិញមូលបត្រនៅក្នុងទីផ្សារបន្ទាប់

រូបភាពទី ២.១ ផែនទីរបស់ ន.ម.ក.

រូបភាពទី ២.២ រូបសញ្ញារបស់ ន.ម.ក.

រូបភាពទី ២.៣ ត្រារបស់ ន.ម.ក.

រូបភាពទី ២.៤ អង្គការចាត់តាំងរបស់ ន.ម.ក.

រូបភាពទី ៣.១ រូបសញ្ញារបស់ ផ.ម.ក.

រូបភាពទី ៣.២ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ ផ.ម.ក.

រូបភាពទី ៣.៣ ក្រុមប្រឹក្សាភិបាលនៃ ផ.ម.ក.

រូបភាពទី ៤.១ លក្ខខណ្ឌតម្រូវរបស់វិនិយោគិនមុនធ្វើការជួញដូរ

រូបភាពទី ៤.២ ម៉ោងជួញដូរ

រូបភាពទី ៤.៣ វិធីសាស្ត្រជួញដូរតាមការចរចា

រូបភាពទី ៤.៤ ការដាក់បញ្ជាជួញដូរ

រូបភាពទី ៤.៥ យន្តការនៃការជួញដូរ

រូបភាពទី៤.៦ ទំហំជួញដូរភាគហ៊ុន និងតម្លៃសរុបជាមធ្យមប្រចាំថ្ងៃ ឆ្នាំ២០១៩

រូបភាពទី៤.៧ ទំហំជួញដូរភាគហ៊ុន និងតម្លៃសរុបជាមធ្យមប្រចាំថ្ងៃ ឆ្នាំ២០២០

រូបភាពទី៤.៨ ការជួញដូរតាមប្រភេទវិនិយោគិន (ក្នុងស្រុក និងបរទេស) ឆ្នាំ២០១៩

រូបភាពទី៤.៩ ការជួញដូរតាមប្រភេទវិនិយោគិន (ក្នុងស្រុក និងបរទេស) ឆ្នាំ២០២០

រូបភាពទី៤.១០ ការជួញដូរតាមប្រភេទវិនិយោគិន (រូបវន្តបុគ្គល និងនីតិបុគ្គល) ឆ្នាំ២០១៩

រូបភាពទី៤.១១ ការជួញដូរតាមប្រភេទវិនិយោគិន (រូបវន្តបុគ្គល និងនីតិបុគ្គល) ឆ្នាំ២០២០

រូបភាពទី៤.១២ ការចូលរួមដាក់បញ្ជាទិញ-លក់របស់វិនិយោគិនខ្មែរ និងបរទេស ឆ្នាំ២០១៩

រូបភាពទី៤.១៣ ការចូលរួមដាក់បញ្ជាទិញ-លក់របស់វិនិយោគិនខ្មែរ និងបរទេស ឆ្នាំ២០២០

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ២០០៧, "ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន"

ឧបសម្ព័ន្ធទី២៖ ប្រកាសស្តីពីការដាក់ឲ្យអនុវត្តវិធានប្រតិបត្តិការប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ, លេខ ០០៥/១១គ.ម.ក./ប្រ.ក.,០៣ ឧសភា ២០១១

ឧបសម្ព័ន្ធទី៣៖ គោលការណ៍ណែនាំស្តីពី នីតិនៃការទូទាត់សាច់ប្រាក់នៅក្នុងទីផ្សារមូលបត្រ, លេខ ០០៣/១២គ.ម.ក.ស.ជ.ណ.,១៤ កុម្ភៈ ២០១៤

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

បន្ទាប់ពីឆ្លងកាត់នូវសង្គ្រាមអស់រយៈពេលជាច្រើនឆ្នាំ ដែលបានបង្កជាការលំបាកដ៏ធ្ងន់ធ្ងរដល់សេដ្ឋកិច្ចជាតិ និងការអភិវឌ្ឍ ប្រទេសកម្ពុជាបានខិតខំប្រឹងប្រែងពង្រឹងប្រព័ន្ធសេដ្ឋកិច្ចរបស់ខ្លួនឲ្យមានការរីកចម្រើនយ៉ាងឆាប់រហ័សក្នុងរយៈពេលប៉ុន្មានទសវត្សកន្លងមកនេះ។ នៅក្នុងឆ្នាំ ២០១៥ ប្រទេសកម្ពុជាបានក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប និងមានគម្រោងវិវត្តទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ ហើយសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាទទួលបានអត្រាកំណើនពិតប្រាកដជាមធ្យម ៧,៧ ភាគរយនៅចន្លោះឆ្នាំ ១៩៩៨ និង ២០១៩ ដែលធ្វើឲ្យប្រទេសនេះក្លាយជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើនលឿនបំផុតនៅលើពិភពលោក។[1] ប៉ុន្តែចាប់ពីឆ្នាំ ២០១៩ ដល់បច្ចុប្បន្ន បញ្ហាជម្ងឺរាតត្បាតកូវីត១៩ បានកើតមានឡើងសាយភាយទូទាំងពិភពលោក និងបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ដំណើរការសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។ ការផ្ទុះឡើងនេះបានបណ្តាលឲ្យប្រាក់ចំណូលកម្ពុជាមានការថយចុះយ៉ាងខ្លាំង។ ទោះជាយ៉ាងណាក៏ដោយ សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាត្រូវបានរំពឹងថានឹងចាប់ផ្តើមងើបឡើងវិញនៅឆ្នាំ ២០២០ នេះ ហើយការអភិវឌ្ឍនឹងបន្តឈានទៅមុខទៀតក្រោមការប្រឹងប្រែងដ៏មុះមុតរបស់រដ្ឋាភិបាល។

ប្រទេសកម្ពុជាសព្វថ្ងៃជាប្រទេសកំពុងអភិវឌ្ឍមួយ ដែលមានប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី និងបើកចំហ។ យើងឃើញថាវិស័យសេវាកម្ម និងវិស័យហិរញ្ញវត្ថុនៅប្រទេសកម្ពុជាក៏មានការរីកចម្រើនគួរឲ្យកត់សម្គាល់ផងដែរ ដោយរដ្ឋាភិបាលបានយកចិត្តទុកដាក់ខ្ពស់ក្នុងការអភិវឌ្ឍវិស័យទាំងនោះ និងបន្តកសាងភាពអំណោយផលដល់ការវិនិយោគតាមរយៈការចេញគោលនយោបាយជាច្រើនដើម្បីលើកទឹកចិត្ត និងទាក់ទាញចំណាប់អារម្មណ៍របស់វិនិយោគិនមកពីទីកន្លែងផ្សេងៗគ្នា។ លើសពីនេះទៅទៀត យើងឃើញថាទីផ្សារហិរញ្ញវត្ថុប្រទេសកម្ពុជាបច្ចុប្បន្នក៏មានការរីកចម្រើនដែរ ជាពិសេសគឺទីផ្សារមូលបត្រដែលទទួលបានការគាំទ្រ និងចាប់អារម្មណ៍យ៉ាងខ្លាំងពីវិនិយោគិនក្នុងស្រុក។ ទីផ្សារមូលបត្រផ្តល់ឲ្យវិនិយោគិននូវឱកាសក្នុងការចាប់ផ្តើមយល់ដឹងពីវិស័យវិនិយោគនៅក្នុងប្រទេសកម្ពុជា ដើម្បីឈានទៅដល់ការទទួលបាននូវអត្ថប្រយោជន៍ជាច្រើន។

និយ័តករមូលបត្រកម្ពុជាហៅកាត់ថា ន.ម.ក. ត្រូវបានបង្កើតឡើងក្នុងគោលបំណងគ្រប់គ្រងវិស័យមូលបត្រនៅក្នុងប្រទេស ជាសម្រួលដល់កិច្ចដំណើរការមូលបត្រឲ្យប្រព្រឹត្តទៅបានដោយរលូន និងលើកកម្ពស់ការអភិវឌ្ឍទីផ្សារមូលបត្រឲ្យមានប្រសិទ្ធភាព ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ និយ័តករមូលបត្រ

[1] https://www.worldbank.org/en/country/cambodia/overview គេហទំព័ររបស់ធនាគារពិភពលោក (២០២១), ធនាគារពិភពលោកនៅប្រទេសកម្ពុជា

កម្ពុជាបានដាក់សម្ពោធគម្រោងបង្កើតផ្សារមូលបត្រកម្ពុជានៅខែកញ្ញា ឆ្នាំ២០០៧ បន្ទាប់មកក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាហៅកាត់ថា ផ.ម.ក. ក៏ត្រូវបានដាក់សម្ពោធជាផ្លូវការនៅខែកក្កដាឆ្នាំ ២០១១ ដែលជាផ្នែកមួយនៃការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០០៦-២០១៥។[2]

ដោយឃើញថាវិស័យមូលបត្រនៅប្រទេសកម្ពុជាមានការរីកចម្រើនជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ព្រមទាំងផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដល់វិនិយោគិនទាំងឡាយ និងសេដ្ឋកិច្ចរបស់ប្រទេសទាំងមូលផងដែរ ប្រធានស្តីពី «នីតិវិធីនៃការជួញដូរមូលបត្រកម្មសិទ្ធិ» ត្រូវបានលើកយកមកធ្វើការសិក្សាស្រាវជ្រាវឲ្យលម្អិត និងចូលរួមដោះស្រាយនូវចម្ងល់មួយចំនួនដែលកើតមានឡើងពីសំណាក់វិនិយោគិន ដែលមានចំណាប់អារម្មណ៍ក្នុងការចាប់ផ្តើមសិក្សាអំពីមូលបត្រ និងចង់ចូលរួមក្នុងវិស័យជួញដូរមូលបត្រកម្មសិទ្ធិនេះ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជាមាននិយ័តករមូលបត្រកម្ពុជា (ន.ម.ក.) និងផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) ដែលដើរតួយ៉ាងសំខាន់ក្នុងការចូលរួមអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជាឲ្យដំណើរការទៅមុខយ៉ាងរលូនល្អ ហើយការកកើតនៃផ្សារមូលបត្រនេះបានក្លាយទៅជាព្រឹត្តិការណ៍ឈានមុខគេមួយសម្រាប់ប្រទេសកម្ពុជា។ បច្ចុប្បន្ននេះ មូលបត្រកម្មសិទ្ធិ ឬភាគហ៊ុនទទួលបានការគាំទ្រយ៉ាងខ្លាំងពីសំណាក់អ្នកវិនិយោគជាច្រើន។

ប៉ុន្តែទោះបីជារាជរដ្ឋាភិបាលបានរួមចំណែកក្នុងការជួយជ្រោមជ្រែងឲ្យវិស័យមូលបត្រ នៅកម្ពុជាអាចបន្តទៅមុខបានដោយប្រសិទ្ធភាពក៏ដោយ យើងសង្កេតឃើញថាការវិនិយោគលើមូលបត្រកម្មសិទ្ធិនៅតែចោទជាបញ្ហា ជាពិសេសសម្រាប់ប្រជាពលរដ្ឋកម្ពុជា ឬអ្នកវិនិយោគថ្មី ដែលពួកគេពុំទាន់បានសិក្សាយល់ដឹងឲ្យស៊ីជម្រៅអំពីដំណើរការនៃការជួញដូរមូលបត្រនៅលើទីផ្សារនៅឡើយ។

ការលើកប្រធានបទ «នីតិវិធីនៃការជួញដូរមូលបត្រកម្មសិទ្ធិ» មកធ្វើការស្រាវជ្រាវ ដើម្បីស្រាយបំភ្លឺនូវចម្ងល់របស់វិនិយោគិនឲ្យជ្រាបកាន់តែច្បាស់ខាងក្រោម៖

- តើការជួញដូរមូលបត្រកម្មសិទ្ធិដំណើរទៅយ៉ាងដូចម្តេច?
- តើវិនិយោគិនត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះ មុននឹងធ្វើការវិនិយោគទៅលើមូលបត្រកម្មសិទ្ធិ?
- តើវិនិយោគិននឹងទទួលបានអត្ថប្រយោជន៍អ្វីខ្លះពីការវិនិយោគនេះ?

[2] https://www.b2b-cambodia.com/industry-overviews/banking-finance/ គេហទំព័ររបស់ B2B Cambodia (២០២១), ធនាគារនិងហិរញ្ញវត្ថុនៅប្រទេសកម្ពុជា

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងរួមនៃការសិក្សាស្រាវជ្រាវនេះ គឺដើម្បីស្វែងយល់ពីនីតិវិធីនៃការជួញដូរមូលបត្រកម្មសិទ្ធិ។ ដោយឡែកគោលបំណងជាក់លាក់លើប្រធានបទនេះមានដូចខាងក្រោម៖

- លក្ខខណ្ឌដែលត្រូវបំពេញមុននឹងក្លាយជាវិនិយោគិនស្របច្បាប់
- លក្ខខណ្ឌតម្រូវមុននឹងអាចជួញដូរមូលបត្របាន
- ដំណើរការជួញដូរមូលបត្រកម្មសិទ្ធិ។

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវរបស់ប្រធានបទនេះគឺ៖

- ការស្រាវជ្រាវផ្តោតទៅលើមូលបត្រកម្មសិទ្ធិតែប៉ុណ្ណោះ
- សិក្សាតែការជួញដូរមូលបត្រកម្មសិទ្ធិនៅផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) លើទីផ្សារបន្ទាប់
- សិក្សាស្រាវជ្រាវលើឯកសារ និងទិន្នន័យពីឆ្នាំ ២០១៩ និងឆ្នាំ ២០២០។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទនីតិវិធីនៃការជួញដូរមូលបត្រកម្មសិទ្ធិត្រូវពឹងផ្អែកលើប្រភពទិន្នន័យ និងការវិភាគទិន្នន័យដូចខាងក្រោម៖

### ៥.១ ការប្រមូលទិន្នន័យ

ការសិក្សាស្រាវជ្រាវនេះប្រើទិន្នន័យដែលមានស្រាប់ (បន្ទាប់បន្សំ) (Secondary data) រួមមានដូចជា៖

- ទិន្នន័យតាមប្រព័ន្ធអ៊ីនធឺណែត
- សៀវភៅ និងឯកសារពាក់ព័ន្ធប្រធានបទក្នុងបណ្ណាល័យ
- សារណាឬរបាយការណ៍បញ្ចប់ការសិក្សារបស់និស្សិតជំនាន់មុនៗ។

### ៥.២ ការវិភាគទិន្នន័យ

បន្ទាប់ពីទទួលបានប្រភពទិន្និន័យ និងទិន្នន័យដែលបានប្រមូលរួមមក ត្រូវឲ្យមានការបកស្រាយលើទិន្និន័យឲ្យអ្នកអាន និងអ្នកសិក្សាស្រាវជ្រាវងាយយល់លើប្រធានបទនេះ គឺប្រើប្រាស់ការវិភាគតាមបែបគុណវិស័យ (Qualitative Research Approach) ដើម្បីពិពណ៌នាឲ្យបានលម្អិត។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

សរុបសេចក្តីមក ការស្រាវជ្រាវលើប្រធានបទនេះនឹងផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដូចជា៖

- ចំពោះនាងខ្ញុំ៖ ទទួលបានបទពិសោធន៍ក្នុងការស្រាវជ្រាវ និងផ្តល់ជាចំណេះដឹងពីការជួញដូរមូលបត្របន្ថែមពីលើទ្រឹស្តីដែលបានរៀនរួចហើយ។

- ចំពោះអ្នកវិនិយោគ៖ វិនិយោគិនអាចទទួលបានចំណេះដឹងបន្ថែមឲ្យកាន់តែច្បាស់ ទាក់ទងនឹងការជួញដូរបណ្ណភាគហ៊ុន និងទុកជាពត៌មាន ឬឯកសារសម្រាប់សាធារណជន ដែលមានបំណងចង់ស្វែងយល់ពីវិស័យមូលបត្រកម្មសិទ្ធិនៅកម្ពុជា។
- ចំពោះស្ថាប័នបោះផ្សាយ៖ ជាពត៌មានសម្រាប់គ្រប់មជ្ឈដ្ឋានដែលមានតម្រូវការ និងអាចជាផ្នែកមួយនៃការពិចារណាទៅលើចំណុចខ្វះខាត ដែលក្រុមហ៊ុនមានដោយចៃដន្យ។
- ចំពោះសិស្សនិស្សិត៖ ជាឯកសារសំរាប់សិស្ស និស្សិតជំនាន់ក្រោយ ដែលមានបំណងចង់ស្រាវជ្រាវពីប្រធានបទនេះ និងផ្តល់ពត៌មានបន្ថែមដល់និស្សិតដែលចង់សិក្សាស្វែងយល់ទាក់ទងនឹងការជួញដូរមូលបត្រកម្មសិទ្ធិ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ខាងក្រោមនេះជារចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវលើស្តីពីនីតិវិធីនៃការជួញដូរមូលបត្រកម្មសិទ្ធិ៖



# ជំពូកទី១

# រំលឹកទ្រឹស្តី

# ជំពូកទី១
# រំលឹកទ្រឹស្តី

## ១.១ ទីផ្សារមូលបត្រកម្មសិទ្ធិ

### ១.១.១ និយមន័យ

ផ្សារមូលបត្រកម្មសិទ្ធិកើតចេញពីបន្សំនៃពាក្យ ទីផ្សារ និងមូលបត្រកម្មសិទ្ធិ។ ទីផ្សារ គឺជាការដោះដូររវាងអ្នកផ្គត់ផ្គង់ និងអ្នកមានតម្រូវការនូវរាល់ទំនិញនិងសេវាកម្ម ជាមួយនឹងបរិមាណផលិតផលនិងតម្លៃសមរម្យក្រោមការប្រកួតប្រជែង បើទោះបីជាអ្នកផ្គត់ផ្គង់និងអ្នកមានតម្រូវការ ពុំបានជួបមុខគ្នាក្នុងកន្លែងកំណត់ណាមួយក៏ដោយ។[3] មូលបត្រ សំដៅដល់គំរូបណ្ណដែលអាចធ្វើការដោះដូរជាសាធារណៈបាន ឬនៅលើទីផ្សារមូលបត្រ។ រីឯមូលបត្រកម្មសិទ្ធិវិញ សំដៅដល់មូលបត្រជាភាគហ៊ុន ឬបញ្ជាក់ពីភាពជាម្ចាស់កម្មសិទ្ធិរបស់ក្រុមហ៊ុនណាមួយ។ វិនិយោគិនដែលកាន់កាប់មូលបត្រកម្មសិទ្ធិ គឺជាម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុន។

តាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន បានកំណត់និយមន័យនៃពាក្យមូលបត្រមហាជន គឺសំដៅដល់ផលប្រយោជន៍ ឬសិទ្ធិស្របច្បាប់លើមូលបត្រនៃក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនិតិបុគ្គលបរទេសប្រហាក់ប្រហែលហើយរាប់បញ្ចូលទាំងភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត និងគ្មានសិទ្ធិបោះឆ្នោត ភាគហ៊ុនបង់ថ្លៃមិនគ្រប់ និងភាគហ៊ុនបុរិមា។ ទីផ្សារមូលបត្រសំដៅដល់ទីផ្សារ ឬទីកន្លែងជួញដូរមូលបត្រ ឬប្រព័ន្ធដែលផ្តល់មធ្យោបាយនៃការធ្វើសំណើលក់ ផ្ទេរ ឬការទិញ-លក់មូលបត្រឧបករណ៍ហិរញ្ញវត្ថុ ដែលតែងតែត្រូវបានជួញដូរលើទីផ្សារនេះរួមមានមូលបត្រកម្មសិទ្ធិ មូលបត្របំណុល និងឧបករណ៍និស្សន្ទជាដើម។[4]

### ១.១.២ ប្រវត្តិទីផ្សារមូលបត្រកម្មសិទ្ធិ

ទីផ្សារភាគហ៊ុន (Stock Market) មានប្រវត្តិតាំងពីយូរយារណាស់មកហើយ។[5] ទីផ្សារភាគហ៊ុនប្រើប្រាស់រយៈពេលអស់រាប់សតវត្សក្នុងការវិវត្តន៍ ដែលបច្ចុប្បន្នទីផ្សារនេះត្រូវបានគេស្គាល់ថាជា ទីផ្សារមូលបត្រ (Securities Market)។ ប៉ុន្តែប្រទេសជាច្រើននៅតែពេញនិយមក្នុងការប្រើប្រាស់ពាក្យ «ទីផ្សារភាគហ៊ុន» ជាជាង «ទីផ្សារមូលបត្រ» ដដែល។

---

[3] https://khemsaritheducation.wordpress.com/2018/05/16/ចូរឲ្យនិយមន័យទីផ្សារ/ គេហទំព័រ khemsaritheducation (២០១៨), ចូរឲ្យនិយមន័យទីផ្សារ

[4] ច្បាប់ពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, ១២ កញ្ញា ២០០៧

[5] http://siborann.blogspot.com/2011/09/blog-post_09.html គេហទំព័រ Investment (២០១១), ប្រវត្តិទីផ្សារមូលបត្រ

ទីផ្សារភាគហ៊ុនត្រូវបានបង្កើតឡើងដំបូងនៅដើមសតវត្សន៍ទី១៧ នៅលើទឹកដីអឺរ៉ុប។[6] នៅគ្រិស្តករាជ ១៦០២ មានអ្នកជំនួញជាច្រើននៅទីក្រុងអាំស្ទែដាំ សាធាណរដ្ឋហូឡង់ បានចាប់ផ្តើមចេះបង្កើតសហគ្រាសធំៗ និងប្រកបអាជីវកម្មខ្នាតធំដែលត្រូវការដើមទុនច្រើន ប៉ុន្តែពួកគេបែរជាជួបនូវបញ្ហាខ្វះទុនពង្រីកសហគ្រាស និង អាជីវកម្មទាំងនោះ។ ហេតុនេះហើយ ពួកគេក៏ផ្តើមមានគំនិតបើកឲ្យមានការសន្សំដើមទុនរួម ដោយអ្នកជំនួញទាំងអស់ប្រមូលយកប្រាក់សន្សំទាំងនោះសម្រាប់ធ្វើជាទុនក្នុងការវិនិយោគ ហើយមានការបែងចែកភាគហ៊ុនរៀងៗខ្លួននៅក្នុងអាជីវកម្មខ្នាតធំនោះ។

បន្ទាប់មក នៅឆ្នាំដដែល ក្រុមហ៊ុនឌឺ ឌាចហ៍ អីស ឥណ្ឌា (The Dutch East India) ជាក្រុមហ៊ុនដំបូងគេបង្អស់ ដែលបោះផ្សាយក្រដាសដែលតំណាងឲ្យភាគហ៊ុន ដើម្បីប្រមូលទុនសម្រាប់ការវិនិយោគ និងជួញដូរទិញលក់ជាមួយម្ចាស់អាជីវកម្មផ្សេងទៀត។ ភាគរយនៃផលចំណេញរបស់ក្រុមហ៊ុនត្រូវបានផ្តល់ជូនដល់អ្នកទិញដោយអាស្រ័យទៅនឹងភាគហ៊ុនដែលមាន។ ភាគហ៊ុនរបស់ The Dutch East India Company ត្រូវបានគេជួញដូរនៅលើទីផ្សារ អាំស្ទែដាំ (Amsterdam Market) រហូតលេចចេញការជួញដូរនៅលើ ក្រុមហ៊ុនផ្សារអាំស្ទែដាំ (Amsterdam Exchange)។ ការជួញដូរភាគហ៊ុនបានរីករាលដាលទៅដល់ប្រទេសព័រទុយហ្កាល់ អេស្ប៉ាញ បារាំង ចក្រភពអង់គ្លេសជាដើម នាំឲ្យពួកគេបានចាប់ផ្តើមបង្កើតឲ្យមានការលក់ភាគហ៊ុន ដើម្បីជាឧបករណ៍ក្នុងការប្រមូលដើមទុនយកទៅពង្រីកមុខជំនួញរហូតធ្វើឲ្យមានចរន្តនៃបដិវត្តឧស្សាហកម្មលើកដំបូង នាសតវត្សរ៍ទី ១៨។

ការជួញដូរភាគហ៊ុនកាន់តែរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃរហូតដល់គ្រិស្តសករាជ ១៧៧៣។ ជាមួយគ្នានោះ អ្នកជំនួញមកពីគ្រប់ទីកន្លែងក៏បានមកជួបជុំគ្នាក្នុងហាងកាហ្វេក្នុងទីក្រុងឡុងដ៍ ចក្រភពអង់គ្លេស ហើយពួកគេបានសម្រេចចិត្តប្រែឈ្មោះហាងកាហ្វេនោះទៅជាទីផ្សារភាគហ៊ុន ដែលមានឈ្មោះថា The London Stock Exchange ដោយបានរៀបចំឲ្យមានការគ្រប់គ្រងបានយ៉ាងត្រឹមត្រូវ។ គំនិតនៃការបង្កើតទីផ្សារមូលបត្រនេះក៏បានរីករាលដាល និងបន្តសាយភាយទៅដល់ប្រទេសផ្សេងៗនៅលើពិភពលោករហូតដល់បច្ចុប្បន្ន ហើយទីផ្សារមូលបត្រដែលធំៗជាងគេ មាននៅក្នុង សហរដ្ឋអាមេរិច ចក្រភពអង់គ្លេស ជប៉ុន ឥណ្ឌា ចិន កាណាដា អាឡឺម៉ង់ បារាំង កូរ៉េខាងត្បូង និងហូឡង់។

## ១.២ ប្រភេទនៃមូលបត្រកម្មសិទ្ធិ

មូលបត្រកម្មសិទ្ធិ គឺជាឧបករណ៍ហិរញ្ញវត្ថុមួយប្រភេទដែលត្រូវបានបង្កើតឡើងសម្រាប់ប្រមូលទុនបន្ថែមពីសាធារណៈជនដើម្បីវិនិយោគនៅក្នុងក្រុមហ៊ុនរបស់ខ្លួន។ ក្រុមហ៊ុនដែលត្រូវការដើមទុន ឬហិរញ្ញប្បទាន

[6] https://khmerpostasia.com/archives/62791 គេហទំព័រ ខ្មែរប៉ុស្តិ៍ (២០២០), ស្វែងយល់ពីប្រវត្តិនៃ «ទីផ្សារមូលបត្រ»

បន្ថែមបោះផ្សាយមូលបត្រកម្មសិទ្ធិនេះលក់ ហើយមូលបត្រប្រភេទនេះយើងអាចរកទិញបានតាមរយៈការបោះផ្សាយលក់ជាសាធារណៈនៅទីផ្សារដំបូង។ សាធារណៈជន ឬវិនិយោគិន ដែលទិញមូលបត្រប្រភេទនេះនឹងក្លាយជាម្ចាស់កម្មសិទ្ធិ ឬភាគហ៊ុនិកមួយចំណែកនៃក្រុមហ៊ុននោះ ហើយមានសិទ្ធិទទួលបានផលប្រយោជន៍ពីចំណូល និងទ្រព្យសកម្មរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រនោះ។ នៅក្នុងទីផ្សារមូលបត្រ គេបែងចែកមូលបត្រកម្មសិទ្ធិជា ២ ប្រភេទគឺ៖ ភាគហ៊ុនធម្មតា (Common stock) និង ភាគហ៊ុនបុរិមា (Preferred stock) ។

### ១.២.១ ភាគហ៊ុនធម្មតា

ភាគហ៊ុនធម្មតា គឺជាភាគហ៊ុនដែលមានការលើកទឹកចិត្តដោយផ្ទាល់ដល់ភាគហ៊ុនិកតាមរយៈភាគលាភ ដែលទទួលបានពីប្រាក់ចំណេញរបស់ក្រុមហ៊ុន ការចំណេញលើមូលធន និងសិទ្ធិក្នុងការទិញភាគហ៊ុនថ្មីរបស់ក្រុមហ៊ុន នៅពេលដែលក្រុមហ៊ុនសម្រេចក្នុងការបង្កើនដើមទុនចុះបញ្ជីរបស់ខ្លួន។[7] អ្នកដែលទិញភាគហ៊ុនធម្មតានេះ គឺតំណាងឲ្យភាពជាម្ចាស់នៅក្នុងក្រុមហ៊ុនហើយមានសិទ្ធិបោះឆ្នោតក្នុងការសម្រេចរាល់ប្រតិបត្តិការរបស់ក្រុមហ៊ុន និងលើទិសដៅ គោលនយោបាយក្រុមហ៊ុន ព្រមទាំងជ្រើសរើសក្រុមប្រឹក្សាភិបាលជាដើម។ ប្រសិនបើក្រុមហ៊ុនក្ស័យធន ម្ចាស់ភាគហ៊ុនធម្មតានឹងទទួលបានការទូទាត់សង ក្រោយម្ចាស់ភាគហ៊ុនបុរិមា ម្ចាស់សញ្ញាបណ្ណ និងម្ចាស់បំណុល។ ប៉ុន្តែទោះយ៉ាងណា ម្ចាស់ភាគហ៊ុនធម្មតាទទួលបានចំណេញពីដំណើរការអាជីវកម្មរបស់ក្រុមហ៊ុនជាងម្ចាស់ភាគហ៊ុនបុរិមា និងម្ចាស់សញ្ញាបណ្ណ ដោយអាស្រ័យទៅតាមស្ថានភាពអាជីវកម្មរបស់ក្រុមហ៊ុនបោះផ្សាយ។

### ១.២.២ ភាគហ៊ុនបុរិមា

ភាគហ៊ុនបុរិមាក៏ជាផ្នែកមួយនៃទ្រព្យកម្មសិទ្ធិផងដែរ។ អ្នកកាន់កាប់ភាគហ៊ុននេះ ពុំមានសិទ្ធិក្នុងការបោះឆ្នោតឡើយ។ ជាទូទៅ ម្ចាស់ភាគហ៊ុនបុរិមាមានអាទិភាពក្នុងការទទួលបានការទូទាត់ភាគលាភមុនម្ចាស់ភាគហ៊ុនធម្មតា។ ភាគលាភរបស់ភាគហ៊ុនបុរិមាពុំមានការធានាថា អាចនឹងត្រូវបានក្រុមហ៊ុនទូទាត់នោះទេ ប៉ុន្តែប្រសិនបើក្រុមហ៊ុនធ្វើការទូទាត់ភាគលាភ នោះក្រុមហ៊ុនត្រូវធ្វើការទូទាត់មុនគេទៅឲ្យម្ចាស់ភាគហ៊ុនបុរិមា តាមអត្រាភាគលាភថេរមួយ ដែលបានកំណត់លើបណ្ណភាគហ៊ុនបុរិមានោះ មុនពេលក្រុមហ៊ុនធ្វើការទូទាត់ភាគលាភឲ្យទៅម្ចាស់ភាគហ៊ុនធម្មតា។[8] នៅពេលក្រុមហ៊ុនក្ស័យធន ម្ចាស់ភាគហ៊ុនបុរិមាមានអាទិភាពក្នុងការទទួលបានការទូទាត់សងការ

[7] http://csx.com.kh/kh/product/equities.jsp?MNCD=4020 គេហទំព័ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (២០២១), មូលបត្រកម្មសិទ្ធិ

[8] http://siborann.blogspot.com/2011/09/blog-post_8065.html?m=1 គេហទំព័រ Investment (២០១១), ភាគហ៊ុនធម្មតា និងភាគហ៊ុនបុរិមា

ខូចខាតមុនគេ ហើយចំពោះការទូទាត់សងថ្លៃការខូចខាតនេះ គឺអាចទូទាត់សងស្មើនឹងតម្លៃដើមរបស់ភាគហ៊ុននៅពេលវាបោះផ្សាយលក់ ពោលគឺតាមតម្លៃចារឹកនៃភាគហ៊ុនបុរិមា។ ម្យ៉ាងទៀតភាគហ៊ុនបុរិមាអាចមានលក្ខណៈ អាចប្តូរទៅជាភាគហ៊ុនធម្មតាបាន ដែលលក្ខណៈនេះកំណត់ដោយលក្ខខណ្ឌដែលមានចុះក្នុងបណ្ណភាគហ៊ុន ឬវិញ្ញាបនបត្រភាគហ៊ុននៅពេលបោះផ្សាយលក់។

## ១.៣ ប្រភេទទីផ្សារមូលបត្រ

### ១.៣.១ ទីផ្សារដំបូង

រូបភាពទី ១.១ ដំណើរការនៃការទិញមូលបត្រនៅក្នុងទីផ្សារដំបូង




ទីផ្សារដំបូង គឺជាកន្លែងដែលមូលបត្រត្រូវបានបោះចេញដោយក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ លក់ទៅឲ្យសាធារណជន ឬវិនិយោគិនដើម្បីទទួលបាននូវហិរញ្ញប្បទាន ឬមូលធនយកទៅវិនិយោគ ឬពង្រីកអាជីវកម្ម។ ក្រុមហ៊ុនដែលមានបំណងចង់បោះផ្សាយលក់មូលបត្រត្រូវទៅរកជំនួយពីក្រុមហ៊ុនមូលបត្រ ដើម្បីជួយក្នុងការរៀបចំឯកសារ និងកិច្ចដំណើរការនៃការបោះផ្សាយនោះ។ ក្រុមហ៊ុនមូលបត្រ ដែលមានតួនាទីក្នុងការជួយសម្របសម្រួល គឺជាក្រុមហ៊ុនមានអាជ្ញាបណ្ណជាប្រភេទក្រុមហ៊ុនធានាទិញមូលបត្រដើម្បីជួយរៀបចំឯកសារ ផ្តល់ពត៌មាន ដែលបង្ហាញពត៌មានលំអិតទៅកាន់ក្រុមហ៊ុនដែលមានបំណងចង់បោះផ្សាយនោះ។ នៅក្នុងទីផ្សារដំបូង វិនិយោគិនត្រូវធ្វើការបញ្ជាទិញមូលបត្រដោយផ្ទាល់ពីក្រុមហ៊ុនបោះផ្សាយនៅក្នុងដំណាក់កាលប៉ុកបៀលឌីង (Book building) ឬការស្ទាបស្ទង់ថ្លៃ ឬការធ្វើបរិវិសកម្ម (subscription) ឬការចុះឈ្មោះទិញ។ ចំពោះសាច់ប្រាក់នៅក្នុងទីផ្សារដំបូង គឺចេញពីវិនិយោគិនទៅកាន់ក្រុមហ៊ុនបោះផ្សាយហើយវិនិយោគិនដែលបានទិញមូលបត្រពីក្រុមហ៊ុនបោះផ្សាយនឹងក្លាយជាម្ចាស់ភាគហ៊ុនមួយចំណែកនៃក្រុមហ៊ុនបោះផ្សាយនោះ។

### ១.៣.២ ទីផ្សារបន្ទាប់

រូបភាពទី ១.២ ដំណើរការនៃការទិញមូលបត្រនៅក្នុងទីផ្សារបន្ទាប់




ទីផ្សារបន្ទាប់ គឺជាកន្លែងដែលធ្វើការទិញលក់មូលបត្ររវាងវិនិយោគិន និងវិនិយោគិន។ ទីផ្សារមូលបត្របានអនុញ្ញាតឲ្យវិនិយោគិនធ្វើការជួញដូរមូលបត្រនៅក្នុងទីផ្សារបន្ទាប់នេះ ប៉ុន្តែមិនមែនជួញដូរដោយផ្ទាល់នៅទីផ្សារនោះទេ គឺតាមរយៈក្រុមហ៊ុនមូលបត្រដែលជាប្រតិបត្តិករទីផ្សារមូលបត្រ។ ដោយសារមូលបត្រមានទម្រង់ជាអរូបិយ ដូច្នេះរាល់ទិន្នន័យទាំងអស់ត្រូវធ្វើតាមប្រព័ន្ធ។ វិនិយោគិនទិញមូលបត្រនៅក្នុងទីផ្សារដំបូង អាចលក់មូលបត្រនោះវិញបាននៅក្នុងទីផ្សារបន្ទាប់ ហើយចំពោះអ្នកទិញមូលបត្រនៅក្នុងទីផ្សារនេះនឹងក្លាយជាភាគហ៊ុនិកថ្មី ចំណែកឯអ្នកលក់នឹងទទួលបានសាច់ប្រាក់។ សាច់ប្រាក់ដែលបានមកពីការជួញដូរលើទីផ្សារនេះ គឺបានទៅលើអ្នកកាន់កាប់មូលបត្រ មិនមែនក្រុមហ៊ុនបោះផ្សាយលក់មូលបត្រឡើយ ពោលគឺក្រុមហ៊ុនបោះផ្សាយលក់មូលបត្រមិនទទួលបានផលប្រយោជន៍ពីការជួញដូរលើទីផ្សារបន្ទាប់ទេ។ នៅលើទីផ្សារបន្ទាប់ មូលបត្រត្រូវបានគេជួញដូរតាម៖

- Organized Exchanged Market: គឺជាកន្លែងជួញដូរមានទីតាំងច្បាស់លាស់ ដែលអ្នកទិញ និងអ្នកលក់ជួបគ្នាក្នុងមូលដ្ឋានទូទៅមួយ ដើម្បីជួញដូរមូលបត្រដោយប្រើប្រាស់ម៉ូដែលដេញថ្លៃ «Open-Outcry»
- Over the Counter Market: គឺជាទីផ្សារមួយដែលមិនត្រូវបានរៀបចំនៅអគារជាក់លាក់នោះទេ។ ការជួញដូរ គឺកើតឡើងទៅតាមបណ្តាញទំនាក់ទំនងពត៌មានវិទ្យា។[9]

[9] ឡេង សុភក្រ្ត et al. (២០១៨), ស្ថាប័ន និង ទីផ្សារហិរញ្ញវត្ថុ, ទំព័រទី ៧១-៧២

## ១.៤ អត្ថប្រយោជន៍នៃទីផ្សារមូលបត្រកម្ពុជា

### ១.៤.១ អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះសេដ្ឋកិច្ចជាតិ

ទីផ្សារមូលបត្រ គឺជាកត្តាមូលដ្ឋានមួយយ៉ាងសំខាន់សម្រាប់សេដ្ឋកិច្ចជាតិ និងជានិមិត្តរូបនៃសេដ្ឋកិច្ចជាតិទាំងមូល។[10] ជាការពិតណាស់ រាល់បម្រែបម្រួលនៃបរិបទជាតិ និងអន្តរជាតិ (សេដ្ឋកិច្ច សង្គម និងនយោបាយ) វានឹងធ្វើឲ្យមានផលប៉ះពាល់ទៅដល់ទីផ្សារមូលបត្រភ្លាម ដោយគ្រាន់តែមើលទៅលើសន្ទស្សន៍ហ៊ុនរបស់ផ្សារមូលបត្រ ព្រោះវាបានឆ្លុះបញ្ចាំងពីស្ថានភាពសេដ្ឋកិច្ចជាតិ។ ហេតុនេះ ស្ទើរតែគ្រប់បណ្តាប្រទេសអភិវឌ្ឍ និងកំពុងអភិវឌ្ឍ មានទីផ្សារមូលបត្រនេះ ហើយវាបានដើរតួនាទីយ៉ាងសំខាន់ចំពោះសេដ្ឋកិច្ចជាតិមានដូចតទៅ៖

- ទីផ្សារមូលបត្រជួយជម្រុញឲ្យមហាជនបង្កើននូវការសន្សំ និងកៀរគរមូលធនដែលនៅសេសសល់ មិនមានតម្រូវការប្រើប្រាស់យកទៅវិនិយោគក្នុងសេដ្ឋកិច្ច។
- ទីផ្សារមូលបត្រ គឺជាមធ្យោបាយមួយប្រមែប្រមូលកៀរគរនូវប្រភពមូលធនដែលនៅទំនេរតូចៗមិនទាន់មានតម្រូវការប្រើប្រាស់ ពូនផ្តុំជាមូលធនធំមួយដើម្បីវិនិយោគក្នុងវិស័យសេដ្ឋកិច្ចរូបវន្ត។
- ទីផ្សារមូលបត្រ គឺជាឧបករណ៍មួយជួយសម្រួលដល់រាជរដ្ឋាភិបាល ក្នុងការអនុវត្តន៍នូវកម្មវិធីអភិវឌ្ឍសេដ្ឋកិច្ច-សង្គម។
- ទីផ្សារមូលបត្រ គឺជាឧបករណ៍មួយដើម្បីទាក់ទាញ និងស្រូបយកនូវមូលធនពីបរទេស។
- ទីផ្សារមូលបត្រជួយជម្រុញឲ្យបណ្តាក្រុមហ៊ុននានា ប្រកបអាជីវកម្មដោយប្រសិទ្ធភាព និងមានតម្លាភាព។
- ទីផ្សារមូលបត្រជួយជម្រុញឲ្យប្រភពមូលធនក្នុងស្រុកមានចរាចរ ឬចលនារស់រវើក។
- ទីផ្សារមូលបត្រជួយបង្កើតនូវទម្លាប់នៃការវិនិយោគ។

### ១.៤.២ អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះវិនិយោគិន

លើសពីនេះទៅទៀត ការវិនិយោគទៅលើមូលបត្រកម្មសិទ្ធិ ឬភាគហ៊ុន ផ្តល់ឲ្យវិនិយោគិននូវអត្ថប្រយោជន៍ជាច្រើន[11] ដូចជា៖

- ក្លាយជាភាគហ៊ុនិក ឬម្ចាស់មួយចំណែកនៃក្រុមហ៊ុនបោះផ្សាយលក់មូលបត្រណាមួយ ដែលភាពជាម្ចាស់នោះសមាមាត្រទៅនឹងចំនួនភាគហ៊ុនដែលខ្លួនមាន

[10] http://www.SERC.gov.kh/khmer/faq.php?pn=2 គេហទំព័ររបស់និយ័តករមូលបត្រកម្ពុជា (២០២០), សំនួរ-ចម្លើយ

[11] សុខ ពិសិដ្ឋ, ២០២០-២០២១, ទីផ្សារមូលបត្រកម្ពុជា

- សិទ្ធិទទួលបានពត៌មានសំខាន់ៗរបស់ក្រុមហ៊ុន ដោយរាល់ពត៌មានទាំងអស់ដែលក្រុមហ៊ុនធ្វើការផ្សព្វផ្សាយជាសាធារណៈ ដូចជាពត៌មានជាប្រចាំត្រីមាស ជាប្រចាំឆ្នាំទាក់ទងនឹងរបាយការណ៍ហិរញ្ញវត្ថុផ្សេងៗ ពត៌មានបន្ទាន់ពិសេសមួយចំនួនពាក់ព័ន្ធនឹងក្រុមហ៊ុន
- មានសិទ្ធិចូលរួមមហាសន្និបាតភាគហ៊ុនិក និងមានសិទ្ធិបោះឆ្នោត (១ភាគហ៊ុន=១សម្លេង)
- មានសិទ្ធិធ្វើការទិញលក់ និងផ្ទេរមូលបត្រដោយសេរី
- ទទួលបានភាគលាភដែលជាចំណែកនៃប្រាក់ចំណេញ បានពីសកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុននៅក្នុងរយៈពេលមួយឆ្នាំ បែងចែកទៅតាមការកំណត់របស់ក្រុមហ៊ុន អាស្រ័យទៅលើគោលនយោបាយភាគលាភរបស់ក្រុមហ៊ុននីមួយៗដែលបានដាក់ចេញនៅដើមឆ្នាំ សម្រាប់អនុវត្តនៅចុងឆ្នាំ។
- ភាគហ៊ុនិកទទួលបានប្រាក់ចំណេញមូលធន ដែលបានពីការលក់មូលបត្រក្នុងតម្លៃខ្ពស់ជាងតម្លៃទិញរបស់ខ្លួនពីមុន។
- វិនិយោគិនដែលមានដើមទុនតិចក៏អាចចូលរួមវិនិយោគនៅក្នុងទីផ្សារមូលបត្រ ដោយការជួញដូរភាគហ៊ុននៅក្នុងទីផ្សារមូលបត្រកម្ពុជា គឺអនុញ្ញាតឲ្យជួញដូរចាប់ពីមួយភាគហ៊ុនឡើងទៅ ទោះមិនមានដើមទុន ឬថវិការច្រើនក៏អាចទិញភាគហ៊ុនបាន។
- បច្ចុប្បន្នវិនិយោគិនអាចជួញដូរបានគ្រប់ទីកន្លែង និងទៅតាមម៉ោងជួញដូរ៖ អាចធ្វើការជួញដូរបាន ៧ម៉ោងក្នុងមួយថ្ងៃ ៥ថ្ងៃក្នុងមួយសប្តាហ៍។ វិនិយោគិនអាចប្រើប្រាស់នូវមធ្យោបាយជួញដូរតាមរយៈទូរស័ព្ទដៃ ថេបប្លេក កុំព្យូទ័រ ធ្វើការបញ្ជាដោយផ្ទាល់។ បច្ចុប្បន្ននេះ ផ្សារមូលបត្របានធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធ ដើម្បីសម្រួលដល់វិនិយោគិនមួយកម្រិត គឺវិនិយោគិនអាចធ្វើការបញ្ជាតាមប្រព័ន្ធជួញដូរចល័ត្រ mobile trading system ដែលវិធីជួញដូរផ្អែកលើគេហទំព័រ web base ហើយអាចចូលទៅអាចដាក់បញ្ជាជួញដូរ ឆែកប្រតិបត្តិការផ្សេងៗ បញ្ជាដកប្រាក់បាន។
- ការវិនិយោគលើភាគហ៊ុនទទួលបានប្រាក់ចំណេញច្រើន បានទាំងភាគលាភ និងប្រាក់ចំណេញមូលធន។
- មិនមានពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិករភាគហ៊ុន ពន្ធលើភាគលាភសម្រាប់និវេសជន (កាត់បន្ថយ ៥០%សម្រាប់អនិវេសជន) និងពន្ធលើប្រាក់ចំណេញមូលធន (ពន្យារការអនុវត្តមួយឆ្នាំ)។ មិនមានការយកពន្ធលើភាគលាភទេសម្រាប់និវាសនជន (អ្នករស់នៅប្រទេសកម្ពុជា ក្នុងច្បាប់ចែងថាចាប់ពី ១៨២ថ្ងៃឡើងទៅ ក្នុងរយៈពេល១២ខែ) ចំពោះអនិវេសនជន ប្រសិនបើទទួលបានភាគលាភ រដ្ឋកាត់ពន្ធ តែអនុគ្រោះនៅត្រឹម ៥០%នៃអត្រាពន្ធ។ ឆ្នាំ ២០២០ អគ្គនាយកដ្ឋានពន្ធដារបានចេញប្រកាសអំពីការ

ប្រមូលពន្ធលើការចំណេញមូលធនដោយរាប់បញ្ចូលទាំងវិស័យមូលបត្រ[12] ដូចនេះប្រាក់ចំណេញមូលធនក្នុងវិស័យមូលបត្រនឹងត្រូវបានធ្វើការកាត់ពន្ធដោយផ្អែកទៅលើប្រកាសដែលបានដាក់ចេញ និងអនុម័តក្នុងឆ្នាំ ២០២០ នោះ។ តែដោយសារតែមានការតវ៉ា និងស្នើសុំពីសាធារណជន ទើបរដ្ឋាភិបាលសម្រេចមានការពន្យារក្នុងការអនុវត្តលើប្រកាសស្តីពីការប្រមូលពន្ធលើប្រាក់ចំណេញមូលធនរហូតដើមឆ្នាំ ២០២២ វិញ។

[12] អនុក្រឹត្យស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ, ១ មេសា ២០២០

# ជំពូកទី២

# និយ័តករមូលបត្រកម្ពុជា

# ជំពូកទី២

# និយ័តករមូលបត្រកម្ពុជា

និយ័តករមូលបត្រកម្ពុជា (ន.ម.ក.) ជាស្ថាប័នដែលមានមុខងារគ្រប់គ្រង ត្រួតពិនិត្យទីផ្សារមូលបត្រ គ្រប់គ្រងបណ្ដាប្រតិបត្តិករមូលបត្រ ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបោះផ្សាយមូលបត្រ និងសំដៅការពារអ្នកវិនិយោគមូលបត្រ ព្រមទាំងធានាឲ្យមានការជួញដូរមូលបត្រប្រកបដោយសណ្ដាប់ធ្នាប់ និងត្រឹមត្រូវនៅក្នុងវិស័យមូលបត្រនៃព្រះរាជាណាចក្រកម្ពុជា។ និយ័តករមូលបត្រកម្ពុជាត្រូវបានបង្កើតឡើងដោយច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០០៧។ ការរៀបចំ និងការប្រព្រឹត្តទៅនៃ ន.ម.ក. ត្រូវបានធ្វើឡើងដោយអនុលោមតាមអនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនិយ័តករមូលបត្រកម្ពុជា ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០០៨។[13]

## ២.១ ស្ថានភាពទូទៅរបស់និយ័តករមូលបត្រកម្ពុជា

ភាពចាំបាច់នានាដើម្បីជំនះទៅលើបញ្ហាផ្សេងៗដែលញាំញីកំណើនសេដ្ឋកិច្ចនៅកម្ពុជា បានរួមចំណែកជាកត្តាលីករដល់ការបង្កើតនិយ័តករមូលបត្រកម្ពុជា (SERC) ក្នុងការធ្វើនិយ័តកម្ម គ្រប់គ្រង និងអភិវឌ្ឍទីផ្សារមូលបត្រនៅកម្ពុជា និងលើកទឹកចិត្តឲ្យមានការទិញនូវឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទៀត។ និយ័តករនេះក៏មានតួនាទីការពារសិទ្ធិរបស់វិនិយោគិន និងធានានូវការចេញ និងការជួញដូរមូលបត្រប្រកបដោយភាពត្រឹមត្រូវ និងមានសណ្ដាប់ធ្នាប់ ខណៈពេលដែលប្រឹងប្រែងពង្រឹងបទបញ្ញត្តិ និងការអភិវឌ្ឍទីផ្សារមូលបត្រប្រកបដោយប្រសិទ្ធភាពបន្ថែមទៀត។ និយ័តករមូលបត្រអាចផ្ដល់អាជ្ញាបណ្ណដល់អ្នកចូលរួមផ្សេងទៀតនៅក្នុងទីផ្សារមូលបត្រនេះព្រមទាំងដើរតួនាទីជាស្ថាប័នដែលផ្ដល់នូវការត្រួតពិនិត្យ និងសម្រួលមូលប្បទានបត្រ។

លើសពីនេះ ន.ម.ក. តែងតែយកចិត្តទុកដាក់ខ្ពស់ទៅលើការលើកកម្ពស់ និងការជម្រុញការយល់ដឹងពាក់ព័ន្ធនឹងវិស័យមូលបត្រដែលជាចំណេះដឹងមូលដ្ឋានសម្រាប់សាធារណជនទូទៅ សិស្ស និស្សិត ធុរជនអ្នកសារព័ត៌មាន ក្រុមហ៊ុនឯកជនស្ថាប័នរដ្ឋ បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិដែលជាអ្នកប្រកបវិជ្ជាជីវៈក្នុងអាជីវកម្មមូលបត្រព្រមទាំងក្រុមហ៊ុនសក្ដានុពលផងដែរ។ ជាលទ្ធផលគិតត្រឹមឆ្នាំ ២០២០ នេះ ន.ម.ក. បានរៀបចំវគ្គបណ្ដុះបណ្ដាលសរុបចំនួន ១៤៣ លើក និងតាមរយៈអនឡាញ ១ លើកដោយមានអ្នកចូលរួម ១៤,៦៧១ រូប។

យោងតាមសេចក្ដីប្រកាសព័ត៌មានរបស់និយ័តករមូលបត្រកម្ពុជានៅល្ងាចថ្ងៃទី២ ខែមីនា ឆ្នាំ២០២១ បានឲ្យដឹងថា គណៈកម្មការមូលបត្រកម្ពុជាត្រូវបានប្រែក្លាយជានិយ័តករមូលបត្រកម្ពុជា អនុលោមតាមច្បាប់ស្ដី

[13] http://www.SERC.gov.kh/khmer/faq.php?pn=2 គេហទំព័ររបស់និយ័តករមូលបត្រកម្ពុជា (២០២០), សំនួរ-ចម្លើយ

ពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១។

ព្រមជាមួយនឹងសកម្មភាពក្នុងស្រុក ន.ម.ក. ក៏ដើរតួនាទីយ៉ាងសកម្មនៅលើឆាកអន្តរជាតិផងដែរ ដែលនៅក្នុងឆ្នាំ ២០២១ ន.ម.ក. នឹងធ្វើជាអនុប្រធាននៃវេទិកាទីផ្សារមូលធនអាស៊ាន (ASEAN Capital Markets Forum-ACMF) ដែលគណៈកម្មការមូលបត្រប្រ៊ុយណេជាប្រធាន។ វេទិកាទីផ្សារមូលធនអាស៊ាន គឺជាក្រុមការងារដែលប្រមូលផ្តុំដោយថ្នាក់ដឹកនាំជាន់ខ្ពស់នៃនិយ័តករមូលបត្រអាស៊ានដែលត្រូវបានបង្កើតឡើងក្រោមការគាំទ្រពីរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន ដែលមានការទទួលខុសត្រូវជាចម្បងក្នុងការអភិវឌ្ឍទីផ្សារមូលបត្រក្នុងតំបន់។ ទន្ទឹមនឹងនេះក្នុងឆ្នាំ ២០២១ ប្រទេសកម្ពុជាគ្រោងនឹងដាក់ឲ្យដំណើរការនូវផលិតផលមួយផ្សេងទៀតដែលហៅថា គម្រោងវិនិយោគរួម។ ការដាក់ឲ្យដំណើរការនូវផលិតផលនេះនឹងជួយជម្រុញនូវប្រសិទ្ធភាពទីផ្សារ និងមធ្យោបាយនៃការកៀរគរសាច់ប្រាក់ដែលនៅសេសសល់នៅក្នុងសេដ្ឋកិច្ចប្រកបដោយប្រសិទ្ធភាពខ្ពស់។[14]

## ២.២ ចក្ខុវិស័យ និងបេសកកម្មរបស់ ន.ម.ក.

### ២.២.១ ចក្ខុវិស័យ

និយ័តករមូលបត្រកម្ពុជាហៅកាត់ថា ន.ម.ក. ត្រូវបានបង្កើតឡើងក្រោយពីច្បាប់មូលបត្ររដ្ឋ និងច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជនបានអនុម័តរួច។ ន.ម.ក. មាន គោលដៅគ្រប់គ្រងវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គមតាមការកៀរគរមូលធនពីសាធារណជន ឬអ្នកវិនិយោគមូលបត្រ ដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុសម្រាប់ការវិនិយោគនៅកម្ពុជា។

### ២.២.២ បេសកកម្ម

- បង្កើត និងរក្សាឲ្យមានទំនុកចិត្តពីអ្នកវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការការពារសិទ្ធិស្របច្បាប់របស់អ្នកវិនិយោគ និងធានាឲ្យមានការបោះផ្សាយ និងការជួញដូរមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវ។
- លើកកម្ពស់ការគ្រប់គ្រងទីផ្សារមូលបត្រឲ្យមានប្រសិទ្ធភាព និងជម្រុញការអភិវឌ្ឍទីផ្សារនេះឲ្យមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយ។

[14] https://www.postkhmer.com/សេដ្ឋកិច្ច/ទិដ្ឋភាពសំខាន់នៃផ្សារមូលបត្រនៅកម្ពុជាត្រឹមឆ្នាំ-២០២០% គេហទំព័រ ភ្នំពេញ ប៉ុស្តិ៍ (២០២១), ទិដ្ឋភាពសំខាន់ៗនៃទីផ្សារមូលបត្រនៅកម្ពុជាត្រឹមឆ្នាំ ២០២០

- ជម្រុញឲ្យមានភាពសម្បូរបែបនៃឧបករណ៍សញ្ញ័យតាមរយៈការទិញមូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត។
- ជម្រុញឲ្យមានការធ្វើវិនិយោគទុនពីបរទេស និងការចូលរួមក្នុងទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- ជួយសម្រួលដល់ការធ្វើឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈនៅក្នុងប្រទេសកម្ពុជា។[15]

## ២.៣ គោលដៅ និងគោលបំណងទូទៅ

និយ័តករមូលបត្រកម្ពុជា (ន.ម.ក.) មានគោលដៅ និងគោលបំណងដូចខាងក្រោម៖

- គ្រប់គ្រង និងត្រួតពិនិត្យទីផ្សារមូលបត្រ រួមទាំងទីផ្សារមូលបត្ររដ្ឋនៃព្រះរាជាណាចក្រកម្ពុជា
- កំណត់លក្ខខណ្ឌ ដើម្បីផ្តល់ការអនុញ្ញាតជូនប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ។
- កំណត់លក្ខខណ្ឌដើម្បីផ្តល់អាជ្ញាបណ្ណជូនក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ
- លើកកម្ពស់ និងជម្រុញដល់ការគោរពតាមលក្ខខណ្ឌនៃច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនានា
- បង្កើត និងរក្សាទំនុកចិត្តអ្នកវិនិយោគដោយការពារសិទ្ធិរបស់អ្នកវិនិយោគ និងធានាឲ្យមានការបោះផ្សាយមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវ។
- ជម្រុញការអភិវឌ្ឍទីផ្សារមូលបត្រ
- ដោះស្រាយវិវាទនានា ដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ
- បង្ការ និងដាក់ទណ្ឌកម្មចំពោះបទល្មើសនានាដែលផ្តល់ផលប៉ះពាល់ដល់ទីផ្សារមូលបត្រ និងអ្នកវិនិយោគ។[16]

## ២.៤ ទីតាំង និង ពត៌មានសម្រាប់ទំនាក់ទំនង

- អាសយដ្ឋានៈ អគារ១៦៨F ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ ភ្នំពេញ រាជធានីភ្នំពេញ[17]
- ទូរស័ព្ទលេខៈ (៨៥៥) ២៣ ៨៨ ៥៦ ១១ / (៨៥៥) ១៦ ៨១៩ ៩៩១ (វិចិត្រ-admin) / (៨៥៥) ០១៧៧៦ ៧៨៥ (តី-webmaster)

[15] http://www.SERC.gov.kh/khmer/m11.php?pn=1 គេហទំព័ររបស់និយ័តករមូលបត្រកម្ពុជា (២០២០), ចក្ខុវិស័យ និងបេសកកម្ម

[16] http://www.SERC.gov.kh/khmer/faq.php?pn=2 គេហទំព័ររបស់និយ័តករមូលបត្រកម្ពុជា (២០២០), សំនួរ-ចម្លើយ

[17] http://www.SERC.gov.kh/khmer/m19.php?pn=1 គេហទំព័ររបស់និយ័តករមូលបត្រកម្ពុជា (២០២០), ទំនាក់ទំនងមក ន.ម.ក.

- ទូរសារៈ (៨៥៥) ២៣ ៨៨ ៥៦ ២២
- អ៊ីម៉ែលៈ INFO@SERC.GOV.KH

រូបភាពទី ២.១ ផែនទីរបស់ ន.ម.ក.




## ២.៥ រូបសញ្ញា និងអត្ថន័យនៃរូបសញ្ញារបស់ ន.ម.ក.

### ២.៥.១ រូបសញ្ញា

- រូបហង្សពណ៌មាស។
- រូបភាពស្លឹកឈើផ្នែកខាងឆ្វេងមានរំលេចស្រមោលពណ៌មាស ហើយខាងស្តាំរំលេចស្រមោលពណ៌ប្រផេះ។
- រូបរង្វង់ចាសដែលពាក់កណ្តាលមានពណ៌មាស និងពាក់កណ្តាលទៀតមានពណ៌ប្រផេះ។
- ព័ទ្ធជុំវិញជារង្វង់នៅផ្នែកខាងលើ ដោយអក្សរខ្មែរថា "និយ័តករមូលបត្រកម្ពុជា" និងព័ទ្ធរង្វង់នៅផ្នែកខាងក្រោមដោយអក្សរអង់គ្លេសថា "SECURITIES AND EXCHANGE COMMISSION OF CAMBODIA"។

រូបភាពទី ២.២ រូបសញ្ញារបស់ ន.ម.ក.

### ២.៥.២ អត្ថន័យនៃរូបសញ្ញា

- រូបហង្សមានពណ៌មាស តំណាងឲ្យអាជ្ញាធរហិរញ្ញវត្ថុដែលជាអ្នកត្រួតពិនិត្យ និងគ្រប់គ្រងប្រតិបត្តិការមូលបត្រ និងធានាឲ្យដំណើរការទីផ្សារមូលបត្រប្រកបដោយប្រសិទ្ធភាព មានសណ្តាប់ធ្នាប់ និងតម្លាភាព។
- រូបរង្វង់ថាសដែលពាក់កណ្តាលមានពណ៌មាស និងពាក់កណ្តាលទៀតមានពណ៌ប្រផេះ ដែលតំណាងឲ្យភាពចំណេញខាត ឬភាពឡើងចុះនៃដំណើរការទីផ្សារ។
- រូបហង្សពណ៌មាសឈរលើរង្វង់ថាសដែលមានជើងម្ខាងជាន់លើផ្ទៃពណ៌មាស និងជើងម្ខាងទៀតជាន់លើផ្ទៃ ពណ៌ប្រផេះ ចង់បង្ហាញថាភាពចំណេញខាត ឬភាពឡើងចុះនៃកិច្ចដំណើរការទីផ្សារស្ថិតនៅក្រោមការត្រួត ពិនិត្យ និងគ្រប់គ្រងរបស់អាជ្ញាធរជានិយ័តករមូលបត្រកម្ពុជាប្រកបដោយប្រសិទ្ធភាពមានសណ្តាប់ធ្នាប់ និងតម្លាភាព។
- រូបស្លឹកឈើ តំណាងឲ្យលទ្ធផលជាផ្លែផ្កានៃការចូលរួមចំណែករបស់វិស័យមូលបត្រក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-ជាតិ។

### ២.៥.៣ ត្រារបស់និយ័តករមូលបត្រកម្ពុជា

ត្រារបស់និយ័តករមូលបត្រកម្ពុជា មានលក្ខណៈប្រហាក់ប្រហែលនឹងត្រាមូលរបស់អាជ្ញាធរ ឬស្ថាប័នរដ្ឋដទៃទៀតដែរ ដោយនៅកន្លែងរង្វង់មូលផ្នែកខាងលើមានអក្សរសរសេរថា «ព្រះរាជាណាចក្រកម្ពុជា» ផ្នែកកណ្តាលមានសញ្ញា ប្រាសាទអង្គរវត្ត និងផ្នែកខាងក្រោមមានអក្សរសរសេរថា «និយ័តករមូលបត្រកម្ពុជា»។[18]

រូបភាពទី ២.៣ ត្រារបស់ ន.ម.ក.



[18] http://www.SERC.gov.kh/khmer/m17.php?pn=1 គេហទំព័ររបស់និយ័តករមូលបត្រកម្ពុជា (២០២០), រូបសញ្ញារបស់ គ.ម.ក

## ២.៦ ប្រធាន និងសមាជិក ន.ម.ក.

និយ័តករមូលបត្រកម្ពុជាមានប្រធានមួយរូប និងសមាជិកចំនួន ៨ រូប ដែលមានអាណត្តិរយៈពេល ០៥ ឆ្នាំ។ ប្រធាននៃ ន.ម.ក. គឺ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន និងជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

សមាជិកចំនួន ០៨ រូបរួមមានៈ

- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១រូប
- តំណាងធនាគារជាតិកម្ពុជា ០១រូប
- តំណាងក្រសួងពាណិជ្ជកម្ម ០១រូប
- តំណាងក្រសួងយុត្តិធម៌ ០១រូប
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ០១រូប
- អគ្គនាយកនៃ ន.ម.ក. ០១រូប
- អ្នកជំនាញដែលមានបទពិសោធន៍វិស័យមូលបត្រ ០២រូប។

## ២.៧ អង្គភាពចាត់តាំង

រូបភាពទី ២.៤ អង្គការចាត់តាំងរបស់ ន.ម.ក.




ន.ម.ក. ដឹកនាំដោយអគ្គនាយក០១រូប ដែលមានឋានៈ និងបុព្វសិទ្ធិស្មើនឹងរដ្ឋលេខាធិការ និងមានអគ្គនាយករងមួយចំនួនជាជំនួយការ។

ន.ម.ក. មាននាយកដ្ឋានចំណុះចំនួន០៦ដូចខាងក្រោមៈ

១. នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

២. នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ

៣. នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ

៤. នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ

៥. នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ

៦. នាយកដ្ឋានកិច្ចការគតិយុត្ត ន.ម.ក. មានអង្គភាពសវនកម្មផ្ទៃក្នុង ដែលស្ថិតនៅក្រោមការដឹកនាំ និងគ្រប់គ្រងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ ន.ម.ក.។[19]

[19] http://www.SERC.gov.kh/khmer/faq.php?pn=2 គេហទំព័ររបស់និយ័តករមូលបត្រកម្ពុជា (២០២០), សំនួរ-ចម្លើយ

# ជំពូកទី៣
# ទីផ្សារមូលបត្រកម្ពុជា

# ជំពូកទី៣

# ទីផ្សារមូលបត្រកម្ពុជា

## ៣.១ ប្រវត្តិផ្សារមូលបត្រកម្ពុជា

ដើម្បីសម្រេចបាននូវការអភិវឌ្ឍប្រទេសកម្ពុជាដោយឈរលើគោលដៅក្នុង ការជម្រុញកំណើនសេដ្ឋកិច្ចតាមរយៈលំហូរមូលធន ការវិនិយោគ និងការវិភាជន៍ជាថ្មីនូវមូលធនតាមរយៈយន្តការទីផ្សារមូលធន នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ស្តីពី «ការអភិវឌ្ឍផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា»។ នៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ ២០០៧ ដោយផ្អែកលើអនុស្សរណៈយោគយល់នេះ សម្តេចអគ្គសេនាបតីតេជោហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសបើកឲ្យដំណើរការគម្រោងបង្កើតទីផ្សារមូលបត្រនៅប្រទេសកម្ពុជា។ នៅថ្ងៃទី២១ ខែមករា ឆ្នាំ ២០០៨ អនុស្សរណៈយោគយល់មួយទៀតស្តីអំពី «ការបង្កើតផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា» ត្រូវបានចុះហត្ថលេខាដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។ នៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០៩ រាជរដ្ឋាភិបាលកម្ពុជាដែលតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ បានចុះកិច្ចព្រមព្រៀង ក្រុមហ៊ុនចម្រុះ (Joint Venture) ដើម្បីបង្កើតផ្សារមូលបត្រស្របតាមច្បាប់ស្តីអំពីសហគ្រាសសាធារណៈ។ នៅថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០១០ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានចុះក្នុងបញ្ជីពាណិជ្ជកម្ម។ ស្របតាមកិច្ចព្រមព្រៀង ក្រុមហ៊ុនចម្រុះ (Joint Venture) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកាន់កាប់ភាគហ៊ុនចំនួន ៥៥% នៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ហើយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េកាន់កាប់ភាគហ៊ុនចំនួន ៤៥% នៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១១ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានទទួលអាជ្ញាបណ្ណជា ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ ព្រមទាំងប្រតិបត្តិកររក្សាទុកមូលបត្រ ពីនិយ័តករមូលបត្រកម្ពុជា (ន.ម.ក.) ស្របតាមច្បាប់ស្តីអំពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។[20] ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាត្រូវបានបង្កើតឡើងដើម្បីរៀបចំ និងដាក់ឲ្យដំណើរការជាទីផ្សារមូលបត្រដំបូងបង្អស់នៅកម្ពុជា កាលពីថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១១ ក្រោមអធិបតីភាពរបស់ ឧបនាយករដ្ឋមន្ត្រី គាត ឈន់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[21]

[20] ច្បាប់ពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, ១២ កញ្ញា ២០០៧

[21] http://csx.com.kh/kh/about/profile.jsp?MNCD=10301 គេហទំព័ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (២០២១), ប្រវត្តិ ផ.ម.ក.

## ៣.២ ទិដ្ឋភាពទូទៅនៃទីផ្សារមូលបត្រនៅកម្ពុជា

ដោយទទួលស្គាល់ពីស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្នមានលក្ខណៈល្អប្រសើរ ប្រទេសកម្ពុជាបានបន្តការពង្រីកសេដ្ឋកិច្ចរបស់ខ្លួនប្រកបដោយចីរភាព និងការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុព្រមទាំងវិស័យឯកជន។ អ្វីដែលកាន់តែពិសេសនោះ រដ្ឋាភិបាលកម្ពុជាបានអនុវត្តនូវយុទ្ធសាស្ត្រជាច្រើនដើម្បីរៀបចំការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុដោយផ្អែកលើចក្ខុវិស័យ និងផែនការអភិវឌ្ឍហិរញ្ញវត្ថុឆ្នាំ (២០០១-២០១០)។ [22] និយ័តករមូលបត្រកម្ពុជា (SERC) ត្រូវបានបង្កើតឡើងដោយដើរតួនាទីជាស្ថាប័នដែលផ្តល់នូវការត្រួតពិនិត្យ និងសម្រួលមូលប្បទានបត្រ ដើម្បីធ្វើនិយ័តកម្ម គ្រប់គ្រង និងអភិវឌ្ឍទីផ្សារមូលបត្រនៅកម្ពុជា ព្រមទាំងលើកទឹកចិត្តឲ្យមានការទិញនូវឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទៀត។

ក្នុងឆ្នាំ ២០១១ ផ្សារមូលបត្រកម្ពុជា (CSX) ត្រូវបានបង្កើតឡើងជាផ្សារភាគហ៊ុនជាតិរបស់ប្រទេស ដើម្បីជាមធ្យោបាយក្នុងការកៀរគរមូលធនព្រមទាំងបែងចែកទុនសម្រាប់ការផ្តល់ហិរញ្ញប្បទានដល់ការវិនិយោគគ្រប់ប្រភេទ និងជម្រុញកំណើនសេដ្ឋកិច្ចជាតិស្របតាមចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលកម្ពុជា។ ផ្សារមូលបត្រកម្ពុជាផ្តោតលើការលើកកម្ពស់កំណើនសេដ្ឋកិច្ច តាមរយៈការសម្របសម្រួលការវិនិយោគ ការពង្រីកវិស័យឯកជន និងលំហូរមូលធន។ រដ្ឋាភិបាលកម្ពុជាបានផ្តល់ការគាំទ្រចាំបាច់មួយចំនួនដល់ផ្សារមូលបត្រកម្ពុជា ដើម្បីបង្កើតបរិយាកាសធុរកិច្ចមួយដែលងាយស្រួលសម្រាប់វិនិយោគិន និងការធ្វើឲ្យក្លាយទៅជាបណ្តាញហិរញ្ញប្បទានដ៏សំខាន់មួយនៅក្នុងប្រទេស។ ទាំងនិយ័តករមូលបត្រ (SERC) និងផ្សារមូលបត្រកម្ពុជា (CSX) សុទ្ធតែមានតួនាទីសំខាន់ក្នុងការធានានូវប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពទៅលើទីផ្សារ និងបទប្បញ្ញត្តិផ្សារមូលបត្រនៅកម្ពុជា។

ចាប់តាំងពីការបង្កើតឲ្យមានទីផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជារយៈពេលជាង ១០ ឆ្នាំមកនេះ យើងសង្កេតឃើញថា ទីផ្សារមូលបត្រហាក់កំពុងបោះជំហានទៅមុខគួរឲ្យកត់សម្គាល់។ អ្នកជំនាញក្នុងវិស័យមូលបត្រកម្ពុជាបានអះអាងថាវិស័យមូលបត្រកម្ពុជា គឺមានការថមថយចុះបន្តិចអំឡុងពេលនៃវិបត្តិមេរោគកូវីដ ១៩ ក្នុងឆ្នាំ ២០២០ តែយ៉ាងណាវិស័យមួយនេះនៅតែធ្វើបានល្អនៅក្នុងត្រីមាសទី ៤ ចុងឆ្នាំ ២០២០ ដោយទំហំនៃការជួញដូរមានការកើនឡើង ៧%។[23] បច្ចុប្បន្នទីផ្សារមូលបត្រកម្ពុជាមានក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ

---

[22] https://opendevelopmentcambodia.net/km/topics/securities-exchange-stock-market/ គេហទំព័រ អង្គការទិន្នន័យអំពីការអភិវឌ្ឍ (២០២១), ផ្សារមូលបត្រ (ផ្សារភាគហ៊ុន)

[23] http://news.pnn.com.kh/news/5505 គេហទំព័រ ពត៌មាន PNN (២០២១), ការជួញដូរភាគហ៊ុននៅក្នុងវិស័យមូលបត្រកម្ពុជា

កម្មសិទ្ធិ (Stock) ប្រមូលទុនបានប្រហែល ១០១ លានដុល្លារអាមេរិក និងក្រុមហ៊ុនបោះផ្សាយលក់មូលបត្របំណុល (Bond) ដែលប្រមូលសាច់ប្រាក់បានជាង ១៤៣ លានដុល្លារអាមេរិក។[24]

បើទោះបីជាវិបត្តិមេរោគកូវីដ១៩ បានធ្វើឲ្យទំនោរសេដ្ឋកិច្ចសកលមានការថមថយចុះបន្តិច កាលពីឆ្នាំ ២០២០ សម្រាប់ឆ្នាំថ្មី ២០២១ នេះ នៅពេលដែលស្ថានការណ៍កូវីដ១៩ អាចត្រូវបានគ្រប់គ្រងគួបផ្សំជាមួយការប្រើប្រាស់វ៉ាក់សាំងដែលមានប្រសិទ្ធភាព ទើបធ្វើឲ្យទីផ្សារមូលបត្រកម្ពុជាចាប់ផ្តើមលូតលាស់ជាបន្តទៀត។ ជាក់ស្តែង វិស័យមូលបត្រកម្ពុជាត្រូវបានរំពឹងថានឹងមានភាពល្អប្រសើរឡើងវិញ ដោយមានក្រុមហ៊ុនចុះបញ្ជីថ្មីៗបន្ថែមដែលបច្ចុប្បន្នកំពុងតែដំណើរការតាមនីតិវិធី និងការចូលរួមកាន់តែច្រើនពីសំណាក់វិនិយោគិនសាធារណៈនឹងធ្វើឲ្យសកម្មភាពទីផ្សារកាន់តែកើនឡើង និងសកម្មជាងមុន។ អ្វីដែលគួរឲ្យចាប់អារម្មណ៍ជាងនេះទៅទៀតគឺច្បាប់ស្តីពីមូលបត្ររដ្ឋ ដែលប្រកាសដាក់ឲ្យប្រើប្រាស់កាលពីចុងខែធ្នូ ឆ្នាំ ២០២០ ដែលអ្នកជំនាញចាត់ទុកថា វាជាការបើកផ្លូវថ្មីមួយទៀតសម្រាប់វិស័យហិរញ្ញវត្ថុនៅកម្ពុជា ដែលរាជរដ្ឋាភិបាលកម្ពុជាអាចកៀរគរប្រភពទុនពីសាធារណជន និងវិនិយោគិនជាស្ថាប័ន ដែលសល់សាច់ប្រាក់ទំនេរអាចយកមកប្រើប្រាស់បាន។[25] នៅក្នុងឆ្នាំ ២០២១ វិស័យមូលបត្រកម្ពុជានឹងមានទីផ្សារថ្មីៗ និងឧបករណ៍ហិរញ្ញវត្ថុជាច្រើនប្រភេទទៀតសម្រាប់វិនិយោគិន ក៏ដូចជាក្រុមហ៊ុនបោះផ្សាយមានជម្រើសកាន់តែច្រើនក្នុងការជួញដូរ។

## ៣.៣ នាមករណ៍ និងផ្លាកសញ្ញារបស់ ផ.ម.ក.

### ក. នាមករណ៍

ក្រុមហ៊ុនមានឈ្មោះជាភាសាខ្មែរថា «ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា» ដែលមានអក្សរកាត់ថា (ផ.ម.ក.) និងជាភាសាអង់គ្លេសថា «Cambodia Securities Exchange» ដែលមានអក្សរកាត់ថា (CSX)។

### ខ. ផ្លាកសញ្ញា

ផ្លាកសញ្ញារបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាមាន៖

- ផ្នែកខាងលើមានអក្សរពណ៌ខៀវសរសេរថា ផ្សារមូលបត្រកម្ពុជា ដែលជាឈ្មោះរបស់ក្រុមហ៊ុន។
- ផ្នែកខាងស្តាំមានរូបហង្សពណ៌មាស ឈរបែរមុខទៅខាងស្តាំ។
- នៅពីក្រោមអក្សរផ្នែកខាងឆ្វេងមានឈ្មោះរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដែលគេសរសេរជាភាសាអង់គ្លេស។

[24] https://www.postkhmer.com/ គេហទំព័រ ភ្នំពេញប៉ុស្តិ៍ (២០២១), ទិដ្ឋភាពសំខាន់ៗនៃទីផ្សារមូលបត្រនៅកម្ពុជាត្រឹមឆ្នាំ ២០២០

[25] ច្បាប់ស្តីពីមូលបត្ររដ្ឋ, ២៥ វិច្ឆិកា ២០២០

រូបភាពទី ៣.១ រូបសញ្ញារបស់ ផ.ម.ក.

## ៣.៤ ចក្ខុវិស័យ និងបេសកកម្មរបស់ ផ.ម.ក.

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាមានចក្ខុវិស័យ និងបេសកកម្មដូចជា៖[26]

**ចក្ខុវិស័យ**

ចក្ខុវិស័យរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាគឺ ដើម្បីកសាងនូវ «មហាវិថី» ហិរញ្ញវត្ថុសម្រាប់កម្ពុជា។

**បេសកកម្ម**

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា បានដាក់ចេញនូវបេសកកម្មដូចជា ៖

- ជួយសម្រួលក្នុងការកៀរគរមូលធនរបស់ក្រុមហ៊ុននៅកម្ពុជា
- បង្កើននូវបរិយាកាសជួញដូរមូលបត្រដែលអំណោយផលដល់អ្នកវិនិយោគិនទាំងក្នុង និងក្រៅប្រទេស
- បង្កើននូវផលិតផល និងសេវាកម្មដ៏ទំនើបជាច្រើនប្រភេទសម្រាប់អ្នកចូលរួមក្នុងទីផ្សារទាំងអស់
- ដាក់ឲ្យដំណើរការនូវសហគ្រាសសាធារណៈមួយដែលមានស្វ័យចិរភាពក្រោមមគ្គទេសដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។

## ៣.៥ រចនាសម្ព័ន្ធគ្រប់គ្រង និងក្រុមប្រឹក្សាភិបាល

រូបភាពទី ៣.២ រចនាសម្ព័ន្ធគ្រប់គ្រង់របស់ ផ.ម.ក.




[26] http://csx.com.kh/kh/about/mission.jsp?MNCD=1020 គេហទំព័ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (២០២១), ចក្ខុវិស័យ និងបេសកកម្ម

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាមាននាយកដ្ឋានចំណុះចំនួន០៦គឺ ៖

- នាយកដ្ឋានប្រតិបត្តិការទីផ្សារមូលបត្រ
- នាយកដ្ឋានពត៌មានវិទ្យា
- នាយកដ្ឋានផាត់ទាត់ និងទូទាត់មូលបត្រ
- នាយកដ្ឋានរក្សាទុកមូលបត្រ
- នាយកដ្ឋានចុះបញ្ជី និងការផ្តល់ពត៌មាន
- នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ។

## ក្រុមប្រឹក្សាភិបាល

- ក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាមានសមាជិកចំនួន ៧ រូប ដោយរាប់បញ្ចូលទាំងប្រធានក្រុមប្រឹក្សាភិបាល អនុប្រធានក្រុមប្រឹក្សាភិបាល (ដែលជាអគ្គនាយករងផងដែរ) និងអគ្គនាយក។ ប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយកជាតំណាងរបស់រាជរដ្ឋាភិបាលកម្ពុជា។ ចំណែកឯអនុប្រធានក្រុមប្រឹក្សាភិបាល គឺជាតំណាងរបស់ក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។
- សមាជិកចំនួន ៤រូប ផ្សេងទៀតគឺជាអភិបាលមិនអចិន្ត្រៃយ៍ ដោយក្នុងនោះ ២រូបត្រូវបានតែងតាំងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង២រូបទៀតត្រូវបានតែងតាំងដោយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។ [27]

រូបភាពទី ៣.៣ ក្រុមប្រឹក្សាភិបាលនៃ ផ.ម.ក.




## ៣.៦ ពត៌មានសម្រាប់ទំនាក់ទំនង

- អាសយដ្ឋាន[28]: អគារ ផ.ម.ក. វិថិព្រះមហាក្សត្រយានី កុសុមៈ (ផ្លូវ ១០៦) សង្កាត់ វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

---

[27] http://csx.com.kh/kh/about/director.jsp?MNCD=10303 គេហទំព័រក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (២០២១), ក្រុមប្រឹក្សាភិបាល

[28] http://csx.com.kh/kh/about/contact.jsp?MNCD=10703 គេហទំព័ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (២០២១), ពត៌មានសម្រាប់ទំនាក់ទំនង

- ទូរស័ព្ទ: (៨៥៥) ២៣ ៩៥៨ ៨៨៨
- ទូរសារ: (៨៥៥) ២៣ ៩៥៥ ៥៥៨
- ក្រសួង និងស្ថាប័នពាក់ព័ន្ធ: info@csx.com.kh
- គេហទំព័រ : www.csx.com.kh

## ៣.៧ តួអង្គចូលរួមក្នុងទីផ្សារមូលបត្រកម្ពុជា

### ៣.៧.១ តួអង្គលើទីផ្សារដំបូង

| | |
|---|---|
| និយ័តករមូលបត្រកម្ពុជា | គ្រប់គ្រងវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងចូលរួមចំណែក ដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គម។ |
| ក្រុមហ៊ុនធានាទិញមូលបត្រ | • កាណាស៊ីឃ្យូរីធី (CANA Securities LTD)<br>• ភ្នំពេញស៊ីឃ្យូរីធី (Phnom Penh Securities PLC)<br>• អេស ប៊ី អាយ រ៉ូយយ៉ាល់ស៊ីឃ្យូរីធី (SBI Royal Securities)<br>• កម្ពុ ស៊ីឃ្យូរីធី (CAMPU Securities)<br>• អ អេច ប៊ី ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី (RHB Securities(Cambodia) Plc)<br>• យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី (Yuanta Securities (Cambodia) Plc) |
| ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ | • រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ<br>• ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី<br>• កំពង់ផែស្វយ័តភ្នំពេញ<br>• តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ<br>• កំពង់ផែស្វយ័តក្រុងព្រះសីហនុ<br>• ធនាគារ អេស៊ីលីដា ភីអិលស៊ី<br>• ផេសថិក (ខេមបូឌា) ម.ក |
| វិនិយោគិន | សាធារណជនទូទៅ រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបានទិញមូលបត្រ។ |

### ៣.៧.២ តួអង្គលើទីផ្សារបន្ទាប់

| | |
|---|---|
| ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា | ទទួលបានការអនុញ្ញាតពី ន.ម.ក. ធ្វើជា ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិកររក្សាទុកមូលបត្រ និងជាប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ ក្នុងឆ្នាំ២០១១។ |
| ក្រុមហ៊ុនមូលបត្រ | អ្នកជួយសម្របសម្រួលក្នុងការទិញ លក់មូលបត្រ។ ក្រុមហ៊ុននេះផ្តល់សេវាកម្មជាឈ្មួញជើងសារ ដែលមានមុខងារជួយវិនិយោគិនដាក់បញ្ជាទិញ ឬលក់មូលបត្រមកកាន់ ផ.ម.ក.។ |
| អន្តរការីទីផ្សារ | • ក្រុមហ៊ុនធានាទិញមូលបត្រ<br>• ក្រុមហ៊ុនពាណិជ្ជករមូលបត្រ<br>• ក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ<br>• ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ |
| តួអង្គចូលរួមដទៃទៀត | • ក្រុមហ៊ុនផ្តល់សេវាសវនកម្ម<br>• ក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់<br>• ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ<br>• ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ (cash settlement agent CSA)<br>• ភ្នាក់ងារ RTP ។ |

# ជំពូកទី ៤

# នីតិវិធីនៃការជួញដូរ
# មូលបត្រកម្មសិទ្ធិ

# ជំពូកទី ៤

# នីតិវិធីនៃការជួញដូរមូលបត្រកម្មសិទ្ធិ

## ៤.១ លក្ខខណ្ឌតម្រូវរបស់វិនិយោគិនមុនធ្វើការជួញដូរ

មុននឹងចាប់ផ្ដើមការជួញដូរ វិនិយោគិនទាំងអស់ត្រូវអនុវត្តជំហានងាយៗដូចខាងក្រោម៖

- ជ្រើសរើសក្រុមហ៊ុនមូលបត្រមួយ
- បើកគណនីសាច់ប្រាក់
- ស្នើសុំលេខអត្តសញ្ញាណវិនិយោគិន
- បើកគណនីជួញដូរ។

រូបភាពទី ៤.១ លក្ខខណ្ឌតម្រូវរបស់វិនិយោគិនមុនធ្វើការជួញដូរ




### ៤.១.១ ការជ្រើសរើសក្រុមហ៊ុនមូលបត្រ

វិនិយោគិនត្រូវជ្រើសរើសក្រុមហ៊ុនមូលបត្រមួយ ក្នុងចំណោមក្រុមហ៊ុនមូលបត្រទាំង ១២ ដែលជាសមាជិករបស់ ផ.ម.ក. ដើម្បីធ្វើជាអ្នកតំណាងរបស់ខ្លួនក្នុងការជួញដូរមូលបត្រ ដែលក្រុមហ៊ុនមូលបត្រទាំងនោះមាន៖[29]

❖ **ក្រុមហ៊ុនធានាទិញមូលបត្រ (Securities Underwriters)**

– កាណា ស៊ីឃ្យូរីធី អិលធីឌី (CANA Securities LTD)

– ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី (Phnom Penh Securities Plc.)

[29] https://www.secc.gov.kh/khmer/m52.php?pn=6 គេហទំព័ររបស់និយ័តករមូលបត្រកម្ពុជា (២០២០),អន្តរកាលទីផ្សារ

– អេស ប៊ី អាយ រ៉ូលយ៉ាល់ ស៊ីឃ្យូរីធី (SBI Royal Securities Plc.)

– កម្ពុ ស៊ីឃ្យូរីធី ភីអិលស៊ី (CAMPU Securities Plc.)

– អ អេច ប៊ី ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី (RHB Securities(Cambodia) Plc.)

– យាន់តា ស៊ីឃ្យូរីធី(ខេមបូឌា) ភីអិលស៊ី (Yuanta Securities (Cambodia) Plc)

– ខេមបូឌា ស៊ីឃ្យូរីធី ម.ក (Cambodia Securities Plc.)

❖ **ក្រុមហ៊ុនពាណិជ្ជករមូលបត្រ (Securities Dealers)**

– ហ្គោលដេន ហ្វ័រឈូន (ខេមបូឌា) ស៊ីឃ្យូរីធី ភីអិលស៊ី (Golden Fortune (Cambodia) Securities Plc.)

❖ **ក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ (Securities Brokers)**

– អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី (ACLEDA Securities Plc.)

– ខេប ស៊ីឃ្យូរីធី លីមីធីត (CAB Securities Limited)

– ខេមបូឌា-វៀតណាម ស៊ីឃ្យូរីធី ឯ.ក (Cambodia-Vietnam Securities Co.,Ltd.)

– ភីភី លីង ស៊ីឃ្យូរីធី ឯ.ក (PP Link Securities Co.,Ltd.)

### ៤.១.២ ការបើកគណនីសាច់ប្រាក់

មុននឹងអាចធ្វើការជួញដូរបាន វិនិយោគិនគឺតម្រូវឲ្យបើកគណនីសាច់ប្រាក់មួយជាមួយភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ហើយភ្នាក់ងារទាំងនោះមាន៖

- ធនាគារ អេស៊ីលីដា ភីអិលស៊ី (Acleda Bank Plc.)
- ធនាគារ កាណាឌីយ៉ា ក.អ (Canadia Bank Plc.)
- ធនាគារ វិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី (Bank for Investment and Development of Cambodia Plc.)
- ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី (Cambodia Public Bank Plc.)
- ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក (B.I.C (Cambodia) Bank Plc.)
- ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ (Advanced Bank of Asia Limited)

### ៤.១.៣ ការស្នើសុំបើកលេខអត្តសញ្ញាណវិនិយោគិន

វិនិយោគិនអាចធ្វើការស្នើសុំលេខអត្តសញ្ញាណវិនិយោគិននៅ ន.ម.ក. ដោយផ្ទាល់ ឬតាមរយៈក្រុមហ៊ុនមូលបត្រ។ បច្ចុប្បន្នការបើកលេខអត្តសញ្ញាណវិនិយោគិន គឺធ្វើតាមរយៈអនឡាញដោយវិនិយោគិនគ្រាន់តែចូលទៅកាន់ Link: https://id.secc.gov.kh ឬតាមគេហទំព័រ ន.ម.ក. រួចជ្រើសរើសពាក្យ «វិនិយោគិន» ➡

«លេខអត្តសញ្ញាណវិនិយោគិន» ចូលទៅកាន់ Link «ការស្នើសុំលេខអត្តសញ្ញាណវិនិយោគិនតាមអនឡាញ»។ កាលពីមុន វិនិយោគិនអាចបើកដោយផ្ទាល់ដោយគាត់មក ន.ម.ក. ដើម្បីបំពេញពាក្យស្នើសុំហើយ ន.ម.ក. ត្រូវការពេល ២ ថ្ងៃ ដើម្បីធ្វើការយល់ព្រម។ ពេលបានលេខអត្តសញ្ញាណវិនិយោគិនហើយ វិនិយោគិនត្រូវយកទៅក្រុមហ៊ុនមូលបត្រដើម្បីបើកគណនីជួញដូរមូលបត្រមួយទៀតទើបអាចជួញដូរបាន។ ម្យ៉ាងទៀត វិនិយោគិនអាចទៅជួបក្រុមហ៊ុនមូលបត្រតែម្តងក៏បាន ដោយក្រុមហ៊ុនមូលបត្របានឲ្យទម្រង់ពាក្យស្នើសុំបើកលេខអត្តសញ្ញាណវិនិយោគិនមកវិនិយោគិនដើម្បីបំពេញ ដោយមានឯកសារភ្ជាប់មកជាមួយ ហើយបង់ថ្លៃសេវាចំនួន ២០,០០០រៀលចំពោះរូបវន្តបុគ្គល និង ៥០,០០០រៀលចំពោះនីតិបុគ្គល។ បន្ទាប់មកក្រុមហ៊ុនមូលបត្រជួយដំណើរការឲ្យដោយយកទម្រង់នោះទៅដាក់នៅ ន.ម.ក ហើយយកទៅបើកគណនីជួញដូរមូលបត្រ។ លេខអត្តសញ្ញាណវិនិយោគិនមានសុពលភាព ១០ ឆ្នាំ ហើយអាចស្នើសុំបន្តសុពលភាពមុនអស់សុពលភាព ៣ខែ ។ វិនិយោគិនម្នាក់ អាចមានលេខអត្តសញ្ញាណវិនិយោគិនតែមួយគត់។ លក្ខខណ្ឌសម្រាប់ការស្នើសុំលេខអត្តសញ្ញាណវិនិយោគិនមានដូចជា៖

- ចំពោះរូបវន្តបុគ្គល
  - រូបថត ៤x៦
  - អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន
- ចំពោះនីតិបុគ្គល
  - រូបថត ៤x៦ របស់បុគ្គលតំណាង
  - វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម និងអាជ្ញាបណ្ណធ្វើអាជីវកម្ម
  - វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ
  - លក្ខន្តិកៈក្រុមហ៊ុន
  - អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់បុគ្គលតំណាង
  - លិខិតផ្ទេរសិទ្ធិដល់បុគ្គលតំណាង
  - ត្រាសម្គាល់នីតិបុគ្គល។

### ៤.១.៤ ការបើកគណនីជួញដូរ

នៅពេលជ្រើសរើសក្រុមហ៊ុនមូលបត្ររួចហើយ វិនិយោគិនត្រូវបើកគណនីជួញដូរមូលបត្រមួយនៅក្រុមហ៊ុនមូលបត្រនោះ។ ក្រុមហ៊ុនមូលបត្រនោះនឹងបន្តបើកឲ្យវិនិយោគិននូវគណនីសាច់ប្រាក់មួយ នៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ និងគណនីមូលបត្រមួយទៀតនៅប្រតិបត្តិកររក្សាទុកមូលបត្ររបស់ផ្សារ

មូលបត្រកម្ពុជា (ផ.ម.ក.)។ នៅពេលជ្រើសរើសក្រុមហ៊ុនមូលបត្រដែលខ្លួនពេញចិត្តបានហើយ វិនិយោគិនត្រូវទៅក្រុមហ៊ុនមូលបត្រនោះដោយតម្រូវឲ្យមានឯកសារមួយចំនួនរួមមាន ៖

១. អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ភ្ជាប់ជាមួយរូបថត ៤×៦ មួយសន្លឹក

២. លេខអត្តសញ្ញាណវិនិយោគិន (ក្រុមហ៊ុនមូលបត្រអាចជួយធ្វើការស្នើសុំពី ន.ម.ក.)

សុពលភាពនៃការប្រើប្រាស់គណនីជួញដូរមូលបត្រនេះ អាស្រ័យទៅនឹងសុពលភាពលេខអត្តសញ្ញាណវិនិយោគិន។

## ៤.២ ដំណើរការប្រតិបត្តិការទីផ្សារ

### ៤.២.១ ពេលវេលានៃការជួញដូរ

ផ្សារមូលបត្រកម្ពុជា បានអនុញ្ញាតឲ្យមានការជួញដូរមូលបត្រកម្មសិទ្ធិដូចខាងក្រោម៖

- ការជួញដូរធ្វើឡើងពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ លើកលែងថ្ងៃឈប់សម្រាកជាសារធារណៈ
- ការជួញដូរចាប់ផ្តើមពីម៉ោង ៨:០០ ព្រឹក រហូតដល់ម៉ោង ៣:០០ រសៀល ដែលបែងចែកទៅតាមវគ្គដូចខាងក្រោម ៖
  - ម៉ោងជួញដូរពីម៉ោង ៨:០០-៩:០០ព្រឹក ដោយប្រើប្រាស់វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ ដែលការផ្គូផ្គងនឹងប្រព្រឹត្តទៅនៅម៉ោង ៩:០០ព្រឹក (វគ្គបើក)
  - ម៉ោងជួញដូរពីម៉ោង ៩:០០ព្រឹក ដល់ ២:៥០ រសៀល ដោយប្រើប្រាស់វិធីសាស្ត្រដេញថ្លៃ ដោយយកថ្លៃច្រើន ដែលការផ្គូផ្គងត្រូវធ្វើឡើងភ្លាមៗនៅពេលបញ្ជាជួញដូរត្រូវគ្នា (វគ្គនិរន្តរ៍)
  - ម៉ោងជួញដូរពីម៉ោង ២:៥០-៣:០០រសៀល ដោយប្រើប្រាស់វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ ដែលការផ្គូផ្គងនឹងប្រព្រឹត្តទៅនៅម៉ោង ៣:០០រសៀល (វគ្គបិទ)

រូបភាពទី ៤.២ ម៉ោងជួញដូរ



ចំណាំ៖ ប្រសិនបើគ្មានការផ្គូផ្គងបញ្ជានៅម៉ោង ៩:00 នាទីព្រឹកទេ នោះវគ្គបើកនឹងត្រូវពន្យាររហូតដល់មានការផ្គូផ្គងនៅក្នុងថ្ងៃដដែល។

### ៤.២.២ ឯកតាបញ្ជា និងឯកតាគម្លាត

- ឯកតាបញ្ជានៃមូលបត្រកម្មសិទ្ធិគឺ ០១ ឯកតាមូលបត្រ។
- ឯកតាគម្លាតថ្លៃនៃមូលបត្រនីមួយៗបានកំណត់ដូចខាងក្រោម ៖[30]

តារាងទី ៤.១ ឯកតាគម្លាតថ្លៃ

| ថ្លៃ | ឯកតាគម្លាតថ្លៃ | ឧទាហរណ៍ថ្លៃបញ្ជាត្រូវ | ឧទាហរណ៍ថ្លៃបញ្ជាខុស |
|---|---|---|---|
| P<៤,000 | ១0 | ២,0៦0 ; ៣,៦៥0 | ២,0៧៥ ; ៣,៦៩៤ |
| ៤,000 ≤P<២0,000 | ២0 | ១៧,២២0 ; ១៩,៥00 | ១0,៥៥៥ ; ១៦,៨៧៩ |
| ២0,000≤P<៤0,000 | ៥0 | ៣0,0៥0 ; ៣៥,៤00 | ៣0,៤៤៧ ; ៣៦,៩៨៧ |
| ៤0,000≤P<១00,000 | ១00 | ៦៨,៩00 ; ៨0,៧00 | ៥0,១៥0 ; ៧0,២៩0 |
| ១00,000≤P<២0,000 | ២00 | ១២0,៤00 ; ១៨៦,៨00 | ១១0,៥00 ; ១៥៥,៧00 |
| ២00,000≤P<៤00,000 | ៥00 | ៣00,៥00 ; ៣៥0,000 | ៣00,៤៨៩ ; ៣៣៥,៦៥0 |
| P≥៤00,000 | ១,000 | ៤0១,000 ; ៥0៥,000 | ៤0៥,៥00 ; ៦៥0,៤៥៦ |

* ទឹកប្រាក់ទាំងអស់គិតជារៀល

[30] http://csx.com.kh/operation/stock/listPosts.do?MNCD=30202 គេហទំព័ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (២០២១), ការជួញដូរភាគហ៊ុន

### ៤.២.៣ ដែនកំណត់ថ្លៃប្រចាំថ្ងៃ

ថ្លៃមូលដ្ឋាន គឺជាថ្លៃគោលដែលប្រើប្រាស់សម្រាប់គណនាដែនកំណត់ថ្លៃប្រចាំថ្ងៃ។ ជាទូទៅ ថ្លៃមូលដ្ឋាន គឺជាថ្លៃបិទនៃថ្ងៃជួញដូរចុងក្រោយ។ ដែនកំណត់នៃថ្លៃមូលដ្ឋានសម្រាប់ការជួញដូរមូលបត្រកម្មសិទ្ធិចុះបញ្ជីលក់ដំបូងត្រូវស្ថិតនៅចន្លោះ ៩០% និង ១៥០% នៃថ្លៃមូលបត្រកម្មសិទ្ធិបោះផ្សាយលក់ជាលើកដំបូង (ថ្លៃ IPO ដែលបានកំណត់នៅក្នុងឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីនៅ ន.ម.ក.)។ ចំពោះដែនកំណត់ថ្លៃប្រចាំថ្ងៃត្រូវស្មើនឹង បូក ឬ ដក ១០% នៃថ្លៃមូលដ្ឋាន។ ឧទាហរណ៍៖ ថ្លៃមូលដ្ឋាន = ១០,០០០រៀល

តារាងទី ៤.២ ដែនកំណត់ថ្លៃ

| បញ្ជាលក់ (ASK) | ថ្លៃ(៛) | បញ្ជាទិញ(Bid) |
|---|---|---|
| ដែនខាងលើ ១៥០% | ១៥,០០០ | |
| | ១១,០០០ | ដែនខាងលើ +១០% |
| ថ្លៃ IPO | ១០,០០០ | ថ្លៃមូលដ្ឋាន |
| ដែនខាងក្រោម ៩០% | ៩,០០០ | ដែនខាងក្រោម -១០% |

### ៤.២.៤ អាទិភាពថ្លៃនៃបញ្ជាទិញ លក់

➢ ថ្លៃ

- បញ្ជាលក់ដែលមានថ្លៃទាបជាង មានអាទិភាពលើបញ្ជាលក់ដែលមានថ្លៃខ្ពស់ជាង
- បញ្ជាទិញដែលមានថ្លៃទាបជាង មានអាទិភាពលើបញ្ជាទិញដែលមានថ្លៃខ្ពស់ជាង

➢ ពេលវេលា

- ករណីដែលបញ្ជាមានថ្លៃស្មើគ្នា នោះអាទិភាពបានទៅលើបញ្ជាដែលទទួលបានមុន

តារាងទី ៤.៣ អាទិភាពនៃបញ្ជាទិញ លក់

| បញ្ជាលក់ (ASK) | ថ្លៃ(៛) | បញ្ជាទិញ(Bid) |
|---|---|---|
| | ១០,៩៨០ | ៥០[១] |
| | ១០,៩៦០ | ២០០[២] ៣០០[៣] |
| | ១០,០០០ | |
| | ៩,៨៤០ | |
| ១០០[៣] ២០០[២] | ៩,៣៦០ | |
| ៥០[១] | ៩,២២០ | |

– អ្នកទី១ ធ្វើការបញ្ជាទិញ ៥០ភាគហ៊ុន នៅថ្លៃ ១០,៩៨០

– អ្នកទី២ ធ្វើការបញ្ជាទិញ ២០០ភាគហ៊ុន នៅថ្លៃ ១០,៩៦០

– អ្នកទី៣ ធ្វើការបញ្ជាទិញ ៣០០ភាគហ៊ុន នៅថ្លៃ ១០,៩៦០

– អ្នកទី១ ធ្វើការបញ្ជាលក់ ៥០ភាគហ៊ុន នៅថ្លៃ ៩,២២០

– អ្នកទី២ ធ្វើការបញ្ជាលក់ ២០០ភាគហ៊ុន នៅថ្លៃ ៩,៣៦០

– អ្នកទី៣ ធ្វើការបញ្ជាលក់ ១០០ភាគហ៊ុន នៅថ្លៃ ៩,៣៦០

ពេលផ្គូផ្គង គឺគេផ្គូផ្គងអ្នកលេខ១នៅបញ្ជាលក់ ជាមួយអ្នកលេខ១នៅបញ្ជាទិញ ដោយសារនៅបញ្ជាទិញ អ្នកលេខ១ ហ៊ានទិញនៅតម្លៃខ្ពស់។ ចំណែកនៅបញ្ជាលក់ អ្នកលេខ១ហ៊ានលក់នៅតម្លៃទាប ដូច្នេះទើបមាន អាទិភាពយកទៅផ្គូផ្គងមុនគេ។ ចំពោះអ្នកលេខ២ និងលេខ៣ ដាក់បញ្ជាទិញ-លក់ដំណាលគ្នា ដូច្នេះគេមើល ទៅលើពេលវេលាថា អ្នកណាដាក់បញ្ជាមុន។

### ៤.២.៥ វិធីសាស្ត្រជួញដូរ

រាល់ការជួញដូរត្រូវធ្វើឡើងតាមវិធីសាស្ត្រដេញថ្លៃ និងវិធីសាស្ត្រជួញដូរតាមការចរចា ៖[31]

**ក. វិធីសាស្ត្រដេញថ្លៃ** ៖ វិធីសាស្ត្រដេញថ្លៃចែកចេញជា ២ គឺ៖

- **វិធីសាស្ត្រដេញថ្លៃយកថ្លៃតែមួយ**

– ជាបញ្ជាទិញ និងបញ្ជាលក់ទាំងអស់ត្រូវបានផ្គូផ្គងព្រមគ្នា និងជួញដូរនៅថ្លៃតែមួយ។

– ថ្លៃផ្គូផ្គងជាថ្លៃដែលអាចផ្គូផ្គងនៅបរិមាណច្រើនបំផុត។

តារាងទី ៤.៤ វិធីសាស្ត្រដេញថ្លៃយកថ្លៃតែមួយ

| បញ្ជាលក់ (ASK) | ថ្លៃ(៛) | បញ្ជាទិញ (Bid) |
|---|---|---|
| | ១០,៥០០ | |
| ៣០០[១] | ១០,៤០០ | ៧០០[៣] ១០០ |
| ២០០[២] | ១០,៣០០ | |
| ១០០[៤] | ១០,២០០ | |
| | ១០,១០០ | |
| ៦០០ | សរុប | ៧០០ |

[31] http://csx.com.kh/operation/market/listPosts.do?MNCD=30201 គេហទំព័ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (២០២១), ការជួញដូរភាគហ៊ុន

ម៉ោងជួញដូរ៖ ៩:០០ AM និង ៣:០០ PM

តម្លៃជួញដូរ៖ ៦០០ x ១០,៤០០៛ = ៦,២៤០,០០០៛

- **វិធីសាស្ត្រដេញថ្លៃយកថ្លៃច្រើន**

– ជាបញ្ជាមួយត្រូវបានផ្គូផ្គង និងអាចជួញដូរបាននៅថ្លៃច្រើនខុសពីគ្នា។

– ថ្លៃជួញដូរគឺជាថ្លៃនៃបញ្ជាដែលទទួលបានមុន។

តារាងទី ៤.៥ វិធីសាស្ត្រដេញថ្លៃយកថ្លៃច្រើន

| បញ្ជាលក់ (ASK) | ថ្លៃ(៛) | បញ្ជាទិញ(Bid) |
|---|---|---|
| | ១០,៥០០ | |
| ~~៣០០~~[១] | ១០,៤០០ | ~~៧០០~~[៣] ១០០ |
| ~~២០០~~[២] | ១០,៣០០ | |
| ~~១០០~~[៤] | ១០,២០០ | |
| | ១០,១០០ | |
| ៦០០ | សរុប | ៧០០ |

ម៉ោងជួញដូរ៖ ៩:០០ AM និង ២:៥០ PM

១. ២០០ x ១០,៣០០៛ = ២,០៦០,០០០៛ (ភ្លាមៗ )

២. ៣០០ x ១០,៤០០៛ = ៣,១២០,០០០៛ (ភ្លាមៗ )

៣. ១០០ x ១០,៤០០៛ = ១,០៤០,០០០៛ (ភ្លាមៗ )

៦,២២០,០០០៛

**ខ. វិធីសាស្ត្រជួញដូរតាមការចរចា**

វិធីសាស្ត្រជួញដូរតាមការចរចា ជាវិធីសាស្ត្រផ្គូផ្គងបញ្ជាតាមការចរចាទិញនិងលក់មួយគូ បន្ទាប់ពីអ្នកទិញនិងអ្នកលក់បានចរចា និងព្រមព្រៀងលើលក្ខខណ្ឌទាំងឡាយនៃការជួញដូរ។ ដើម្បីផ្គូផ្គងបញ្ជាទិញនិងលក់តាមការចរចាមួយគូបាន ចាំបាច់ត្រូវមានពត៌មានលម្អិតដូចគ្នាទាំងស្រុងចំនួន ៤ គឺ ឈ្មោះមូលបត្រ, ថ្លៃ, បរិមាណ និងលេខកូដជួញដូរតាមការចរចា។

រូបភាពទី ៤.៣ វិធីសាស្ត្រជួញដូរតាមការចរចា




លក្ខណៈសំខាន់ៗនៃវិធីសាស្ត្រជួញដូរតាមការចរចារៈ

- បញ្ជាអប្បបរមា៖ បញ្ជាតាមការចរចាត្រូវមានបរិមាណយ៉ាងហោច៥០.០០០ភាគហ៊ុន ឬតម្លៃជួញដូរ ២០០.០០០.០០០រៀល (យកមួយណាដែលតូចជាង)។
- ឯកតាគម្លាតថ្លៃ៖ ១រៀល។
- ដែនកំណត់ថ្លៃប្រចាំថ្ងៃ៖ មិនអនុវត្តចំពោះការជួញដូរតាមវិធីសាស្ត្រជួញដូរតាមការចរចា។
- ការលុបចោលបញ្ជា៖ ដរាបណាបញ្ជាមិនទាន់អនុវត្តការជួញដូរ នោះបញ្ជាតាមការចរចាអាចលុបបាន តែពុំអាចកែប្រែបានឡើយ។

## ៤.៣ នីតិវិធីការជួញដូរមូលបត្រកម្មសិទ្ធិ

### ៤.៣.១ ការដាក់បញ្ជាជួញដូរ

បន្ទាប់ពីទទួលបានលេខអត្តសញ្ញាណវិនិយោគិន និងបានបើកគណនីជួញដូរមូលបត្រហើយ វិនិយោគិនអាចធ្វើការដាក់បញ្ជាទិញ-លក់មូលបត្រនៅ ផ.ម.ក. តាមរយៈក្រុមហ៊ុនមូលបត្របាន។ មុននឹងដាក់បញ្ជាបាន វិនិយោគិនត្រូវមានលុយ ១០០% (សម្រាប់បញ្ជាទិញ) ឬមូលបត្រ ១០០% (សម្រាប់បញ្ជាលក់)។ បន្ទាប់ពីវិនិយោគិនដាក់បញ្ជាទិញ-លក់ហើយ ក្រុមហ៊ុនមូលបត្រជាអ្នកបញ្ជូនបញ្ជាទិញ-លក់នោះបន្តទៅប្រព័ន្ធរបស់ ផ.ម.ក. ដែលមានប្រតិបត្តិករ ៣ គឺ៖

- **ប្រតិបត្តិករទីផ្សារមូលបត្រ៖** ជាប្រតិបត្តិករជួរមុខមានតួនាទីក្នុងការទទួលបញ្ជា ដែលវិនិយោគិនធ្វើការបញ្ជាទិញហើយធ្វើការប្រមូលនូវបញ្ជាទិញ-លក់ទាំងអស់ចូលក្នុងប្រព័ន្ធ ដើម្បីគណនា និងផ្គូផ្គងរកបញ្ជាថ្លៃណាដែលអាចជួញដូរជាមួយគ្នាបាន។ បន្ទាប់ពីមានការផ្គូផ្គងរួច ប្រតិបត្តិករទីផ្សារមូលបត្រត្រូវរកថ្លៃណាដែលត្រូវគ្នាទើបអាចមានការជួញដូរបាន ឬការជួញដូរបានជោគជ័យ ហើយត្រូវបញ្ជូនពត៌មាននៃការជួញដូរជោគជ័យនោះទៅប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ។ ថ្ងៃជួញដូរនេះហៅថា T0។

- **ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ៖** ទទួលយកពត៌មាននៃការជួញដូរជោគជ័យហើយមានតួនាទីធ្វើការផាត់ទាត់ និងទូទាត់ដោយធ្វើនៅមួយថ្ងៃបន្ទាប់ពីថ្ងៃជួញដូរ (T+១) ដោយធ្វើការបន្សុទ្ធថ្លៃជាមួយនឹងមូលបត្រ ដែលមានការជួញដូរនៅក្នុងប្រព័ន្ធ ផ.ម.ក. គឺធ្វើការកាត់កងថ្លៃសរុបរបស់ក្រុមហ៊ុនមូលបត្រនីមួយៗថាមានវិនិយោគិនណាខ្លះដាក់បញ្ជាទិញ និងវិនិយោគិនណាខ្លះដាក់បញ្ជាលក់។ ដូចនេះ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ នឹងធ្វើការសរុបថ្លៃហើយកាត់កងគ្នាដើម្បីដឹងថាក្រុមហ៊ុនមូលបត្រនោះអស់សាច់ប្រាក់ប៉ុន្មាន ឬទទួលបានសាច់ប្រាក់ប៉ុន្មាន។ បន្ទាប់ពីធ្វើការបន្សុទ្ធរួច ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ត្រូវបញ្ជូនពត៌មាននោះទៅប្រតិបត្តិកររក្សាទុកមូលបត្រ។
- **ប្រតិបត្តិកររក្សាទុកមូលបត្រ** ៖ មានតួនាទីគ្រប់គ្រង និងរក្សាទុកមូលបត្រ។ ចំពោះសាច់ប្រាក់ ប្រតិបត្តិករនេះមានជំនួយការរបស់គាត់ គឺភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ (CSA) ដោយប្រតិបត្តិកររក្សាទុកមូលបត្រត្រូវបញ្ជូនពត៌មាននៃការទូទាត់សាច់ប្រាក់ បន្ទាប់ពីប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ធ្វើការទូទាត់ហើយនៅថ្ងៃ (T+១) ទៅឲ្យ CSA ដែលជាជំនួយការទូទាត់សាច់ប្រាក់របស់គាត់។ពេល CSA ទទួលបានពត៌មាននឹងហើយក៏មិនទាន់ទូទាត់ភ្លាមៗដែល គឺត្រូវការពត៌មានមួយទៀតដែលពត៌មាននោះទទួលបានពីក្រុមហ៊ុនមូលបត្រ។ នៅព្រឹកថ្ងៃ (T+២) ក្រុមហ៊ុនមូលបត្រនឹងផ្ញើពត៌មានសម្រាប់ឲ្យ CSA ធ្វើការទូទាត់ឲ្យ។ បន្ទាប់ពីបានពត៌មានគ្រប់ហើយ CSA នឹងធ្វើការទូទាត់ហើយផ្ញើឯកសារមកប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រវិញ ដើម្បីធ្វើការផ្ទៀងផ្ទាត់។ ពេលផ្ទៀងផ្ទាត់ហើយ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនឹងធ្វើការរៀបចំ ហើយបញ្ជូនពត៌មានទៅប្រតិបត្តិកររក្សាទុកមូលបត្រដើម្បីធ្វើការផ្លាស់ប្តូរផ្ទេរកម្មសិទ្ធិករ។ ហើយសាច់ប្រាក់ និងមូលបត្រនឹងធ្វើការផ្ទេរក្នុងពេលតែមួយនៅព្រឹកថ្ងៃ (T+២) មុនម៉ោង ៩:៣០។

រូបភាពទី ៤.៤ ការដាក់បញ្ជាជួញដូរ



### ៤.៣.២ មធ្យោបាយ និងពត៌មាននៃការដាក់បញ្ជា

➢ **មធ្យោបាយនៃការដាក់បញ្ជា**

វិនិយោគិនអាចដាក់បញ្ជាទៅកាន់ក្រុមហ៊ុនមូលបត្រតាមមធ្យោបាយដូចជា៖

- ដាក់បញ្ជាដោយផ្ទាល់នៅក្រុមហ៊ុនមូលបត្រ
- ឯកសារជាលាយលក្ខណ៍អក្សរ
- ពាក្យសម្តី
- អ៊ីម៉ែល ទូរស័ព្ទ ឬ ទូរសារ

➢ **ពត៌មាននៃការដាក់បញ្ជា**

ពត៌មានដែលវិនិយោគិនត្រូវផ្តល់ឲ្យក្រុមហ៊ុនមូលបត្រ ពេលដែលដាក់បញ្ជាទិញ លក់មានដូចជា៖

- ឈ្មោះវិនិយោគិន
- លេខអត្តសញ្ញាណវិនិយោគិន
- លេខគណនីជួញដូរ
- ឈ្មោះមូលបត្រ
- ប្រភេទបញ្ជាទិញ-លក់
- បរិមាណ
- ថ្លៃ។

### ៤.៣.៣ យន្តការនៃការជួញដូរ

➢ **ថ្ងៃជួញដូរ ($T_0$)**

មុនចាប់ផ្តើមជួញដូរ វិនិយោគិនត្រូវបញ្ចូលសាច់ប្រាក់ទៅក្នុងគណនីជួញដូររបស់ក្រុមហ៊ុនមូលបត្រឲ្យបានមុនម៉ោងជួញដូរ។ ផ្សារចាប់ផ្តើមបើកនិងទទួលបញ្ជាចាប់ពីម៉ោង ៨:០០ព្រឹក ដល់ម៉ោង ៣:០០រសៀល ប៉ុន្តែការផ្គូរផ្គងបញ្ជាចាប់ផ្តើមពីម៉ោង ៩:០០ព្រឹក ដល់ម៉ោង ២:៥០រសៀល និងផ្គូផ្គងលើកចុងក្រោយនៅម៉ោង ៣:០០ រសៀល។

➢ **មួយថ្ងៃបន្ទាប់ពីថ្ងៃជួញដូរ (T+១ )**

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រចាប់ផ្តើមធ្វើការផាត់ទាត់សាច់ប្រាក់និងមូលបត្រដើម្បីស្វែងរកចំនួនសាច់ប្រាក់ និងចំនួនមូលបត្រសរុបដែលវិនិយោគិនម្នាក់ទទួលបាន។

ពីម៉ោង ១:៣០ ដល់ម៉ោង ២:៣០នាទីថ្ងៃ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ ចេញសេចក្តីណែនាំសម្រាប់ការទូទាត់ទៅកាន់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ និងក្រុមហ៊ុនមូលបត្រ។

➢ **ពីរថ្ងៃបន្ទាប់ពីថ្ងៃជួញដូរ (T+២ )**

មុនម៉ោង ៨:៣០ព្រឹក ក្រុមហ៊ុនមូលបត្រដែលជាអ្នកទិញត្រូវផ្ទេរសាច់ប្រាក់ពីគណនីក្រុមហ៊ុនមូលបត្រចូលទៅក្នុងគណនីរបស់ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ។ បន្ទាប់មក សាច់ប្រាក់ត្រូវបានផ្ទេរពីគណនីប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រទៅគណនីក្រុមហ៊ុនមូលបត្រដែលជាអ្នកលក់។ ពេលនោះដែរ មូលបត្រត្រូវបានផ្ទេរពីគណនីក្រុមហ៊ុនមូលបត្រដែលជាអ្នកលក់ទៅគណនីក្រុមហ៊ុនមូលបត្រដែលជាអ្នកទិញតាមរយៈគណនីមូលបត្ររបស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ។

រូបភាពទី ៤.៥ យន្តការនៃការជួញដូរ




(១) វិនិយោគិនបើកគណនីជួញដូរ (គណនីសាច់ប្រាក់ និងគណនីមូលបត្រ) នៅក្រុមហ៊ុនមូលបត្រមួយនៅមួយថ្ងៃមុនថ្ងៃជួញដូរ។

(២) វិនិយោគិនផ្តល់សេចក្តីបង្គាប់ឲ្យដាក់បញ្ជា (ទិញឬលក់) ទៅកាន់ក្រុមហ៊ុនមូលបត្រជាលាយលក្ខណ៍អក្សរ ពាក្យសំដី (ថតទុក) ឬមធ្យោបាយអេឡិចត្រូនិចនានា។

(៣) ក្រុមហ៊ុនមូលបត្រដាក់បញ្ជាទៅតាមការបង្គាប់មកកាន់ ន.ម.ក. ប៉ុន្តែមុននឹងដាក់បញ្ជាក្រុមហ៊ុនមូលបត្របានបង្កកទុករួចហើយនូវសាច់ប្រាក់ ឬបរិមាណមូលបត្រយ៉ាងហោច ១០០% នៃបញ្ជានីមួយៗ។

(៤) បញ្ជាទាំងឡាយត្រូវបានផ្គូផ្គងនៅក្នុងប្រព័ន្ធជួញដូររបស់ ផ.ម.ក. ទៅតាមគោលការណ៍ដេញថ្លៃដែលបានកំណត់ទុកជាមុន។

(៥) ផ.ម.ក. ជូនដំណឹងអំពីលទ្ធផលនៃការជួញដូរទៅកាន់ក្រុមហ៊ុនមូលបត្រ នៅថ្ងៃ T+0។

(៦) ក្រុមហ៊ុនមូលបត្របញ្ជាក់លទ្ធផលនៃការជួញដូរដែលពាក់ព័ន្ធជាមួយអតិថិជននីមួយៗរបស់ខ្លួន (នៅ T+0)។

(៧) ក្នុងករណីមានកំហុសឆ្គងប្រតិបត្តិការបង្កឡើងដោយក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនមូលបត្រនោះត្រូវដាក់ពាក្យស្នើសុំមកកាន់ ផ.ម.ក. ដើម្បីកែតម្រូវមុនពេលថ្ងៃត្រង់នៃថ្ងៃ T+1។ បន្ទាប់ពីកំហុសឆ្គងត្រូវបានកែតម្រូវ ហើយដំណើរការក្នុងចំនុចទី៥ និងទី៦ នឹងត្រូវអនុវត្តម្តងទៀត។

(៨) វិនិយោគិនបង់ប្រាក់ ឬបញ្ជូនមូលបត្រតាមរយៈក្រុមហ៊ុនមូលបត្រ។ ប៉ុន្តែជាក់ស្តែង គឺក្រុមហ៊ុនមូលបត្រប្រើប្រាស់សាច់ប្រាក់ ឬមូលបត្ររបស់អតិថិជន ដែលបានបង្កកទុកដើម្បីទូទាត់ដោយសុំ ឬមិនបាច់សុំការអនុញ្ញាតពីអតិថិជនឡើយ។

(៩) ក្រុមហ៊ុនមូលបត្រទូទាត់ការជួញដូរក្នុងនាមវិនិយោគិននៅ ផ.ម.ក.។

## ៤.៤ យន្តការនៃការផាត់ទាត់ និងទូទាត់មូលបត្រ

ដើម្បីផ្តល់ភាពងាយស្រួលក្នុងការទូទាត់សាច់ប្រាក់ និងទូទាត់មូលបត្រនៅក្នុងដំណើរការនៃការផាត់ទាត់ និងទូទាត់មូលបត្រកម្មសិទ្ធិ សមាជិក (សំដៅដល់ក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពី ន.ម.ក. ដែលមានសិទ្ធិប្រើប្រាស់នូវប្រព័ន្ធរបស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្ររបស់ ផ.ម.ក.) តម្រូវឲ្យបើកគណនី ២ ប្រភេទ គឺបើកគណនីទូទាត់សម្រាប់ការទូទាត់សាច់ប្រាក់ និងគណនីទូទាត់សម្រាប់ការទូទាត់មូលបត្រ។

### ៤.៤.១ ការបើកគណនីសាច់ប្រាក់សម្រាប់ការទូទាត់សាច់ប្រាក់

មុននឹងចាប់ផ្តើម ប្រតិបត្តិការនេះគ្រប់សមាជិក និងអ្នកពាក់ព័ន្ធនឹងការទូទាត់សាច់ប្រាក់ទាំងអស់ចាំបាច់ត្រូវបើកគណនីទូទាត់សាច់ប្រាក់ ក្នុងគោលបំណងបំពេញកាតព្វកិច្ចក្នុងការទូទាត់សាច់ប្រាក់ពេលធ្វើប្រតិបត្តិការជួញដូរមូលបត្រ។ សមាជិកទាំងអស់តម្រូវឲ្យបើកគណនីសាច់ប្រាក់ ៣ គឺ៖

- គណនីទូទាត់សាច់ប្រាក់ក្នុងនាមខ្លួនផ្ទាល់ (Cash Account)៖ បើកនៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដើម្បីបំពេញកាតព្វកិច្ចទូទាត់សាច់ប្រាក់។ បន្ទាប់ពីបានបើកគណនីសាច់ប្រាក់ ឬមានការផ្លាស់ប្តូរគណនីសាច់ប្រាក់ សមាជិកត្រូវរាយការណ៍អំពីឈ្មោះនៃភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្ររបស់ខ្លួន និងលេខគណនីទូទាត់ជូនដល់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ យ៉ាងហោចណាស់ ៥ ថ្ងៃនៃថ្ងៃធ្វើការមុនចាប់ផ្តើមការជួញដូរ។[32]
- គណនេយ្យទូទាត់សាច់ប្រាក់ក្នុងនាមអតិថិជន (Client Money Account)៖ បើកនៅភ្នាក់ងារទូទាត់សាច់

[32] ប្រកាសស្តីពីការដាក់ឲ្យអនុវត្តវិធានប្រតិបត្តិការប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ, លេខ ០០៥/១១គ.ម.ក./ប្រ.ក.,០៣ ឧសភា ២០១១ ប្រការ៧

ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ក្រោមឈ្មោះរបស់ក្រុមហ៊ុនមូលបត្រ ដើម្បីបំពេញកាតព្វកិច្ចទូទាត់សាច់ប្រាក់នៅក្នុងប្រតិបត្តិការជួញដូរមូលបត្រ។ អតិថិជនអាចធ្វើការទូទាត់សាច់ប្រាក់ជាប្រាក់រៀល ឬដុល្លារបាន ដែលនេះជាកត្តាមួយដែលបង្កភាពងាយស្រួលដល់អតិថិជន។[33]

- គណនេយ្យទូទាត់សាច់ប្រាក់របស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ (Cash Settlement Account)៖ បើកនៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ជាប្រាក់រៀលដើម្បីអនុញ្ញាតឲ្យប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្របំពេញកាតព្វកិច្ចទូទាត់សាច់ប្រាក់ទៅឲ្យសមាជិករបស់ខ្លួននូវការបរិច្ឆេទទូទាត់ជាប្រាក់រៀល តាមរយៈប្រព័ន្ធពត៌មានវិទ្យារបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

ការទូទាត់សាច់ប្រាក់ត្រូវបានធ្វើឡើង តាមរយៈការផ្ទេរសាច់ប្រាក់ពីគណនីសាច់ប្រាក់របស់សមាជិកទៅគណនីទូទាត់សាច់ប្រាក់របស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ។ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រត្រូវផ្ទេរសាច់ប្រាក់ទទួលបាននេះទៅឲ្យសមាជិក ដែលត្រូវទទួលបានការទូទាត់សាច់ប្រាក់។

### ៤.៤.២ ការបើកគណនីសាច់ប្រាក់សម្រាប់ការទូទាត់មូលបត្រ

ការបើកគណនីទូទាត់សាច់ប្រាក់តែមួយដើម្បីបំពេញការទូទាត់ គឺមិនទាន់គ្រប់គ្រាន់នៅឡើយទេ ដូចនេះសមាជិក និងអ្នកពាក់ព័ន្ធទាំងអស់ត្រូវបើកគណនីមូលបត្រមួយទៀត។[34]

ក្រុមហ៊ុនមូលបត្រ ត្រូវបើកគណនីមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ ក្រោមឈ្មោះរបស់ក្រុមហ៊ុនមូលបត្រស្របតាមវិធានប្រតិបត្តិការរក្សាទុកមូលបត្ររបស់ប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីបំពេញកាតព្វកិច្ចក្នុងការទូទាត់មូលបត្រ។ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ត្រូវបើកគណនីមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រដើម្បីបំពេញកាតព្វកិច្ចក្នុងការទូទាត់មូលបត្រ និងធានាដល់ការទូទាត់មូលបត្រដែលជាសមាជិក។ ការទូទាត់មូលបត្រត្រូវធ្វើឡើងតាមរយៈការផ្ទេរក្នុងបញ្ជី (Book-EntryTransfer) ពីគណនីមូលបត្ររបស់សមាជិកទៅគណនីទូទាត់មូលបត្ររបស់ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រនៃ ផ.ម.ក.។ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រត្រូវផ្ទេរមូលបត្រដែលទទួលបាននេះទៅសមាជិក ដែលត្រូវទទួលបានការទូទាត់មូលបត្រ។

[33] គោលការណ៍ណែនាំស្តីពី នីតិនៃការទូទាត់សាច់ប្រាក់នៅក្នុងទីផ្សារមូលបត្រ, លេខ ០០៣/១២គ.ម.ក.ស.ជ.ណ.,១៤ កុម្ភៈ ២០១៤

[34] ប្រកាសស្តីពីការដាក់ឲ្យអនុវត្តវិធានប្រតិបត្តិការប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ, លេខ ០០៥/១១គ.ម.ក./ប្រ.ក.,០៣ ឧសភា ២០១១ ប្រការ៨

### ៤.៤.៣ ដំណើរការផាត់ទាត់

នៅពេលពត៌មានជួញដូរត្រូវបានបញ្ជាក់ និងផ្ទៀងផ្ទាត់រួចហើយក្រុមហ៊ុនមូលបត្រត្រូវតាំងនាមឲ្យអតិថិជន ក្នុងការទូទាត់សាច់ប្រាក់សម្រាប់មូលបត្រដែលបានទិញ ឬលក់ទៅភាគីម្ខាងទៀតដែលជាសមាជិក និងជាអន្តរការីរបស់អ្នកលក់មូលបត្រ ឬអ្នកទទួលមូលបត្រដោយប្រើប្រាស់សាច់ប្រាក់ ឬមូលបត្រដែលបានបង្កកទុករួចហើយ ក្នុងភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. ត្រូវគណនាចំនួនមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ចុងក្រោយដោយសមាជិក ឬអ្នកចូលរួម ដោយធ្វើការបន្សុទ្ធ ឬកាត់កងចំនួនមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ក្នុងថ្ងៃដូចគ្នារបស់សមាជិក ឬអ្នកចូលរួមនីមួយៗ។

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. ត្រូវជូនដំណឹងអំពីពត៌មានដូចខាងក្រោមដល់សមាជិក ឬអ្នកចូលរួមនៅកាលបរិច្ឆេទផាត់ទាត់ និងកាលបរិច្ឆេទទូទាត់៖

១. កាលបរិច្ឆេទផាត់ទាត់ និងកាលបរិច្ឆេទទូទាត់។

២. បរិមាណនៃមូលបត្រនីមួយៗដែលត្រូវទូទាត់ដោយសមាជិក ឬអ្នកចូលរួម ឬក្នុងនាមអតិថិជន។

៣. ទឹកប្រាក់ដែលត្រូវទូទាត់ដោយសមាជិក ឬអ្នកចូលរួម ឬក្នុងនាមអតិថិជន។

បរិមាណមូលបត្រ និងចំនួនសាច់ប្រាក់ដែលត្រូវទូទាត់ ត្រូវគណនាតាមវិធីសាស្ត្រដូចខាងក្រោម៖

- ចំពោះមូលបត្រ៖ ត្រូវបានគណនាដោយធ្វើការផាត់ទាត់បរិមាណលក់សរុប និងបរិមាណទិញសរុបនៃមូលបត្រនីមួយៗសម្រាប់សមាជិក ឬអ្នកចូលរួមដែលពាក់ព័ន្ធ។
- ចំពោះសាច់ប្រាក់៖ ត្រូវបានគណនាដោយធ្វើការផាត់ទាត់តម្លៃទិញសរុប និងតម្លៃលក់សរុបសម្រាប់សមាជិក ឬអ្នកចូលរួម ដែលពាក់ព័ន្ធ។[35]

### ៤.៤.៤ ដំណើរការទូទាត់

ការទូទាត់ គឺជាការបញ្ចប់ប្រតិបត្តិការដែលអ្នកលក់ផ្ទេរមូលបត្រ ឬឧបករណ៍ហិរញ្ញវត្ថុទៅឲ្យអ្នកទិញ ហើយអ្នកទិញផ្ទេរសាច់ប្រាក់ទៅឲ្យអ្នកលក់។[36]

---

[35] ប្រកាសស្តីពីការដាក់ឲ្យអនុវត្តវិធានប្រតិបត្តិការប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ, លេខ ០០៥/១១គ.ម.ក./ប្រ.ក.,០៣ ឧសភា ២០១១ ប្រការ១០

[36] http://csx.com.kh/operation/clearing/listPosts.do?MNCD=3030 គេហទំព័ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (២០២១), ការផាត់ទាត់និងទូទាត់

### ក. ការទូទាត់សាច់ប្រាក់

ដើម្បីបង្កលក្ខណៈងាយស្រួលដល់វិនិយោគិនក្នុងការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ និងបំបាត់នូវកំហុសឆ្គង ដែលអាចកើតឡើងដោយថាហេតុនៅកំឡុងពេលប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលបត្រផ្សារមូលបត្រកម្ពុជាបានបែងចែកការទូទាត់សាច់ប្រាក់ជា ២ គឺ៖[37]

➢ **ការទូទាត់សាច់ប្រាក់ក្នុងធនាគារតែមួយ**

មុនដល់កាលបរិច្ឆេទទូទាត់ (T+២) ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រចាំបាច់ត្រូវបញ្ជូនពត៌មាននៃការបន្សុទ្ធសាច់ប្រាក់ និងមូលបត្រដែលត្រូវទូទាត់ទៅកាន់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធ នឹងមូលបត្រ។ បន្ទាប់មកនៅមុនម៉ោង ៨:៣០នាទីព្រឹកនៃកាលបរិច្ឆេទទូទាត់ (T+២) ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវផ្ទេរសាច់ប្រាក់ពីគណនីសាច់ប្រាក់អតិថិជនក្នុងនាមជាអ្នកទិញ ទៅកាន់គណនីទូទាត់សាច់ប្រាក់របស់អតិថិជនក្នុងនាមជាអ្នកទិញដូចគ្នា ដែលបើកក្រោមឈ្មោះក្រុមហ៊ុនមូលបត្រ។ បន្ទាប់មកត្រូវផ្ទេរសាច់ប្រាក់ដែលត្រូវទូទាត់ទៅកាន់គណនីទូទាត់សាច់ប្រាក់របស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រយ៉ាងយូរនៅត្រឹមម៉ោង ១០:៣០នាទីព្រឹក។ បន្ទាប់មក ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រត្រូវបង្វិលសាច់ប្រាក់បន្តទៅគណនីទូទាត់សាច់ប្រាក់របស់អតិថិជនជាអ្នកលក់ ដែលបានបើកគណនីក្រោមឈ្មោះក្រុមហ៊ុនមូលបត្រនៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រយ៉ាងយូរត្រឹមម៉ោង១០:៣០នាទីព្រឹក។ ក្រោយពីចប់សព្វគ្រប់ហើយ ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រត្រូវជូនដំណឹងដល់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រអំពីការទូទាត់សាច់ប្រាក់ដែលបានអនុវត្តរួច។

➢ **ការទូទាត់សាច់ប្រាក់ក្នុងអន្តរធនាគារ**

ក្នុងការទូទាត់សាច់ប្រាក់តាមរយៈធនាគារពីរផ្សេងគ្នាត្រូវបានអនុវត្តតាមដំណាក់កាលដូចខាងក្រោម៖

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រត្រូវផ្តល់ការប្រឹក្សាដល់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រខាងអ្នកទិញ និងភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រខាងអ្នកលក់អំពីទម្រង់នៃការផ្ទេរប្រាក់រវាងគ្នានឹងគ្នា។ បន្ទាប់មកមុនម៉ោង ៨:៣០នាទីព្រឹកនៃកាលបរិច្ឆេទទូទាត់ (T+២) ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រខាងអ្នកទិញ ត្រូវផ្ទេរសាច់ប្រាក់ពីគណនីអតិថិជនរបស់អ្នកទិញ ទៅកាន់គណនីទូទាត់សាច់ប្រាក់ក្នុងនាមជាអ្នកទិញដែលបើកក្រោមឈ្មោះក្រុមហ៊ុនមូលបត្រ ទៅកាន់គណនីទូទាត់សាច់ប្រាក់របស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រដែលបើកនៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូល

[37] ហ៊ាង បុទម្យ និងហង់ ពិសី, «យន្តការផាត់ទាត់ និងទូទាត់មូលបត្រកម្មសិទ្ធិ», (និក្ខេបបទបរិញ្ញាបត្រ,សាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច,២០១៤,៤៧-៤៨)

បត្រខាងអ្នកទិញយ៉ាងយូរមុនម៉ោង ៨:៣០នាទីព្រឹក។ បន្ទាប់មកទៀត ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រខាងអ្នកទិញ ត្រូវផ្ទេរសាច់ប្រាក់ទៅកាន់គណនីទូទាត់សាច់ប្រាក់របស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រដែលបើកនៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រខាងអ្នកលក់ ឆ្លងតាមរយៈសភាផាត់ទាត់នៃធនាគារជាតិនៃកម្ពុជា។ នៅថ្ងៃដដែល ប្រតិបត្តិករផាត់ទាត់ និងទូទាត់មូលបត្រត្រូវផ្ទេរសាច់ប្រាក់ទៅគណនីទូទាត់សាច់ប្រាក់របស់អតិថិជនដែលបើកក្រោមឈ្មោះក្រុមហ៊ុនមូលបត្រ នៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រខាងអ្នកលក់យ៉ាងយូរត្រឹមម៉ោង ១០:៣០នាទីព្រឹក។ បន្ទាប់មក ក្រុមហ៊ុនមូលបត្រខាងអ្នកលក់ ត្រូវផ្ទេរសាច់ប្រាក់បន្តទៅកាន់គណនីអតិថិជនរបស់អ្នកលក់។ ចុងបញ្ចប់ក្រុមហ៊ុនមូលបត្រទាំងសងខាងត្រូវត្រួតពិនិត្យពីសមតុល្យសាច់ប្រាក់ក្នុងគណនីអតិថិជន ថាតើបានទទួលសាច់ប្រាក់ដូចតាមការទូទាត់ដែរ ឬទេ។

**ខ. ការទូទាត់មូលបត្រ**

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រត្រូវជូនដំណឹងដល់ប្រតិបត្តិកររក្សាទុកមូលបត្រ និងប្រតិបត្តិករទីផ្សារមូលបត្រអំពីការទូទាត់សាច់ប្រាក់ត្រូវបានបំពេញរួចរាល់ចប់សព្វគ្រប់អស់ហើយ។ បន្ទាប់មកប្រតិបត្តិកររក្សាទុកមូលបត្រត្រូវផ្ទេរមូលបត្រពីគណនីមូលបត្ររបស់ក្រុមហ៊ុនមូលបត្រដែលតំណាងឲ្យអតិថិជន (អ្នកលក់) ទៅកាន់គណនីមូលបត្ររបស់ក្រុមហ៊ុនមូលបត្ររបស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រដែលបានបើកនៅក្នុងប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីធ្វើការផាត់ទាត់មូលបត្រនៅពេលមានប្រតិបត្តិការជួញដូរមូលបត្រកើតឡើង។ ក្រោយមកទៀតប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រត្រូវធ្វើការផ្ទេរមូលបត្រពីគណនីមូលបត្ររបស់ខ្លួន ទៅកាន់គណនីមូលបត្ររបស់ក្រុមហ៊ុនមូលបត្រដែលតំណាងឲ្យអតិថិជន (អ្នកទិញ)។ ប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវជូនដំណឹងទៅកាន់តួអង្គពាក់ព័ន្ធក្នុងការផាត់ទាត់មូលបត្រដូចជាប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ ប្រតិបត្តិកររក្សាទុកមូលបត្រ និងក្រុមហ៊ុនមូលបត្រទាំងសងខាងផងដែរ។

## ៤.៥ យន្តការនៃការរក្សាទុកមូលបត្រ

ប្រតិបត្តិកររក្សាទុកមូលបត្រសំដៅដល់កន្លែងសម្រាប់ដាក់ផ្ញើរមូលបត្រ។ ការដាក់ផ្ញើរមូលបត្រ គឺជាដំណើរការនៃការផ្ទេរកម្មសិទ្ធិករមូលបត្រតាមរយៈការផ្ទេររវាងគណនី (Book Entry) (ការកត់ត្រាឥណទាន/ឥណពន្ធ ក្នុងសៀវភៅគណនីរបស់សមាជិក និងអ្នកចូលរួម) ដោយគ្មានចរន្តនៃការផ្ទេរមូលបត្ររូបវន្ត។

នៅពេលមូលបត្រមានការជួញដូររវាងវិនិយោគិន ប្រតិបត្តិកររក្សាទុកមូលបត្រធ្វើការទូទាត់នូវប្រតិបត្តិការទាំងនោះតាមរយៈការផ្ទេររវាងគណនី (Book Entry) ដោយគ្មានការផ្ទេរមូលបត្ររូបវន្ត។ ដូច្នេះហានិភ័យចំពោះការបាត់ និងការលួចមូលបត្រត្រូវបានជៀសវាងទាំងស្រុង។ សមាជិក អ្នកចូលរួម និងអតិថិជន ដែលបានដាក់ផ្ញើរមូលបត្រនៅ ផ.ម.ក. មិនចាំបាច់ដកមូលបត្រទៅវិញនៅពេលដែលត្រូវអនុវត្តសិទ្ធិកម្មសិទ្ធិករឡើយ។

បុគ្គលដែលអាចបើកគណនីមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្ររួមមាន ក្រុមហ៊ុនមូលបត្រ និងក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ។ បុគ្គលដែលមានបំណងបើកគណនីមូលបត្រត្រូវបំពេញបែបបទបើកគណនីមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ។ គ្រប់គណនីមូលបត្រទាំងអស់រួមមានគណនីមូលបត្ររបស់សមាជិក ឬអតិថិជនត្រូវបានបង្កើតឡើងក្នុងប្រព័ន្ធ Ledger (ledger system) របស់ ផ.ម.ក. ដែលផ្ទុកផងដែរនូវទិន្នន័យលម្អិតនៃប្រតិបត្តិការរបស់សមាជិក និងអតិថិជនព្រមទាំងទិន្នន័យលម្អិតនៃបញ្ជីភាគហ៊ុនិក។

ដើម្បីដាក់ផ្ញើរមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ បុគ្គលដែលដាក់ផ្ញើរត្រូវផ្តល់ព័ត៌មានដូចខាងក្រោមដល់ប្រតិបត្តិកររក្សាទុកមូលបត្រ៖

- ប្រភេទមូលបត្រ
- ចំនួននៃការបោះផ្សាយ
- ឈ្មោះមូលបត្រ
- អក្សរកូដ
- ចំនួនមូលបត្រសរុប
- កាលបរិច្ឆេទបោះផ្សាយ
- កាលបរិច្ឆេទចុះបញ្ជី
- ព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងកម្មសិទ្ធិភាពមូលបត្រ។[38]

## ៤.៦ ទិន្នន័យសំខាន់សំខាន់ៗនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ទិន្នន័យសំខាន់ៗនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាត្រូវបានដកស្រង់មកតាមត្រីមាសនីមួយៗ ដែលគិតពីឆ្នាំ ២០១៩ និង ២០២០។ ទិន្នន័យទាំងនោះរួមមាន៖

- ទំហំជួញដូរភាគហ៊ុន និងតម្លៃសរុបជាមធ្យមប្រចាំថ្ងៃ
- ការជួញដូរតាមប្រភេទវិនិយោគិន(ក្នុងស្រុក និងបរទេស)
- ការជួញដូរតាមប្រភេទវិនិយោគិន(រូបវន្តបុគ្គល និងនីតិបុគ្គល)
- ការចូលរួមដាក់បញ្ជាទិញ-លក់របស់វិនិយោគិនខ្មែរ និងបរទេស។

[38] http://csx.com.kh/operation/depository/listPosts.do?MNCD=3040 គេហទំព័ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (២០២១), ការរក្សាទុកមូលបត្រ

### ៤.៦.១ ទំហំជួញដូរភាគហ៊ុន និងតម្លៃសរុបជាមធ្យមប្រចាំថ្ងៃ

រូបភាពទី៤.៦ ទំហំជួញដូរភាគហ៊ុន និងតម្លៃសរុបជាមធ្យមប្រចាំថ្ងៃឆ្នាំ២០១៩




យោងតាមក្រាបខាងលើ យើងឃើញថានៅក្នុងឆ្នាំ ២០១៩៖

- នៅត្រីមាសទី១៖ ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃមានចំនួន ៦៧,៣១១ ភាគហ៊ុន ដែលមានតម្លៃប្រហែលនឹង ៥២,៨១៦ ដុល្លារសហរដ្ឋអាមេរិក។
- នៅត្រីមាសទី២៖ ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃមានចំនួន ១៨១,៥០៤ ភាគហ៊ុន ដែលមានតម្លៃប្រហែលនឹង ៥៦១,៦៤៤ ដុល្លារសហរដ្ឋអាមេរិក។
- នៅត្រីមាសទី៣៖ ទំហំជួញដូរជាមធ្យមថ្ងៃមានចំនួន ១២,៥៣៩ ភាគហ៊ុន ដែលមានតម្លៃប្រហែលនឹង ២៧,១២១ ដុល្លារសហរដ្ឋអាមេរិក។
- នៅត្រីមាសទី៤៖ ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃមានចំនួន ១១,៥០២ ភាគហ៊ុន ដែលមានតម្លៃប្រហែលនឹង ២៤,៦០៥ ដុល្លារសហរដ្ឋអាមេរិក។

រូបភាពទី៤.៧ ទំហំជួញដូរភាគហ៊ុន និងតម្លៃសរុបជាមធ្យមប្រចាំថ្ងៃ ឆ្នាំ២០២០



យោងតាមក្រាបខាងលើ យើងឃើញថានៅក្នុងឆ្នាំ ២០២០៖

- នៅត្រីមាសទី១៖ ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃមានចំនួន ៩,០៤០ ភាគហ៊ុន ដែលមានតម្លៃប្រហែលនឹង ១៥,៧២៣ ដុល្លារសហរដ្ឋអាមេរិក។
- នៅត្រីមាសទី២៖ ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃមានចំនួន ៦១,៧៨២ ភាគហ៊ុន ដែលមានតម្លៃប្រហែលនឹង ២៦៩,៩៥៤ ដុល្លារសហរដ្ឋអាមេរិក។
- នៅត្រីមាសទី៣៖ ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃមានចំនួន ៦០,០៣៤ ភាគហ៊ុន ដែលមានតម្លៃប្រហែលនឹង ១២៧,១៧០ ដុល្លារសហរដ្ឋអាមេរិក។
- នៅត្រីមាសទី៤៖ ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃមានចំនួន ៥៩,៩៣៣ ភាគហ៊ុន ដែលមានតម្លៃប្រហែលនឹង ៥៥,៩៧៩ ដុល្លារសហរដ្ឋអាមេរិក។

### ៤.៦.២ ការជួញដូរតាមប្រភេទវិនិយោគិន (ក្នុងស្រុក និងបរទេស)

រូបភាពទី៤.៨ ការជួញដូរតាមប្រភេទវិនិយោគិន(ក្នុងស្រុក និងបរទេស) ឆ្នាំ២០១៩




យោងតាមក្រាបខាងលើ យើងឃើញថានៅក្នុងឆ្នាំ ២០១៩៖

- នៅត្រីមាសទី១៖ ការជួញដូរតាមប្រភេទមាន ២៩% ជាវិនិយោគិនក្នុងស្រុក និង ៧១% ជាវិនិយោគិនក្រៅស្រុក។
- នៅត្រីមាសទី២៖ ការជួញដូរតាមប្រភេទមាន ១% ជាវិនិយោគិនក្នុងស្រុក និង ៩៩% ជាវិនិយោគិនក្រៅស្រុក។
- នៅត្រីមាសទី៣៖ ការជួញដូរតាមប្រភេទមាន ៦៣% ជាវិនិយោគិនក្នុងស្រុក និង ៣៧% ជាវិនិយោគិនក្រៅស្រុក។
- នៅត្រីមាសទី៤៖ ការជួញដូរតាមប្រភេទមាន ៦២% ជាវិនិយោគិនក្នុងស្រុក និង ៣៨% ជាវិនិយោគិនក្រៅស្រុក។

រូបភាពទី៤.៩ ការជួញដូរតាមប្រភេទវិនិយោគិន(ក្នុងស្រុក និងបរទេស) ឆ្នាំ២០២០




យោងតាមក្រាបខាងលើ យើងឃើញថានៅក្នុងឆ្នាំ ២០២០៖

- នៅត្រីមាសទី១៖ ការជួញដូរតាមប្រភេទមាន ៥១% ជាវិនិយោគិនក្នុងស្រុក និង ៤៩% ជាវិនិយោគិនក្រៅស្រុក។
- នៅត្រីមាសទី២៖ ការជួញដូរតាមប្រភេទមាន ៦០% ជាវិនិយោគិនក្នុងស្រុក និង ៤០% ជាវិនិយោគិនក្រៅស្រុក។
- នៅត្រីមាសទី៣៖ ការជួញដូរតាមប្រភេទមាន ៨១% ជាវិនិយោគិនក្នុងស្រុក និង ១៩% ជាវិនិយោគិនក្រៅស្រុក។
- នៅត្រីមាសទី៤៖ ការជួញដូរតាមប្រភេទមាន ៦៨% ជាវិនិយោគិនក្នុងស្រុក និង ៣២% ជាវិនិយោគិនក្រៅស្រុក។

### ៤.៦.៣ ការជួញដូរតាមប្រភេទវិនិយោគិន (រូបវ័ន្តបុគ្គល និងនីតិបុគ្គល)

រូបភាពទី៤.១០ ការជួញដូរតាមប្រភេទវិនិយោគិន(រូបវ័ន្តបុគ្គល និងនីតិបុគ្គល) ឆ្នាំ២០១៩



យោងតាមក្រាបខាងលើ យើងឃើញថានៅក្នុងឆ្នាំ ២០១៩ៈ

- នៅត្រីមាសទី១ៈ ការជួញដូរតាមប្រភេទវិនិយោគិនមាន ៤៧%ជារូបវន្តបុគ្គល និង ៥៣% ជានីតិបុគ្គល។
- នៅត្រីមាសទី២ៈ ការជួញដូរតាមប្រភេទវិនិយោគិនមាន ២%ជារូបវន្តបុគ្គល និង ៩៨% ជានីតិបុគ្គល។
- នៅត្រីមាសទី៣ៈ ការជួញដូរតាមប្រភេទវិនិយោគិនមាន ៩៤%ជារូបវន្តបុគ្គល និង ៦% ជានីតិបុគ្គល។
- នៅត្រីមាសទី៤ៈ ការជួញដូរតាមប្រភេទវិនិយោគិនមាន ៩៦%ជារូបវន្តបុគ្គល និង ៤% ជានីតិបុគ្គល។

រូបភាពទី៤.១១ ការជួញដូរតាមប្រភេទវិនិយោគិន (រូបវន្តបុគ្គល និងនីតិបុគ្គល) ឆ្នាំ២០២០




យោងតាមក្រាបខាងលើ យើងឃើញថានៅក្នុងឆ្នាំ ២០២០ៈ

- នៅត្រីមាសទី១ៈ ការជួញដូរតាមប្រភេទវិនិយោគិនមាន ៩០% ជារូបវន្តបុគ្គល និង ១០% ជានីតិបុគ្គល។
- នៅត្រីមាសទី២ៈ ការជួញដូរតាមប្រភេទវិនិយោគិនមាន ៦២% ជារូបវន្តបុគ្គល និង ៣៨% ជានីតិបុគ្គល។
- នៅត្រីមាសទី៣ៈ ការជួញដូរតាមប្រភេទវិនិយោគិនមាន ៧៣% ជារូបវន្តបុគ្គល និង ២៧% ជានីតិបុគ្គល។
- នៅត្រីមាសទី៤ៈ ការជួញដូរតាមប្រភេទវិនិយោគិនមាន ៦១% ជារូបវន្តបុគ្គល និង ៣៩% ជានីតិបុគ្គល។

### ៤.៦.៤ ការចូលរួមដាក់បញ្ជាទិញ-លក់របស់វិនិយោគិនខ្មែរ និងបរទេស

រូបភាពទី៤.១២ ការចូលរួមដាក់បញ្ជាទិញ-លក់របស់វិនិយោគិនខ្មែរ និងបរទេស ឆ្នាំ២០១៩






យោងតាមក្រាបខាងលើ យើងឃើញថានៅក្នុងឆ្នាំ ២០១៩៖

- នៅត្រីមាសទី១៖ ការចូលរួមដាក់បញ្ជាទិញលក់របស់វិនិយោគិន ជនជាតិខ្មែរ ៦៧% ជនជាតិចិន ១៨% ជនជាតិជប៉ុន ៩% ជនជាតិផ្សេងៗ ៦%។
- នៅត្រីមាសទី២៖ ការចូលរួមដាក់បញ្ជាទិញលក់របស់វិនិយោគិន ជនជាតិខ្មែរ ៦៣% ជនជាតិចិន ១៥% ជនជាតិជប៉ុន ១៣% ជនជាតិផ្សេងៗ ៩%។
- នៅត្រីមាសទី៣៖ ការចូលរួមដាក់បញ្ជាទិញលក់របស់វិនិយោគិន ជនជាតិខ្មែរ ៦៦% ជនជាតិចិន ១៣% ជនជាតិជប៉ុន ១២% ជនជាតិផ្សេងៗ ៩%។
- នៅត្រីមាសទី៤៖ ការចូលរួមដាក់បញ្ជាទិញលក់របស់វិនិយោគិន ជនជាតិខ្មែរ ៧៥% ជនជាតិចិន ៩% ជនជាតិជប៉ុន ១០% ជនជាតិផ្សេងៗ ៦%។

រូបភាពទី៤.១៣ ការចូលរួមដាក់បញ្ជាទិញ-លក់របស់វិនិយោគិនខ្មែរ និងបរទេស ឆ្នាំ២០២០



យោងតាមក្រាបខាងលើ យើងឃើញថានៅក្នុងឆ្នាំ ២០២០៖

- នៅត្រីមាសទី១៖ ការចូលរួមដាក់បញ្ជាទិញលក់របស់វិនិយោគិន ជនជាតិខ្មែរ ៧១% ជនជាតិចិន ៩% ជនជាតិជប៉ុន ១៤% ជនជាតិផ្សេងៗ ៦%។
- នៅត្រីមាសទី២៖ ការចូលរួមដាក់បញ្ជាទិញលក់របស់វិនិយោគិន ជនជាតិខ្មែរ ៩៣% ជនជាតិចិន ២% ជនជាតិជប៉ុន ៣% ជនជាតិផ្សេងៗ ២%។
- នៅត្រីមាសទី៣៖ ការចូលរួមដាក់បញ្ជាទិញលក់របស់វិនិយោគិន ជនជាតិខ្មែរ ៩២% ជនជាតិចិន ៣% ជនជាតិជប៉ុន ២% ជនជាតិផ្សេងៗ ៣%។
- នៅត្រីមាសទី៤៖ ការចូលរួមដាក់បញ្ជាទិញលក់របស់វិនិយោគិន ជនជាតិខ្មែរ ៩៣% ជនជាតិចិន ២% ជនជាតិជប៉ុន ៣% ជនជាតិផ្សេងៗ ២%។

## ៤.៧ ចំណុចខ្លាំង និងចំណុចខ្សោយនៃការជួញដូរមូលបត្រ

### ៤.៧.១ ចំណុចខ្លាំង

- រាជរដ្ឋាភិបាលក៏បានដើរតួនាទីយ៉ាងសំខាន់ក្នុងការជម្រុញការវិនិយោគលើវិស័យមូលបត្រឲ្យរីកចម្រើនទៅមុខបន្តទៀតដោយមានការអនុគ្រោះពន្ធជាដើម ដើម្បីទាក់ទាញវិនិយោគិនឲ្យចូលរួមក្នុងវិស័យនេះកាន់តែច្រើនឡើង
- ការចូលរួមភាគហ៊ុនពីក្រុមហ៊ុនមូលបត្រកូរ៉េ និងការបង្ហាត់បង្រៀនពីបុគ្គលិកជំនាញបានធ្វើឲ្យការរៀបចំដំណើរការ និងប្រតិបត្តិការក្នុងទីផ្សារមានលក្ខណៈច្បាស់លាស់ និងងាយស្រួលយល់
- ការដាក់អនុវត្តនូវច្បាប់ បទបញ្ញត្តិ វិធានការ និងប្រកាសដែលទាក់ទងនឹងប្រតិបត្តិករទីផ្សារ និងដំណើរការជួញដូរមានប្រសិទ្ធិភាព
- ប្រព័ន្ធបច្ចេកវិទ្យាទំនើប និងត្រឹមត្រូវសម្រាប់ដាក់អនុវត្តក្នុងយន្តការជាត់ទាត់ និងទូទាត់ព្រមទាំងរក្សាទុកមូលបត្រ
- ក្រុមហ៊ុនមូលបត្រដែលចូលរួមនៅក្នុងវិស័យមូលបត្រសុទ្ធតែជាក្រុមហ៊ុន ដែលត្រូវបានការទទួលស្គាល់ និងទទួលបានអាជ្ញាបណ្ណពីនិយ័តករមូលបត្រកម្ពុជា។
- ការផ្តល់ដំណឹង និងការផ្សព្វផ្សាយពត៌មានទាក់ទងនឹងមូលបត្រ ទីផ្សារមូលបត្រ និងទិន្នន័យផ្សេងៗរបស់ទីផ្សារតាមរយៈគេហទំព័រផ្លូវការ និងបណ្តាញសង្គមដែលធ្វើឲ្យមានភាពងាយស្រួលសម្រាប់វិនិយោគិន និងមហាជនទូទៅក្នុងការយល់ដឹងបន្ថែម
- ការយកចិត្តទុកដាក់ខ្ពស់ទៅលើការលើកកម្ពស់ និងការជម្រុញការយល់ដឹងពាក់ព័ន្ធនឹងវិស័យមូលបត្រដែលជាចំណេះដឹងមូលដ្ឋានសម្រាប់សាធារណជនដោយមានការរៀបចំសិក្ខាសិលាអប់រំ និងវគ្គបណ្តុះ

បណ្តាលបន្ថែម ព្រមទាំងបើកឲ្យមានកម្មវិធីប្រកួតប្រជែងដល់សិស្សនិស្សិត និងមហាជនក្នុងការអនុវត្ត ទិញ-លក់មូលបត្រនៅលើទីផ្សារ។

**៤.៧.២ ចំណុចខ្សោយ**

- ជាក់ស្តែង ទីផ្សារមូលបត្រនៅកម្ពុជាពុំទាន់សូវមានភាពទូលំទូលាយនៅឡើយទេ សាធារណជនភាគច្រើនពុំសូវមានការយល់ដឹងខាងផ្នែកវិស័យមូលបត្រ ចំណេះដឹងរបស់វិនិយោគិនទាក់ទងនឹងការជួញដូរមូលបត្រនៅផ្សារមូលបត្រកម្ពុជានៅមានកម្រិតនៅឡើយ
- ក្រុមហ៊ុនចុះបញ្ជីក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាមានចំនួនតិច ដែលជាហេតុធ្វើឲ្យមានជម្រើសតិចក្នុងការជ្រើសរើស
- ចំនួននៃប្រតិបត្តិការជួញដូរមានកម្រិតទាបនៅឡើយ ដែលនាំឲ្យវិនិយោគិនខ្វះការទុកចិត្តលើក្រុមហ៊ុនមូលបត្រ និងដំណើរការទីផ្សារ
- នៅលើទីផ្សារមូលបត្រកម្ពុជាមិនទាន់ឃើញមានការជួញដូរមូលបត្រច្រើនប្រភេទ ឬច្រើនបែបនៅឡើយ ជាហេតុនាំឲ្យមិនសូវទាក់ទាញវិនិយោគិន ក៏ដូចជាក្រុមហ៊ុនមួយចំនួនដែលមានបំណងចង់បង្កើនដើមទុន ឬមូលធនតាមរយៈការបោះផ្សាយលក់មូលបត្រ។

# សេចក្តីសន្និដ្ឋាន
# និងការផ្តល់អនុសាសន៍

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

បន្ទាប់ពីធ្វើការស្រាវជ្រាវលើប្រធានបទតាមរយៈការដកស្រង់ព័ត៌មានពាក់ព័ន្ធបានមកពី បណ្ណាល័យ ប្រព័ន្ធអ៊ីនធឺណិត និងឯកសារយោងពីសាស្ត្រាចារ្យកន្លងមក អាចឲ្យយើងសង្កេតឃើញថាផ្សារមូលបត្រដែលបានដាក់ដំណើរការនៅក្នុងឆ្នាំ ២០១១ បានប្រព្រឹត្តទៅស្របតាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលដែលមានការរៀបចំច្បាប់ និងបទបញ្ញត្តិផ្សេងៗទាក់ទងនឹងវិស័យនេះប្រកបដោយប្រសិទ្ធិភាព។ ការលំបាកដែលជួបប្រទះត្រូវបានដោះស្រាយជាបណ្តើរៗ ដោយមានការត្រួតពិនិត្យ និងណែនាំពីសំណាក់ ន.ម.ក. ដែលប្រៀបដូចជាអាណាព្យាបាលរបស់ ផ.ម.ក. ទើបក្រុមហ៊ុននេះអាចដំណើរការបានយ៉ាងល្អនៅឆ្នាំ ២០១២។ លើសពីនេះ ផ.ម.ក. ក៏បានគោរពតាមមុខងារព្រមទាំងបានបំពេញតួនាទីយ៉ាងល្អក្នុងការផ្តល់សេវាជួញដូរមូលបត្រ ដល់វិនិយោគិនក៏ដូចជាសាធារណៈជនផងដែរ។

ជាលទ្ធផលនៃការស្រាវជ្រាវចំណោទបញ្ហាដែលចោទទៅលើការយល់ដឹងពីផ្សារមូលបត្រកម្ពុជា បានបង្ហាញថាការជួញដូរនៅក្នុងផ្សារមូលបត្រកម្ពុជា ត្រូវអនុវត្តដោយប្រតិបត្តិករទាំងបីនៅក្នុងទីផ្សារ។ រាល់ដំណាក់កាលនីមួយៗពិតជាមានការស្មុគស្មាញ ដោយមានវិធានជាច្រើនដែលតម្រូវឲ្យ ផ.ម.ក. ខិតខំព្យាយាមបន្តការងារនេះរហូតដល់មានប្រសិទ្ធភាពឡើង។ ទន្ទឹមនឹងនេះដើម្បីធ្វើការជួញដូរបាន គឺតម្រូវឲ្យវិនិយោគិន និងសា-ធារណៈជនទូទៅត្រូវ មានលេខអត្តសញ្ញាណវិនិយោគិន និងបើកគណនីជួញដូរជាមួយក្រុមហ៊ុនមូលបត្រជាមុនសិន។ បន្ទាប់មកទៀតវិនិយោគិនគ្រាន់តែស្វែងយល់ខ្លះៗអំពីវិធាននៃការជួញដូរ ម៉ោងជួញដូរ និងឯកតាជួញដូរ ដើម្បីធ្វើការជួញដូរក្នុងទីផ្សារមូលបត្រ និងរង់ចាំការជាត់ទាត់ និងទូទាត់ ព្រមទាំងការរក្សាទុកមូលបត្រពីប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ។

សរុបសេចក្តីមកឆ្លងតាមការសិក្សាស្រាវជ្រាវលើប្រធានបទនេះ យើងអាចសន្និដ្ឋានបានថា ទីផ្សារមូលបត្រកម្ពុជា ជាកាតាលីករមួយដ៏សំខាន់ក្នុងការជម្រុញនូវការប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុឲ្យបានទូលំទូលាយជាងមុន និងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិផងដែរ។

## ២. ការផ្តល់អនុសាសន៍

ដើម្បីធ្វើឲ្យវិស័យមូលបត្រនេះមានភាពរីកចម្រើនដោយទទួលបានជោគជ័យខ្ពស់ នាងខ្ញុំសូមចូលរួមផ្តល់ជាអនុសាសន៍ដូចខាងក្រោមៈ

- ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា គួរតែបន្តស្វែងយល់ពីវិស័យនេះបន្ថែមទៀតពីប្រទេសជិតខាង ដើម្បីធ្វើឲ្យវិស័យនេះកាន់តែមានការរីកចម្រើនខ្លាំងឡើង ដែលអាចចូលរួមក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិផងដែរ

- ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា គួរតែណែនាំជម្រុញបន្ថែមដល់គ្រឹះស្ថានសាធារណៈ និងឯកជនឲ្យធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈឲ្យបានច្រើន ដើម្បីឲ្យពួកគេអាចកៀរគរប្រមូលដើមទុនមកប្រើប្រាស់ក្នុងអាជីវកម្មរបស់គេ លើសពីនេះទៅទៀត ការបង្កើនការបោះផ្សាយលក់មូលបត្រនេះក៏អាចផ្តល់ជម្រើសយ៉ាងច្រើនដល់វិនិយោគិន ដែលមានបំណងក្នុងការវិនិយោគលើទីផ្សារមូលបត្រ
- ដោយសារក្រុមហ៊ុនមួយចំនួនយល់ថា ការបោះផ្សាយលក់មូលបត្រមាននីតិវិធីចុះបញ្ជីច្រើន ចំណាយទុន និងពេលវេលាច្រើន រដ្ឋាភិបាលកម្ពុជាគួរតែធ្វើការបន្ធូរបន្ថយនូវច្បាប់មួយចំនួន និងគួរតែពន្យល់ពីច្បាប់ទាំងនោះទៅដល់ក្រុមហ៊ុនឲ្យបានច្បាស់លាស់ ដើម្បីជាភាពងាយស្រួលដល់ការបោះផ្សាយលក់មូលបត្រ
- និយ័តករមូលបត្រកម្ពុជា គួររៀបរៀងសៀវភៅណែនាំខ្លីៗស្តីពីយន្តការ ឬដំណើរការនៃការជួញដូរមូលបត្រដោយធ្វើការសម្រាយពីច្បាប់ បទបញ្ញត្តិ អនុក្រឹត្យ និងគោលការណ៍ណែនាំផ្សេងៗ ដែលពាក់ព័ន្ធនឹងវិស័យមូលបត្រដើម្បីចែកដល់វិនិយោគិន ឬក្រុមហ៊ុនមូលបត្រក៏ដូចជាប្រជាពលរដ្ឋ និងសិស្សនិស្សិតទូទៅ។ ការធ្វើដូចនេះនឹងផ្តល់ភាពងាយស្រួលដល់វិនិយោគិន និងបងប្អូនប្រជាពលរដ្ឋក្នុងការស្វែងយល់ពីវិស័យមូលបត្រនេះ។
- ដើម្បីឲ្យមានការកើនឡើងនៃចំនួនក្រុមហ៊ុនចុះបញ្ជី និងការវិនិយោគនៅលើទីផ្សារកម្ពុជា ន.ម.ក. និង ផ.ម.ក. គួរតែបង្កើតឲ្យមានរង្វាន់លើកទឹកចិត្តសម្រាប់ក្រុមហ៊ុនចុះបញ្ជីដំបូង និងវិនិយោគិនដែលបានជួញដូរច្រើន
- និយ័តករមូលបត្រកម្ពុជា គួរបន្តឲ្យមានការប្រកួតប្រជែងទាក់ទងនឹងការជួញដូរមូលបត្រដើម្បីជាកត្តាទាក់ទាញចំណាប់អារម្មណ៍ពីមហាជនឲ្យមានការចង់ដឹងចង់លឺពីវិស័យមូលបត្រនៅកម្ពុជា។ ម្យ៉ាងទៀតកម្មវិធីប្រកួតប្រជែងគឺជាជំហានដំបូងដ៏មានប្រសិទ្ធភាពមួយក្នុងការផ្សព្វផ្សាយពត៌មាន និងនីតិវិធីទាក់ទងនឹងការជួញដូរមូលបត្រ។

# ឯកសារយោង

# ឯកសារយោង

## ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗដែលទាក់ទងនឹងវិស័យមូលបត្រ


១. ច្បាប់ពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, ១២ កញ្ញា ២០០៧

២. ច្បាប់ពីមូលបត្ររដ្ឋ, ២៥ វិច្ឆិកា ២០២០

៣. ប្រកាសស្តីពីការដាក់ឲ្យអនុវត្តវិធានប្រតិបត្តិការប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ, លេខ ០០៥/១១គ.ម.ក./ប្រ.ក.,០៣ ឧសភា ២០១១ ប្រការ៧

៤. គោលការណ៍ណែនាំស្តីពី នីតិនៃការទូទាត់សាច់ប្រាក់នៅក្នុងទីផ្សារមូលបត្រ, លេខ ០០៣/១២គ.ម.ក.ស.ជ.ណ.,១៤ កុម្ភៈ ២០១៤

៥. ប្រកាសស្តីពីការដាក់ឲ្យអនុវត្តវិធានប្រតិបត្តិការប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ, លេខ ០០៥/១១គ.ម.ក./ប្រ.ក.,០៣ ឧសភា ២០១១ ប្រការ៨

៦. ប្រកាសស្តីពីការដាក់ឲ្យអនុវត្តវិធានប្រតិបត្តិការប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ, លេខ ០០៥/១១គ.ម.ក./ប្រ.ក.,០៣ ឧសភា ២០១១ ប្រការ១០

៧. និយ័តករមូលបត្រកម្ពុជា, ២០១៩, ព្រឹត្តិបត្រទិន្នន័យជួញដូរមូលបត្រ ប្រចាំត្រីមាសទី១, ២, ៣, ៤

៨. និយ័តករមូលបត្រកម្ពុជា, ២០២០, ព្រឹត្តិបត្រទិន្នន័យជួញដូរមូលបត្រ ប្រចាំត្រីមាសទី១, ២, ៣, ៤

៩. ផ្សារមូលបត្រកម្ពុជា, ២០១៩, របាយការណ៍ស្ថិតិមូលបត្រកម្មសិទ្ធិ ប្រចាំត្រីមាសទី១, ២, ៣, ៤

១០. ផ្សារមូលបត្រកម្ពុជា, ២០២០, របាយការណ៍ស្ថិតិមូលបត្រកម្មសិទ្ធិ ប្រចាំត្រីមាសទី១, ២, ៣, ៤


## សៀវភៅ និងអត្ថបទផ្សេងៗ និងឯកសារស្រាវជ្រាវ


១១. ឡេង សុភក្រ្ត et al. (២០១៨), ស្ថាប័ន និង ទីផ្សារហិរញ្ញវត្ថុ, ទំព័រទី ៧១-៧២

១២. សុខ ពិសិដ្ឋ, ២០២០-២០២១, ទីផ្សារមូលបត្រកម្ពុជា

១៣. ហ៊ាង បុទម្យ និងហង់ ពិសី, «យន្តការជាត់ទាត់ និងទូទាត់មូលបត្រកម្មសិទ្ធិ», (និក្ខេបបទបរិញ្ញាបត្រ, សាកលវិទ្យាល័យ ភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច,២០១៤, ៤៧-៤៨)


## ឯកសារដកស្រង់ពីគេហទំព័រ


១៤. ធនាគារពិភពលោក (២០២១), ធនាគារពិភពលោកកម្ពុជា។ ដកស្រង់ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២១ ពីគេហទំព័រ: https://www.worldbank.org/en/country/cambodia/overview

១៥. B2B Cambodia (២០២១), ធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា។ ដកស្រង់ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២១ ពីគេហទំព័រ: https://www.b2b-cambodia.com/industry-overviews/banking-finance/

១៦. khemsaritheducation (២០១៨), ចូរឲ្យនិយមន័យទីផ្សារ។ ដកស្រង់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១

ពីគេហទំព័រ: https://khemsaritheducation.wordpress.com/2018/05/16/ចូរឲ្យនិយមន័យទីផ្សារ/
១៧. Investment (២០១១), ប្រវត្តិទីផ្សារមូលបត្រ។ ដកស្រង់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១
ពីគេហទំព័រ: http://siborann.blogspot.com/2011/09/blog-post_09.html
១៨. ខ្មែរប៉ុស្តិ៍ (២០២០), ស្វែងយល់ពីប្រវត្តិនៃ «ទីផ្សារមូលបត្រ»។ ដកស្រង់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១
ពីគេហទំព័រ: https://khmerpostasia.com/archives/62791
១៩. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (២០២១), មូលបត្រកម្មសិទ្ធិ។ ដកស្រង់ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២១
ពីគេហទំព័រ: http://csx.com.kh/kh/product/equities.jsp?MNCD=4020
២០. Investment (២០១១), ភាគហ៊ុនធម្មតា និងភាគហ៊ុនបុរិមា។ ដកស្រង់ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២១
ពីគេហទំព័រ: http://siborann.blogspot.com/2011/09/blog-post_8065.html?m=1
២១. និយ័តករមូលបត្រកម្ពុជា (២០២០), អន្តរការី ។ ដកស្រង់ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២១
ពីគេហទំព័រ: http://www.secc.gov.kh/khmer/m52.php?pn=6
២២. និយ័តករមូលបត្រកម្ពុជា (២០២០), សំនួរ-ចម្លើយ។ ដកស្រង់ថ្ងៃទី១៨ ខែមិថុនាឆ្នាំ២០២១
ពីគេហទំព័រ: http://www.secc.gov.kh/khmer/faq.php?pn=2
២៣. ភ្នំពេញ ប៉ុស្តិ៍ (២០២១), ទិដ្ឋភាពសំខាន់ៗនៃទីផ្សារមូលបត្រនៅកម្ពុជាត្រឹមឆ្នាំ ២០២០។ ដកស្រង់ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០២១ ពីគេហទំព័រ:
https://www.postkhmer.com/សេដ្ឋកិច្ច/ទិដ្ឋភាពសំខាន់នៃផ្សារមូលបត្រនៅកម្ពុជាត្រឹមឆ្នាំ-២០២០%
២៤. និយ័តករមូលបត្រកម្ពុជា (២០២០), ចក្ខុវិស័យ និងបេសកកម្ម។ ដកស្រង់ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២១
ពីគេហទំព័រ: http://www.secc.gov.kh/khmer/m11.php?pn=1
២៥. និយ័តករមូលបត្រកម្ពុជា (២០២០), ទំនាក់ទំនងមក ន.ម.ក.។ ដកស្រង់ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២១
ពីគេហទំព័រ: http://www.secc.gov.kh/khmer/m19.php?pn=1
២៦. និយ័តករមូលបត្រកម្ពុជា (២០២០), រូបសញ្ញារបស់ ន.ម.ក.។ ដកស្រង់ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២១
ពីគេហទំព័រ: http://www.secc.gov.kh/khmer/m17.php?pn=1
២៧. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (២០២១), ប្រវត្តិ ផ.ម.ក។ ដកស្រង់ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២១
ពីគេហទំព័រ: http://csx.com.kh/kh/about/profile.jsp?MNCD=10301
២៨. គេហទំព័រអង្គការទិន្នន័យអំពីការអភិវឌ្ឍ (២០២១), ផ្សារមូលបត្រ (ផ្សារភាគហ៊ុន)។
ដកស្រង់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១
ពីគេហទំព័រ: https://opendevelopmentcambodia.net/km/topics/securities-exchange-stock-market/

២៩. ពត៌មាន PNN (២០២១), ការជួញដូរភាគហ៊ុននៅក្នុងវិស័យមូលបត្រកម្ពុជា។
ដកស្រង់ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២១ ពីគេហទំព័រ: http://news.pnn.com.kh/news/5505

៣០. ភ្នំពេញប៉ុស្តិ៍ (២០២១), ទិដ្ឋភាពសំខាន់ៗនៃទីផ្សារមូលបត្រនៅកម្ពុជាត្រឹមឆ្នាំ ២០២០។
ដកស្រង់ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២១ ពីគេហទំព័រ: https://www.postkhmer.com/

៣១. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (២០២១), ចក្ខុវិស័យ និងបេសកកម្ម។
ដកស្រង់ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២១
ពីគេហទំព័រ: http://csx.com.kh/kh/about/mission.jsp?MNCD=1020

៣២. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (២០២១), ក្រុមប្រឹក្សាភិបាល ។ ដកស្រង់ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២១
ពីគេហទំព័រ: http://csx.com.kh/kh/about/director.jsp?MNCD=10303

៣៣. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (២០២១), ពត៌មានសម្រាប់ទំនាក់ទំនង។
ដកស្រង់ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១
ពីគេហទំព័រ: http://csx.com.kh/kh/about/contact.jsp?MNCD=10703

៣៤. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (២០២១), ទិដ្ឋភាពនៃការជួញដូរ។ ដកស្រង់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១
ពីគេហទំព័រ: http://csx.com.kh/operation/market/listPosts.do?MNCD=30201

៣៥. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (២០២១), ការជួញដូរភាគហ៊ុន។ ដកស្រង់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១
ពីគេហទំព័រ: http://csx.com.kh/operation/stock/listPosts.do?MNCD=30202

៣៦. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (២០២១), ការផាត់ទាត់ទូទាត់។ ដកស្រង់ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២១
ពីគេហទំព័រ: http://csx.com.kh/operation/clearing/listPosts.do?MNCD=3030

៣៧. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (២០២១), ការរក្សាទុកមូលបត្រ។ ដកស្រង់ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២១
ពីគេហទំព័រ: http://csx.com.kh/operation/depository/listPosts.do?MNCD=3040

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១៖

# ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

# ស្តីពី

# ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ឆ្នាំ ២០០៧

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ....................សហវ.....

# សារម្ភកថា

វិស័យមូលបត្រដែលជាវិស័យមួយដ៏ថ្មីស្រឡាង នឹងចាប់បដិសន្ធិឡើងក្នុងអនាគតដ៏ខ្លីខាងមុខ នឹងផ្តល់នូវសេវាកម្មហិរញ្ញវត្ថុ ដែលសេវាកម្មនេះនឹងបំពេញបន្ថែមទៅលើប្រព័ន្ធធនាគារ ដែលមានស្រាប់ក្នុងការកៀរគរមូលធន ព្រមទាំងពង្រីកមធ្យោបាយគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ និងធ្វើអោយប្រព័ន្ធហិរញ្ញវត្ថុរបស់ព្រះរាជាណាចក្រកម្ពុជា មានលក្ខណៈគ្រប់ជ្រុងជ្រោយ ដោយផ្តល់នូវជំរើសថ្មីមួយទៀតក្នុងការធ្វើហិរញ្ញប្បទានផ្ទាល់ដល់គំរោងវិនិយោគនានា ដែលជាកម្លាំងចលករនៃកំណើនសេដ្ឋកិច្ច ។

វិស័យមូលបត្រ និងវិស័យធនាគារ ជាវិស័យពីរដែលដំណើរការដោយបំពេញឱ្យគ្នាទៅវិញទៅមកក្នុងការអភិវឌ្ឍន៍និងការពង្រឹងប្រព័ន្ធហិរញ្ញវត្ថុទាំងមូល របស់ព្រះរាជាណាចក្រកម្ពុជា ឱ្យកាន់តែមានប្រសិទ្ធភាព ដើម្បីជម្រុញការអភិវឌ្ឍន៍សេដ្ឋកិច្ចផង និងដើម្បីធានាការប្រកួតប្រជែងរបស់ព្រះរាជាណាចក្រកម្ពុជា ក្នុងបរិការណ៍សកលភាវូបនីយកម្មផង ។ ឯកសារ «ចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ ២០០១-២០១០» របស់រាជរដ្ឋាភិបាល ដែលត្រូវបានធ្វើបច្ចុប្បន្នកម្មទៅជា «**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ ២០០៦-២០១៥**» បានកំណត់នូវគោលដៅរយៈពេលវែងមួយ ដែលទ្រទ្រង់ដល់ការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុអោយរឹងមាំ ដោយផ្អែកលើយន្តការទីផ្សារ ដើម្បីគាំទ្រប្រកបដោយសមធម៌និងចីរភាព នូវការកេណ្ឌប្រមូលធនធាន នូវការបែងចែកធនធានហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព និងនូវកំណើនសេដ្ឋកិច្ចដែលត្រូវមានមូលដ្ឋានធំទូលាយ និងរឹងមាំ ។ នៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុនេះ អាទិភាពចំពោះមុខសម្រាប់ការអភិវឌ្ឍទីផ្សារមូលបត្រ គឺការអនុម័តច្បាប់គោលស្តីពី «**ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន**» និងការលើកកម្ពស់ការយល់ដឹងរបស់សាធារណជន ក៏ដូចជាការអប់រំតួអង្គដែលប្រុងហក់ចូលក្នុងទីផ្សារមូលបត្រនេះ ។ ច្បាប់នេះជាហេដ្ឋារចនាសម្ព័ន្ធចាំបាច់ សំរាប់ទ្រទ្រង់ដល់ការអភិវឌ្ឍទីផ្សារមូលបត្រឱ្យមានដំណើរការល្អ ពោលគឺបង្កើតនូវបរិស្ថានទីផ្សារហិរញ្ញវត្ថុដែលមានសុវត្ថិភាព និងប្រសិទ្ធភាព។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

សេចក្តីព្រាងច្បាប់ស្តីពី «**ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន**» ត្រូវបានរៀបចំតាក់តែងឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ កិច្ចដំណើរការនៃការរៀបចំសេចក្តីព្រាងច្បាប់នេះ បានឆ្លងកាត់ការពិភាក្សាពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍មកពីផ្នែកឯកជន ជាមួយក្រសួងនិងស្ថាប័នពាក់ព័ន្ធ តាមរយៈការធ្វើសិក្ខាសាលាជាច្រើនលើក និងដៃគូរអភិវឌ្ឍន៍ផ្លូវការដូចជាធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ជាដើម ហើយក៏បានដកស្រង់យកបទពិសោធន៍ និងវិធានល្អៗនៃការអនុវត្តក្នុងវិស័យមូលបត្រពីបណ្តាប្រទេសនានាជាពិសេស ប្រទេសនៅអាស៊ាន ដោយផ្អែកលើគោលការណ៍របស់អង្គការអន្តរជាតិនៃគណៈកម្មការមូលបត្រ (International Organization of Securities Commissions-IOSCO) ដើម្បីដាក់បញ្ចូលក្នុងច្បាប់នេះ ស្របតាមស្ថានភាពគតិយុត្តិរបស់ព្រះរាជាណាចក្រកម្ពុជា។

ច្បាប់ស្តីពី «**ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន**» នេះ ត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៧ ។

ច្បាប់នេះ មានគោលដៅគ្រប់គ្រងប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់ ប្រតិបត្តិកររក្សាទុកមូលបត្រ និងប្រតិបត្តិករដទៃទៀតនៅក្នុងទីផ្សារមូលបត្រ ដែលធ្វើការជួញដូរឬផ្តល់សេវាកម្មមូលបត្រ ព្រមទាំងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកំរិត ឬនីតិបុគ្គលប្រតិស្រុតិ ដែលបោះផ្សាយលក់មូលបត្រមហាជន ។

ដូចគ្នានឹងមូលបត្ររដ្ឋដែរ (**ច្បាប់ស្តីពី មូលបត្ររដ្ឋ**) មូលបត្រមហាជនគឺជាការដ្ឋានថ្មីមួយនៅក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល ។ អាទិភាពចំពោះមុខជាច្រើនត្រូវបាន និងកំពុងអនុវត្តនិងដោះស្រាយ សម្រាប់ភាពជោគជ័យនៃការបង្កើតទីផ្សារមូលបត្រនៅកម្ពុជា ក្នុងនោះការផ្សព្វផ្សាយច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងមូលបត្រ ក៏ជាអាទិភាពចាំបាច់មួយដែរ។ ការបោះពុម្ពផ្សាយច្បាប់ស្តីពី «**ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន**» នៅពេលនេះ គឺមិនត្រឹមតែជាការផ្សព្វផ្សាយអំពីក្របខ័ណ្ឌគ្រប់គ្រងទីផ្សារមូលបត្រប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាការជម្រុញសាធារណជនឱ្យមានការយកចិត្តទុកដាក់ និងលើកកម្ពស់ចំណេះដឹងអំពីកិច្ចដំណើរការរបស់ទីផ្សារមូលបត្រ និងជម្រុញឱ្យមានការចូលរួមកាន់តែទូលំទូលាយក្នុងទីផ្សារមូលបត្រនៅកម្ពុជា ដែលគ្រោងនឹងបង្កើតឡើងក្នុង ឆ្នាំ ២០០៩ ខាងមុខនេះ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានជំនឿយ៉ាងមុតមាំថា ច្បាប់ស្តីពី «**ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន**» ដែលបោះពុម្ពផ្សាយទៅនេះ នឹងក្លាយជាឧបករណ៍ដ៏មានប្រយោជន៍ដល់អនាគតអ្នកចូលរួមក្នុងទីផ្សារ ក៏ដូចមជ្ឈដ្ឋានអាការដេម៉ិក និងសាធារណជនទូទៅ ក្នុងការបង្កើនការ

យល់ដឹងរបស់ខ្លួនឱ្យបានស៊ីជម្រៅ អំពីគោលការណ៍សំខាន់ៗពាក់ព័ន្ធនឹងប្រតិបត្តិការទីផ្សារមូលបត្រ នៅកម្ពុជា ។

រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងឋានៈជាប្រធាន **គណៈកម្មការមូលបត្រកម្ពុជា** (Cambodia Securities and Exchange Commission) មានភារកិច្ចធានាអោយបាននូវ អភិបាលកិច្ចល្អ ទាំងរបស់ក្រុមហ៊ុន ទាំងរបស់ស្ថាប័នរដ្ឋ ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលកំពុងកសាងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមរយៈការដ្ឋាន **«កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០០៥-២០១៥»** (Public Financial Management Reform Program-PFM) អោយបានឈានដល់កំរិតស្តង់ដារអន្តរជាតិ ដែលក្នុងនោះមានទាំងគណនេយ្យភាពហិរញ្ញវត្ថុ និងទាំងគណនេយ្យភាពចំពោះលទ្ធផល គឺកំពុងប្រឹងប្រែងជំរុញគ្រប់សហគ្រាសអនុវត្តច្បាប់ស្តីពី «គណនេយ្យសហគ្រាស សវនកម្មគណនេយ្យ សហគ្រាសនិងវិជ្ជាជីវៈគណនេយ្យ» ពីព្រោះក្រុមហ៊ុនទាំងនេះ អាចក្លាយជាតួអង្គប្រតិបត្តិការនៃផ្សារមូលបត្រ ។

កិច្ចខិតខំប្រឹងប្រែងនេះ ជាផ្នែកមួយនៃការគ្រប់គ្រងហិរញ្ញវត្ថុអោយបានគ្រប់ជ្រុងជ្រោយ ក្នុងគោលបំណងកសាងភាពប្រណាំងប្រជែងរបស់ព្រះរាជាណាចក្រកម្ពុជា ក្នុងបរិការណ៍សកលភាវូបនីយកម្ម ។ យ៉ាងណាមិញ ទីផ្សារមូលបត្រមានចំណងស្អិតរមួតរវាង **ហិរញ្ញវត្ថុឯកជន-ជាតិ ហិរញ្ញវត្ថុឯកជន-អន្តរជាតិ** និង **ហិរញ្ញវត្ថុសាធារណៈ-អន្តរជាតិ** ក៏ដូចជា**ហិរញ្ញវត្ថុសាធារណៈ-ជាតិ**ដែរ តាមរយៈការបោះផ្សាយលក់មូលបត្ររដ្ឋ ។ ដូច្នេះក្នុងការប្រឹងប្រែង រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាប្រធាននៃ **គណៈកម្មការមូលបត្រកម្ពុជា** ត្រូវមានចក្ខុវិស័យ គោលនយោបាយ យុទ្ធសាស្ត្រ និងដឹកនាំការសំរេចផែនការគ្រប់ជ្រុងជ្រោយ ទើបសំរេចបានទីផ្សារមូលបត្រមួយប្រកបដោយប្រសិទ្ធភាព ហើយនាំផលចំណេញដល់ព្រះរាជាណាចក្រកម្ពុជា ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៧*

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**អំពីកិច្ចដំណើរការកសាង**

**សេចក្តីព្រាងច្បាប់ស្តីពី «ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន»**

**ក. សេចក្តីព្រាងច្បាប់នេះត្រូវបានពិនិត្យ និងកែសម្រួលដោយៈ**

១. ឯកឧត្តម **គាត ឈន់** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

២. ឯកឧត្តម បណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានឧត្តមក្រុមប្រឹក្សា សេដ្ឋកិច្ចជាតិ

៣. ឯកឧត្តម **ជាវ ម៉េងឈាង** រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៤. ឯកឧត្តម បណ្ឌិត **ហង់ ជួនណារ៉ុន** អគ្គលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ខ. សមាសភាពនៃក្រុមការងារតាក់តែងសេចក្តីព្រាងច្បាប់ៈ**

១. លោក **ម៉ី ទាន់** ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

២. បណ្ឌិត **ម៉ិញ បានកុសល** អនុប្រធានទី ១ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៣. លោក **កៅ ថាច** ប្រធានការិយាល័យទីផ្សារហិរញ្ញវត្ថុ នៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ

៤. លោក **ឌឹង ចន្ថា** អនុប្រធានការិយាល័យទីផ្សារហិរញ្ញវត្ថុនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ

៥. បណ្ឌិត **ហួត ពុំ** អនុប្រធានការិយាល័យទីផ្សារហិរញ្ញវត្ថុ នៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ

៦. លោក **ទាវ សុទី** មន្ត្រីជំនាញការិយាល័យទីផ្សារហិរញ្ញវត្ថុ នៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ

**គ. អំពីការអនុម័តសេចក្តីព្រាងច្បាប់**

- សេចក្តីព្រាងច្បាប់នេះត្រូវបានអនុម័តដោយអង្គប្រជុំគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៧
- សេចក្តីព្រាងច្បាប់នេះត្រូវបានអនុម័តដោយរដ្ឋសភានៅថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០៧
- អត្ថបទច្បាប់នេះត្រូវបានព្រឹទ្ធសភា ពិនិត្យ និងយល់ព្រមស្របតាមទម្រង់ និងគតិច្បាប់ នៅថ្ងៃទី ៤ ខែ តុលា ឆ្នាំ ២០០៧
- ច្បាប់នេះ ត្រូវបានប្រកាសអោយប្រើប្រាស់ដោយ ព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៧ ។

# ព្រះរាជក្រម

នស/រកម/០១០៧/០២៨

# យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៧ នាសម័យប្រជុំវិសាមញ្ញរបស់រដ្ឋសភានីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំវិសាមញ្ញរបស់ព្រឹទ្ធសភា ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់

# ស្ដីពី

# ការបោះផ្សាយ

# និង

# ការជួញដូរមូលបត្រមហាជន

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.- គោលដៅ**

ច្បាប់នេះមានគោលដៅគ្រប់គ្រងទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់ ប្រតិបត្តិកររក្សាទុកមូលបត្រ និងប្រតិបត្តិករដទៃទៀតនៅក្នុងទីផ្សារមូលបត្រដែលធ្វើការជួញដូរ ឬផ្តល់សេវាកម្មហិរញ្ញវត្ថុ ព្រមទាំងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិ-បុគ្គលប្រតិស្រុតដែលបោះផ្សាយលក់មូលបត្រ។ ច្បាប់នេះរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គម តាមរយៈការកៀរគរមូលធនពីសាធារណជន ឬអ្នកវិនិយោគមូលបត្រ ដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុ សម្រាប់ការវិនិយោគ។

**មាត្រា ២.- គោលបំណង**

ច្បាប់នេះមានគោលបំណង :

១-បង្កើត និងរក្សាឱ្យមានទំនុកចិត្តពីអ្នកវិនិយោគ នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការការពារសិទ្ធិស្របច្បាប់របស់អ្នកវិនិយោគ និងធានាឱ្យមានការបោះ-ផ្សាយ និងការជួញដូរមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវ។

២-លើកកម្ពស់ការគ្រប់គ្រងទីផ្សារមូលបត្រឱ្យមានប្រសិទ្ធភាព និងជម្រុញការអភិវឌ្ឍទីផ្សារនេះឱ្យមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយ។

៣-ជម្រុញឱ្យមានភាពសម្បូរបែបនៃឧបករណ៍សញ្ជ័យ តាមរយៈការទិញមូល-បត្រ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត។

៤-ជំរុញឱ្យមានការធ្វើវិនិយោគទុនពីបរទេស និងការចូលរួមក្នុងទីផ្សារមូល-បត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៥-ជួយសម្រួលដល់ការធ្វើឯកជនភាវូបនីយកម្ម សហគ្រាសសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៣.- វិសាលភាព**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះរាល់ប្រតិបត្តិការមូលបត្រមហាជននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៤.- និយមន័យ**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងច្បាប់នេះត្រូវបានកំណត់ដោយសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

## ជំពូកទី ២

## គណៈកម្មការមូលបត្រកម្ពុជា

**មាត្រា ៥.- អាណត្តិរបស់គណៈកម្មការមូលបត្រកម្ពុជា**

គណៈកម្មការមូលបត្រកម្ពុជា (សរសេរកាត់ថា **គ.ម.ក.**) ត្រូវបានបង្កើតឡើងដោយច្បាប់នេះ ដែលមានប្រធាន ១(មួយ)រូប និងសមាជិកចំនួន ៨(ប្រាំបី)រូប ដែលតែងតាំងដោយអនុក្រឹត្យ។ សមាជិករបស់ **គ.ម.ក.** មានអាណត្តិ ៥(ប្រាំ)ឆ្នាំ។ ក្នុងរយៈពេលនៃការបំពេញមុខងាររបស់ខ្លួន សមាជិកអាចត្រូវបានដកហូត ឬផ្លាស់ប្ដូរភារកិច្ច។ សមាជិក **គ.ម.ក.** អាចត្រូវបានតែងតាំងសារជាថ្មីទៀតបាន តាមសំណើរបស់ប្រធាន **គ.ម.ក.** នៅពេលផុតអាណត្តិ។

**មាត្រា ៦.- សមាសភាពរបស់គណៈកម្មការមូលបត្រកម្ពុជា**

ប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា ជារដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ សមាសភាពរបស់ **គ.ម.ក.** មាន :

១- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១ (មួយ)រូប

២- តំណាងធនាគារជាតិនៃកម្ពុជា ០១ (មួយ)រូប

៣- តំណាងក្រសួងពាណិជ្ជកម្ម ០១ (មួយ)រូប

៤- តំណាងក្រសួងយុត្តិធម៌ ០១ (មួយ)រូប

៥- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ០១ (មួយ)រូប

៦- អគ្គនាយក **គ.ម.ក.** ០១ (មួយ)រូប

៧- អ្នកជំនាញដែលមានបទពិសោធន៍វិស័យមូលបត្រ ០២(ពីរ)រូប ដែលមានស្ថានភាពអព្យាក្រឹត្យ ព្រមទាំងជ្រើសរើស និងស្នើឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

បេក្ខភាពរបស់អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ត្រូវជ្រើសរើស និងស្នើឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជូនប្រមុខរាជរដ្ឋាភិបាល។ សមាជិកនៃ **គ.ម.ក.** ដែលជាអ្នកជំនាញ ត្រូវមានសញ្ញាបត្រថ្នាក់ក្រោយឧត្តមសិក្សា មានសមត្ថភាព និងលក្ខណសម្បត្តិគ្រប់គ្រាន់ និង សមស្របក្នុងការបំពេញភារកិច្ចរបស់ខ្លួនព្រមទាំងមានបទពិសោធន៍មួយ ឬ ច្រើនផ្នែក ដូចជាពាណិជ្ជកម្មគ្រប់គ្រងក្រុមហ៊ុនទីផ្សារមូលបត្រ ច្បាប់ សេដ្ឋកិច្ច គណនេយ្យ និងផ្នែកផ្សេងទៀតតាមតម្រូវការជាក់ស្តែង។

**មាត្រា ៧.- មុខងាររបស់គណៈកម្មការមូលបត្រកម្ពុជា**

គណៈកម្មការមូលបត្រកម្ពុជា មានមុខងារដូចខាងក្រោម :

១-គ្រប់គ្រង និងត្រួតពិនិត្យទីផ្សារមូលបត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជារួមទាំងទីផ្សារមូលបត្ររដ្ឋ។

២-ដាក់ឱ្យអនុវត្តនូវគោលនយោបាយ ដែលពាក់ព័ន្ធនឹងទីផ្សារមូលបត្រ។

៣-កំណត់លក្ខខណ្ឌ ដើម្បីផ្តល់ការអនុញ្ញាត ជូនប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ។

៤-កំណត់លក្ខខណ្ឌដើម្បីផ្តល់អាជ្ញាប័ណ្ណជូនក្រុមហ៊ុនមូលបត្រ និង ភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ។

៥-លើកកម្ពស់ និងជម្រុញដល់ការគោរពតាមលក្ខខណ្ឌនៃច្បាប់នេះ។

៦-ដើរតួជាស្ថាប័នពិនិត្យ និងដោះស្រាយលើការតវ៉ាចំពោះសេចក្តីសម្រេចរបស់

នីតិបុគ្គលមានអាជ្ញាប័ណ្ណ ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់សមាជិកអ្នកចូលរួម ឬអ្នកវិនិយោគ។

៧-ពិគ្រោះយោបល់ជាមួយបុគ្គល ដែលមានលក្ខណសម្បត្តិសមស្រប ដើម្បីបង្កើតគោលនយោបាយសម្រាប់ការអភិវឌ្ឍទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៨-បំពេញការងារផ្សេងទៀតដែលមានចែងនៅក្នុងអនុក្រឹត្យ។

**មាត្រា ៨.- មុខងាររបស់អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា**

អគ្គនាយកនៃ **គ.ម.ក.** មានមុខងារដូចខាងក្រោម :

១-គ្រប់គ្រងបុគ្គលិក និងមន្ត្រីជំនាញដែលទទួលបន្ទុកសម្របសម្រួលកិច្ចការរដ្ឋបាលរបស់ **គ.ម.ក.** ក្នុងការគ្រប់គ្រងការអភិវឌ្ឍ និងការត្រួតពិនិត្យទីផ្សារមូលបត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២-រាយការណ៍និងផ្តល់អនុសាសន៍ជូនប្រធាននិងសមាជិកទាំងអស់នៃ **គ.ម.ក.** នូវរាល់បញ្ហាទាំងអស់ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងការអភិវឌ្ឍ និងការត្រួតពិនិត្យទីផ្សារមូល-បត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមទាំងការលើកសំណើសុំធ្វើវិសោធនកម្មច្បាប់ និងបទ-ប្បញ្ញត្តិផ្សេងៗ។

៣-ពិនិត្យសំណុំឯកសារ ដែលស្នើសុំធ្វើសំណើលក់មូលបត្រជាសាធារណៈ និងផ្តល់ការអនុញ្ញាតលើពាក្យស្នើសុំ ដែលបានបំពេញតាមលក្ខខណ្ឌនៃច្បាប់ និងបទប្បញ្ញត្តិផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក.**។

៤-ពិនិត្យឯកសារផ្តល់ព័ត៌មាន ដែលទាក់ទងនឹងសំណើដាក់លក់មូលបត្រមហាជនដែលដាក់មក **គ.ម.ក.** ដើម្បីធានានូវការគោរពតាមលក្ខខណ្ឌនៃច្បាប់នេះ និងបញ្ញត្តិនានានៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដោយផ្តល់ការអនុញ្ញាត និងចុះបញ្ជីឯកសារដែលបំពេញតាមលក្ខខណ្ឌត្រឹមត្រូវ។

៥-ត្រួតពិនិត្យឯកសារផ្តល់ព័ត៌មានជាប្រចាំ ដែលផ្តល់ជូនទីផ្សារមូលបត្រនូវ

ព័ត៌មានហិរញ្ញវត្ថុ ព័ត៌មានមិនមែនហិរញ្ញវត្ថុ និងព័ត៌មានផ្សេងទៀតរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និងនីតិបុគ្គលប្រតិស្រុត ដែលបោះផ្សាយលក់មូលបត្រជូនអ្នកវិនិយោគសាធារណៈ។

៦-ត្រួតពិនិត្យការអនុវត្តច្បាប់របស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និងនីតិបុគ្គលប្រតិស្រុត ដែលបោះផ្សាយលក់មូលបត្រជូនអ្នកវិនិយោគសាធារណៈ ដោយគោរពតាមលក្ខខណ្ឌទាំងឡាយដែលច្បាប់តម្រូវ និងចាត់វិធានការអនុវត្តសមស្របណាមួយ ចំពោះអំពើល្មើសនឹងច្បាប់នេះ។

៧-ទាក់ទងនឹងទីផ្សារមូលបត្រ ប្រព័ន្ធផាត់ទាត់និងទូទាត់ និងសេវារក្សាទុកមូលបត្រ អគ្គនាយក **គ.ម.ក.** ត្រូវ :

ក-ពិនិត្យ និងពិនិត្យឡើងវិញលើពាក្យស្នើសុំអាជ្ញាប័ណ្ណ និងផ្តល់ការអនុញ្ញាត នៅពេលដែលអ្នកស្នើសុំបំពេញតាមលក្ខខណ្ឌនៃច្បាប់នេះ និងលក្ខខណ្ឌផ្សេងទៀតដែល **គ.ម.ក.** បានកំណត់។

ខ-ពិនិត្យ និងពិនិត្យឡើងវិញ និងផ្តល់ការអនុញ្ញាតឱ្យធ្វើការកែប្រែលើវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធផាត់ទាត់និងទូទាត់ និងសេវារក្សាទុកមូលបត្រ ដែលទទួលបានការអនុញ្ញាត។

គ-ត្រួតពិនិត្យសកម្មភាពរបស់ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រដើម្បីធានាការគោរពតាមលក្ខខណ្ឌនៃការផ្តល់ការអនុញ្ញាត និងលក្ខខណ្ឌនៃច្បាប់នេះ និងលក្ខខណ្ឌផ្សេងទៀតដែល **គ.ម.ក.** បានកំណត់។

ឃ-ធ្វើការស៊ើបអង្កេតករណីសង្ស័យ ចំពោះអំពើល្មើសរបស់បុគ្គលដែលទទួលបានការអនុញ្ញាតទៅនឹងលក្ខខណ្ឌនៃការផ្តល់ការអនុញ្ញាត ឬ លក្ខខណ្ឌដែលច្បាប់តម្រូវ និងចាត់វិធានការអនុវត្តសមស្របណាមួយរួមមានការព្យួរ ឬការដកហូតការអនុញ្ញាត។

ង-មុនផ្តល់ការអនុញ្ញាត ឬដកហូតការអនុញ្ញាត អគ្គនាយកត្រូវសុំការ

ពិគ្រោះយោបល់ ពីការប្រជុំពេញអង្គរបស់ **គ.ម.ក.**។

៨-ទាក់ទងនឹងក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ អគ្គនាយកនៃ **គ.ម.ក.** ត្រូវ :

ក-ពិនិត្យពាក្យស្នើសុំអាជ្ញាប័ណ្ណ និងផ្តល់អាជ្ញាប័ណ្ណ ប្រសិនបើអ្នកស្នើសុំបានបំពេញតាមលក្ខខណ្ឌនៃច្បាប់នេះ និងលក្ខខណ្ឌផ្សេងទៀតដែល **គ.ម.ក.** បានកំណត់។

ខ-ត្រួតពិនិត្យសកម្មភាពរបស់អ្នកកាន់អាជ្ញាប័ណ្ណ ក្នុងការគោរពតាមលក្ខខណ្ឌនៃអាជ្ញាប័ណ្ណ រួមទាំងលក្ខខណ្ឌហិរញ្ញវត្ថុ។

គ-ត្រួតពិនិត្យការគោរពតាមលក្ខខណ្ឌ នៃអាជីវកម្មដែលកំណត់ក្នុងច្បាប់នេះ និងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។

ឃ-ពិនិត្យដើម្បីផ្តល់ការអនុញ្ញាត ចំពោះការស្នើសុំឱ្យក្លាយទៅជាស្វ័យនិយ័តករចំពោះពាណិជ្ជករមូលបត្រ ឬទីប្រឹក្សាវិនិយោគ ប្រសិនបើអ្នកស្នើសុំនោះបានគោរពតាមលក្ខខណ្ឌដែលបានកំណត់។

ង-ត្រួតពិនិត្យការអនុវត្តតាមលក្ខខណ្ឌ នៃច្បាប់របស់ស្វ័យនិយ័តករដែលបានការអនុញ្ញាត។

ច-ធ្វើការស៊ើបអង្កេតករណីសង្ស័យ ចំពោះអំពើល្មើសនឹងលក្ខខណ្ឌនៃអាជ្ញាប័ណ្ណ ឬនៃការអនុញ្ញាត ឬអំពើល្មើសនឹងលក្ខខណ្ឌនៃច្បាប់នេះរបស់អ្នកកាន់អាជ្ញាប័ណ្ណ និងចាត់វិធានការអនុវត្តសមស្របណាមួយ ដូចជា ព្យួរ ឬដកហូតអាជ្ញាប័ណ្ណ ឬការអនុញ្ញាត។

៩-ចាត់វាល់វិធានការសមស្រប ដែលច្បាប់នេះអនុញ្ញាតដើម្បីអង្កេតស្វែងរក និងបង្ក្រាបអាជីវកម្មខុសច្បាប់ ផ្ទុយនឹងក្រមសីលធម៌ និងអំពើមិនសមស្រប ដែលពាក់ព័ន្ធនឹងអាជីវកម្មមូលបត្រ។

### មាត្រា ៩.- សិទ្ធិអំណាចរបស់អគ្គនាយកក្នុងការគ្រប់គ្រង គ.ម.ក

ក្នុងគោលបំណងអនុវត្តតាមមុខងារដែលមានចែងក្នុងច្បាប់នេះ អគ្គនាយកនៃ **គ.ម.ក.** មានសិទ្ធិអំណាចដូចខាងក្រោម :

១-ផ្តល់សិទ្ធអំណាចទៅបុគ្គលិករបស់ **គ.ម.ក.** ឬផ្តល់សិទ្ធអំណាចទៅបុគ្គលផ្សេងទៀត ដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមុន។

២-ក្នុងករណីអគ្គនាយកនៃ **គ.ម.ក.** មានមូលហេតុត្រឹមត្រូវ ហើយជឿជាក់ថាបទល្មើសត្រូវបានប្រព្រឹត្តនៅក្រោមច្បាប់នេះ អគ្គនាយកនៃ **គ.ម.ក.** អាចសម្រេចឱ្យបុគ្គលិករបស់ខ្លួនធ្វើការស៊ើបអង្កេតលើ :

ក-បុគ្គលដែលទទួលបានអាជ្ញាប័ណ្ណ ឬ ទទួលបានការអនុញ្ញាត។

ខ-បុគ្គលដែលធ្វើសំណើលក់មូលបត្រជាសាធារណៈ។

គ-ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលមានមូលបត្រដាក់លក់ ឬ ដាក់តម្លៃនៅក្នុងទីផ្សារមូលបត្រ។

ឃ-បុគ្គលផ្សេងទៀតតាមការជាក់ស្តែង។

៣-ប្រមូលភស្តុតាងពីបុគ្គលដែលស្ថិតក្រោមការស៊ើបអង្កេត។

៤-រាយការណ៍ជាបន្ទាន់អំពីលទ្ធផលនៃការស៊ើបអង្កេតជូនប្រធាន និងសមាជិកទាំងអស់នៃ **គ.ម.ក.** ដោយភ្ជាប់មកជាមួយនូវអនុសាសន៍ ដើម្បីចាត់វិធានការអនុវត្តបន្ត។

៥-បញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ដើម្បីធ្វើការចោទប្រកាន់ពីបទល្មើស។

៦-ធ្វើការអង្កេតលើរាល់សកម្មភាពទីផ្សារមូលបត្រប្រតិស្រុត។

៧-ផ្សព្វផ្សាយឈ្មោះ និងសកម្មភាពរបស់បុគ្គលដែលមានពិរុទ្ធភាពពីបទល្មើសដែលមានចែងក្នុងច្បាប់នេះ ឬ ដែលទទួលទណ្ឌកម្មខាងវិន័យពី **គ.ម.ក.**។

៨-ដកហូត ឬព្យួរអាជ្ញាប័ណ្ណ ការអនុញ្ញាត ឬការចុះបញ្ជីដែលបានផ្តល់ឱ្យ។

៩-សិទ្ធិមួយចំនួនទៀតស្របតាមមាត្រា ៤៥ នៃច្បាប់នេះ។

**មាត្រា ១០.- សិទ្ធិពិសេសរបស់ គ.ម.ក.**

មន្ត្រីរបស់ **គ.ម.ក.** ទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ មានមុខងារដូចមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌស្តីពីមុខងាររបស់នគរបាលយុត្តិធម៌។

**មាត្រា ១១.- ការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ម.ក.**

ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា ត្រូវកំណត់ដោយអនុក្រឹត្យ។ **គ.ម.ក.** ត្រូវមានថវិកាសម្រាប់ចំណាយផ្ទាល់ខ្លួនដាច់ដោយឡែក។

## ជំពូកទី ៣
## សំណើលក់មូលបត្រ និង ការបោះផ្សាយមូលបត្រ

**មាត្រា ១២.- ការបោះផ្សាយ និងលក់មូលបត្រ**

គ្មានបុគ្គលណាមួយបោះផ្សាយ និងលក់មូលបត្រជាសាធារណៈបានទេ លើកលែងតែបុគ្គលនោះទទួលបានការអនុញ្ញាតពី **គ.ម.ក.** ដោយអនុលោមតាមច្បាប់ និងលក្ខខណ្ឌផ្សេងៗ ដែលកំណត់ដោយ **គ.ម.ក.**។ បុគ្គលនោះត្រូវបង់ថ្លៃសេវានៃការដាក់ពាក្យស្នើសុំ ដែលកំណត់ឡើងស្របតាមច្បាប់នេះ។

**មាត្រា ១៣.- ការពិនិត្យលើពាក្យស្នើសុំបោះផ្សាយ និងលក់មូលបត្រ**

អគ្គនាយកនៃ **គ.ម.ក.** ត្រូវពិនិត្យរាល់ពាក្យស្នើសុំ ដូចមានចែងក្នុងមាត្រា ១២ នៃច្បាប់នេះ និងជូនដំណឹងដល់បុគ្គលដែលបានដាក់ពាក្យស្នើសុំនោះ អំពីភាពសមស្រប ឬមិនសមស្រប នៃសំណើនោះជាមួយនឹងផលប្រយោជន៍សាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេលយ៉ាងយូរ ៣(បី) ខែ គិតចាប់ពីថ្ងៃដាក់ពាក្យស្នើសុំ។

**មាត្រា ១៤.- លក្ខខណ្ឌនៃពាក្យស្នើសុំបោះផ្សាយ និងលក់មូលបត្រ**

ដើម្បីសម្រេចថា ពាក្យស្នើសុំមួយមានភាពសមស្រប ឬមិនសមស្របនឹងផលប្រយោជន៍សាធារណៈនៃព្រះរាជាណាចក្រកម្ពុជា អគ្គនាយកនៃ **គ.ម.ក.** ត្រូវតែពិចារណាលើ :

១-គុណភាពនៃអភិបាលកិច្ច និង ប្រវត្តិហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ។

២-តម្រូវការរបស់ទីផ្សារមូលបត្រ រួមទាំងតម្រូវការដើម្បីអភិវឌ្ឍទីផ្សារមូលបត្រ។

៣-កត្តាជោគជ័យនៃសំណើបោះផ្សាយ និងលក់មូលបត្រជាសាធារណៈ រួមទាំង

អត្ថិភាពនៃកិច្ចសន្យាធានាទិញ ឬគម្រោងចុះកិច្ចសន្យាធានាទិញដែលនឹងធានាថា រាល់មូល-បត្រទាំងអស់ដែលប្រកាសលក់ក្នុងក្របខ័ណ្ឌនៃសំណើលក់ជាសាធារណៈនោះ អាចបោះផ្សាយបាន ឬ អាចលក់អស់។

៤-លក្ខខណ្ឌតម្រូវក្នុងការចុះបញ្ជីដើម្បីលក់នៅទីផ្សារមូលបត្រ។

៥-លក្ខខណ្ឌផ្សេងៗ តម្រូវក្នុងការផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មានឱ្យស្របតាមជំពូកនេះ។

៦-បញ្ហាផ្សេងៗទៀត ដែលអគ្គនាយកនៃ **គ.ម.ក.** ពិនិត្យឃើញថាមានលក្ខណៈសមស្របក្នុងការការពារផលប្រយោជន៍សាធារណៈ។

## មាត្រា ១៥.- ការយល់ព្រមលើសំណើបោះផ្សាយ និងលក់មូលបត្រ

ប្រសិនបើ **គ.ម.ក.** យល់ព្រមលើសំណើបោះផ្សាយ និងលក់មូលបត្រ ដែលដាក់ជូនតាមមាត្រា ១២ នៃច្បាប់នេះ បុគ្គលដែលធ្វើសំណើនោះអាចចាប់ផ្តើមធ្វើសំណើបោះផ្សាយ និងលក់មូលបត្រជាសាធារណៈ ដោយអនុលោមតាមច្បាប់នេះ។

## មាត្រា ១៦.- ការដាក់លក់មូលបត្រជាសាធារណៈ

គ្មានបុគ្គលណាមួយធ្វើសំណើលក់មូលបត្រជាសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជាបានទេ លើកលែងតែសំណើលក់នោះធ្វើឡើងដោយគោរពតាមលក្ខខណ្ឌខាងក្រោម ៖

១-មូលបត្រដែលធ្វើសំណើលក់នោះ ត្រូវបោះផ្សាយដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលបានចុះបញ្ជីពាណិជ្ជកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដោយនីតិបុគ្គលប្រតិស្រុតដែលត្រូវបានកំណត់ស្របតាមច្បាប់ និងលិខិតបទដ្ឋានជាធរមាន។

២-រាល់លក្ខខណ្ឌនៃការស្នើសុំលក់ និងឯកសារផ្តល់ព័ត៌មានដែលត្រូវបំពេញតាមលក្ខខណ្ឌនៃច្បាប់នេះ និងលក្ខខណ្ឌដទៃទៀតដែលត្រូវបានកំណត់ស្របតាមច្បាប់នេះ ត្រូវតែទទួលបានការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **គ.ម.ក.** លើកលែងតែការដាក់លក់នោះ គឺជាការដាក់លក់មូលបត្រអញ្ញត្រកម្មដូចមានចែងក្នុងអនុក្រឹត្យ ដោយអនុលោមតាមច្បាប់

នេះ។ ចំពោះឯកសារផ្តល់ព័ត៌មានត្រូវតែចុះបញ្ជីនៅ **គ.ម.ក.**។

**មាត្រា ១៧.- បែបបទនៃការដាក់លក់មូលបត្រ និងការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន**

បុគ្គលណាដែលស្នើសុំធ្វើសំណើលក់មូលបត្រជាសាធារណៈត្រូវដាក់ពាក្យសុំការអនុញ្ញាតធ្វើសំណើលក់នោះ និង សុំការអនុញ្ញាតចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ដែលទាក់ទងទៅនឹងសំណើលក់ទៅ **គ.ម.ក.**។ បុគ្គលស្នើសុំត្រូវ :

១-ដាក់ពាក្យសុំមួយច្បាប់តាមទម្រង់កំណត់ ដែលរួមមានលក្ខខណ្ឌនៃសំណើលក់ជាសាធារណៈនៃមូលបត្រ និងឯកសារផ្តល់ព័ត៌មានមួយច្បាប់ ដែលបំពេញតាមលក្ខខណ្ឌរបស់ច្បាប់នេះព្រមទាំងលក្ខខណ្ឌទាំងឡាយណា ដែលត្រូវបានកំណត់ដោយអនុលោមតាមច្បាប់នេះ។

២-បង់ថ្លៃសេវាតាមការកំណត់សម្រាប់ការដាក់ពាក្យស្នើសុំ។

**មាត្រា ១៨.- ការចុះបញ្ជី និងការយល់ព្រមលើឯកសារផ្តល់ព័ត៌មាន**

អគ្គនាយកនៃ **គ.ម.ក.** អាចផ្តល់ការអនុញ្ញាត ចំពោះឯកសារផ្តល់ព័ត៌មាន និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានដែលបានដាក់ជូន **គ.ម.ក.** ប្រសិនបើអគ្គនាយកនៃ **គ.ម.ក.** ពិនិត្យឃើញថាឯកសារនោះបំពេញតាមលក្ខខណ្ឌរបស់ច្បាប់ និងលក្ខខណ្ឌផ្សេងៗ ដែលត្រូវបានកំណត់អនុលោមតាមច្បាប់នេះ។

**មាត្រា ១៩.- ការបដិសេធលើឯកសារផ្តល់ព័ត៌មាន**

ការសម្រេចបដិសេធចំពោះការផ្តល់ការអនុញ្ញាត និង ការចុះបញ្ជីឯកសារផ្តល់ព័ត៌មានត្រូវធ្វើឡើងដូចខាងក្រោម :

១-ប្រសិនបើអគ្គនាយកនៃ **គ.ម.ក.** ពិនិត្យឃើញថា ឯកសារផ្តល់ព័ត៌មានដែលបានដាក់សុំការអនុញ្ញាតនោះ ពុំបានបំពេញតាមលក្ខខណ្ឌនៃច្បាប់នេះ និង លក្ខខណ្ឌផ្សេងៗដទៃទៀតដែលបានកំណត់ដោយអនុលោមតាមច្បាប់នេះ អគ្គនាយកនៃ **គ.ម.ក.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកដាក់ពាក្យស្នើសុំដោយផ្តល់នូវ :

ក-មូលហេតុ។

ខ-ឱកាសឱ្យអ្នកដាក់ពាក្យស្នើសុំ ឬ ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដើម្បីធ្វើការពន្យល់បន្ថែមលើគុណសម្បត្តិនៃសំណើដាក់លក់មូលបត្រជាសាធារណៈនោះ។

គ-ឱកាសឱ្យអ្នកដាក់ពាក្យស្នើសុំ ឬ ក្រុមហ៊ុនបោះផ្សាយមូលបត្រដើម្បីធ្វើការកែប្រែឯកសារផ្តល់ព័ត៌មាន។

២-ប្រសិនបើអគ្គនាយកនៃ **គ.ម.ក.** នៅតែពិនិត្យឃើញថា ឯកសារផ្តល់ព័ត៌មានដែលតម្រូវឱ្យកែប្រែនោះ នៅតែមិនបានបំពេញតាមលក្ខខណ្ឌនៃច្បាប់ និងលក្ខខណ្ឌផ្សេងៗដទៃទៀតដែលបានកំណត់ដោយអនុលោមតាមច្បាប់នេះ អគ្គនាយកនៃ **គ.ម.ក.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ដល់អ្នកដាក់ពាក្យស្នើសុំយ៉ាងឆាប់រហ័ស តាមដែលអាចធ្វើទៅបានថាឯកសារផ្តល់ព័ត៌មានត្រូវបានបដិសេធមិនឱ្យចុះបញ្ជី។

**មាត្រា ២០.- ឯកសារផ្តល់ព័ត៌មានបន្ថែម**

ក្នុងរយៈពេលឯកសារផ្តល់ព័ត៌មាននៅមានសុពលភាព បុគ្គល ឬ ក្រុមហ៊ុនស្នើសុំចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ឬ ក្រុមហ៊ុនបោះផ្សាយមូលបត្រ ត្រូវដាក់ឯកសារផ្តល់ព័ត៌មានបន្ថែម ឬឯកសារផ្តល់ព័ត៌មានជំនួសជូនទៅ **គ.ម.ក.** ដើម្បីសុំការអនុញ្ញាត និងចុះបញ្ជី ប្រសិនបើឯកសារផ្តល់ព័ត៌មាន មាន :

១-ការកែប្រែ ឬ ផ្លាស់ប្តូរព័ត៌មាន ដែលប៉ះពាល់ដល់ខ្លឹមសារឯកសារផ្តល់ព័ត៌មានដែលបានផ្តល់។

២-បញ្ហាសំខាន់ថ្មីបានកើតឡើងដោយសារតែច្បាប់ ឬលក្ខខណ្ឌផ្សេងទៀតដែលកំណត់ដោយអនុលោមតាមច្បាប់នេះបានតម្រូវឱ្យបង្ហាញបញ្ហាសំខាន់ថ្មីនោះ ទោះបីជាឯកសារផ្តល់ព័ត៌មានត្រូវបានរៀបចំហើយក៏ដោយ។

៣-ឯកសារផ្តល់ព័ត៌មាន ដែលបានផ្តល់មានបង្កប់នូវព័ត៌មានសំខាន់ណាមួយដែលមានលក្ខណៈមិនច្បាស់លាស់ ឬក្លែងបន្លំ ឬដែលនាំឱ្យយល់ខុស ឬមានការខកខានមិនបានបង្ហាញនូវចំណុចសំខាន់ដែលត្រូវដាក់ក្នុងឯកសារផ្តល់ព័ត៌មាន។

បុគ្គល ឬ ក្រុមហ៊ុនស្នើសុំចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ឬ ក្រុមហ៊ុនបោះផ្សាយមូលបត្រ មិនត្រូវផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មានបន្ថែម ឬ ឯកសារផ្តល់ព័ត៌មានជំនួសជាសាធារណៈ លើកលែងតែឯកសារផ្តល់ព័ត៌មានបន្ថែម ឬ ឯកសារផ្តល់ព័ត៌មានជំនួសនោះ ទទួលបានការអនុញ្ញាត និងចុះបញ្ជីពី គ.ម.ក.។

**មាត្រា ២១.- ការព្យួរ ឬ ការលុបចោលឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីរួច**

អគ្គនាយកនៃ **គ.ម.ក.** មានសិទ្ធិព្យួរការចុះបញ្ជីនៃឯកសារផ្តល់ព័ត៌មាន ដើម្បីការពារផលប្រយោជន៍សាធារណៈ ក្នុងករណីអគ្គនាយកនៃ **គ.ម.ក.** ពិនិត្យឃើញថា ឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីរួចហើយ ដោយរួមទាំងឯកសារផ្តល់ព័ត៌មានបន្ថែម ឬ ឯកសារផ្តល់ព័ត៌មានជំនួសនោះ :

១-មានព័ត៌មានដែលមានលក្ខណៈក្លែងបន្លំ ឬ ដែលនាំឱ្យយល់ខុស ឬ ខកខានពុំបានផ្តល់ព័ត៌មានសំខាន់ណាមួយ។

២-ពុំបានអនុវត្តតាមច្បាប់ ឬ លក្ខខណ្ឌផ្សេងទៀត ដែលបានកំណត់អនុលោមតាមច្បាប់នេះ។

ការព្យួរការចុះបញ្ជីឯកសារផ្តល់ព័ត៌មានត្រូវធ្វើឡើងក្នុងរយៈពេលជាក់លាក់ណាមួយ មិនឱ្យលើសពី ០១(មួយ)ខែ ហើយបន្ទាប់ពីផុតរយៈពេលនៃការព្យួរនេះ បើអគ្គនាយកនៃ **គ.ម.ក.** ពិនិត្យឃើញថា បញ្ហាដែលបណ្តាលឱ្យមានការព្យួរមិនត្រូវបានដោះស្រាយឱ្យបានសមស្រប អគ្គនាយកនៃ **គ.ម.ក.** មានសិទ្ធិលុបចោលការចុះបញ្ជីឯកសារផ្តល់ព័ត៌មាននោះ។

**មាត្រា ២២.- លក្ខខណ្ឌបន្ថែមទាក់ទងនឹងសំណើលក់ និងការបោះផ្សាយមូលបត្រ**

លក្ខខណ្ឌបន្ថែមទៀត ដែលទាក់ទងនឹងការគ្រប់គ្រង និងត្រួតពិនិត្យសំណើលក់ជាសាធារណៈ និងការបោះផ្សាយមូលបត្រ ត្រូវកំណត់ដោយ **គ.ម.ក.**។

## ជំពូកទី ៤
## ដំណើរការរបស់ទីផ្សារមូលបត្រ

**មាត្រា ២៣.- ការអនុញ្ញាតឱ្យធ្វើប្រតិបត្តិការទីផ្សារមូលបត្រ ប្រព័ន្ធផាត់ទាត់និងទូទាត់ ឬ សេវារក្សាទុកមូលបត្រ**

គ្មានបុគ្គលណាមួយ អាចធ្វើប្រតិបត្តិការទីផ្សារមូលបត្រ ប្រព័ន្ធផាត់ទាត់និងទូទាត់ ឬ សេវារក្សាទុកមូលបត្រឡើយ លើកលែងតែបុគ្គលនោះទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** ដោយអនុលោមតាមច្បាប់នេះ ឬ ច្បាប់ផ្សេងៗទៀតជាធរមាន។ មាត្រានេះមិនត្រូវបានអនុវត្តចំពោះធនាគារជាតិនៃកម្ពុជាទេ ដែលអាចធ្វើប្រតិបត្តិការប្រព័ន្ធផាត់ទាត់និងទូទាត់ ឬ សេវារក្សាទុកមូលបត្រ។

**មាត្រា ២៤.- ការដាក់ពាក្យស្នើសុំធ្វើប្រតិបត្តិការទីផ្សារមូលបត្រ ប្រព័ន្ធផាត់ទាត់និងទូទាត់ ឬ សេវារក្សាទុកមូលបត្រ**

ការដាក់ពាក្យស្នើសុំ ដើម្បីធ្វើប្រតិបត្តិការទីផ្សារមូលបត្រ ប្រព័ន្ធផាត់ទាត់និងទូទាត់ ឬ សេវារក្សាទុកមូលបត្រ ត្រូវធ្វើឡើងដូចខាងក្រោម :

១-បុគ្គលត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពី **គ.ម.ក.** ដើម្បីធ្វើប្រតិបត្តិការទីផ្សារមូលបត្រ ប្រព័ន្ធផាត់ទាត់និងទូទាត់ ឬ សេវារក្សាទុកមូលបត្រ តាមទម្រង់ដែលបានកំណត់ និងបង់ថ្លៃសេវាតាមការកំណត់របស់ **គ.ម.ក.**។

២-ក្រោយពីទទួលបានពាក្យស្នើសុំតាមកថាខណ្ឌ (១) អគ្គនាយកនៃ **គ.ម.ក.** ត្រូវបញ្ជូនពាក្យស្នើសុំមួយច្បាប់ជូនប្រធាន **គ.ម.ក.** និងសមាជិកនៃ **គ.ម.ក.** ទាំងអស់ ដើម្បីផ្តល់អនុសាសន៍លើពាក្យស្នើសុំនោះឱ្យបានយ៉ាងឆាប់តាមការជាក់ស្តែង។

៣-អគ្គនាយកនៃ **គ.ម.ក.** អាចតម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំផ្តល់នូវព័ត៌មានបន្ថែមតាមការចាំបាច់។ ក្នុងករណីអ្នកដាក់ពាក្យស្នើសុំមិនបានផ្តល់ព័ត៌មានបន្ថែម អគ្គនាយកនៃ **គ.ម.ក.** អាចបដិសេធមិនពិនិត្យពាក្យស្នើសុំនោះ។

## មាត្រា ២៥.- ការអនុញ្ញាតលើពាក្យស្នើសុំ

ការសម្រេចផ្តល់ការអនុញ្ញាត លើការស្នើសុំធ្វើប្រតិបត្តិការទីផ្សារមូលបត្រ ប្រព័ន្ធផាត់ទាត់និងទូទាត់ ឬ សេវារក្សាទុកមូលបត្រមានដូចតទៅ :

១-ក្រោយពីទទួលបានការសម្រេចពីការប្រជុំពេញអង្គរបស់ **គ.ម.ក.** មក អគ្គនាយកនៃ **គ.ម.ក.** ត្រូវផ្តល់ការអនុញ្ញាតដល់បុគ្គល ដើម្បីដាក់ឱ្យធ្វើប្រតិបត្តិការទីផ្សារមូលបត្រ ប្រព័ន្ធផាត់ទាត់និងទូទាត់ ឬ សេវារក្សាទុកមូលបត្រ ប្រសិនបើអគ្គនាយកនៃ **គ.ម.ក.** ពិនិត្យឃើញថា ពាក្យស្នើសុំនោះបានបំពេញតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់នេះ។

២-អគ្គនាយកនៃ **គ.ម.ក.** មិនត្រូវបដិសេធផ្តល់ការអនុញ្ញាតលើពាក្យស្នើសុំដោយមិនបានផ្តល់មូលហេតុជាលាយលក្ខណ៍អក្សរជាមុន និងមិនបានផ្តល់ឱកាសឱ្យអ្នកដាក់ពាក្យស្នើសុំធ្វើការពន្យល់។

៣-ប្រសិនបើអគ្គនាយកនៃ **គ.ម.ក.** ផ្តល់ការអនុញ្ញាតតាមកថាខណ្ឌ (១) :

-ការអនុញ្ញាតត្រូវធ្វើឡើង ដោយគោរពតាមលក្ខខណ្ឌកំណត់ អនុលោមតាមច្បាប់នេះ

-ក្នុងរយៈពេលដែលការអនុញ្ញាតនៅមានសុពលភាព អគ្គនាយកនៃ **គ.ម.ក.** អាចកំណត់នូវលក្ខខណ្ឌបន្ថែម ឬ កែប្រែ ឬ ដកហូតលក្ខខណ្ឌបន្ថែមណាមួយមកវិញបាន ក្រោយពីបានទទួលការសម្រេចរបស់ **គ.ម.ក។**

## មាត្រា ២៦.- លក្ខខណ្ឌតម្រូវឱ្យមានប្រព័ន្ធផាត់ទាត់ និងទូទាត់

មុនពេលដែលអគ្គនាយកនៃ **គ.ម.ក.** ផ្តល់ការអនុញ្ញាតលើពាក្យស្នើសុំ ដើម្បីដាក់ឱ្យដំណើរការប្រតិបត្តិការទីផ្សារមូលបត្រ អ្នកដាក់ពាក្យស្នើសុំត្រូវបញ្ជាក់ជូន **គ.ម.ក.** អំពីលទ្ធភាពរបស់ខ្លួន ក្នុងការរៀបចំឱ្យមានការប្រើប្រាស់ប្រព័ន្ធផាត់ទាត់ និងទូទាត់មួយសមស្រប សម្រាប់ប្រតិបត្តិការជួញដូរនៅក្នុងទីផ្សារមូលបត្រនោះ។

### មាត្រា ២៧.- ការព្យួរ និងការដកហូត ការអនុញ្ញាត

សិទ្ធិអំណាចរបស់អគ្គនាយកនៃ **គ.ម.ក.** ក្នុងការគ្រប់គ្រងប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់ ឬ ប្រតិបត្តិកររក្សាទុកមូលបត្រ មានដូចតទៅ :

១-ក្រោយពេលផ្តល់ការអនុញ្ញាតស្របតាមជំពូកនេះ ប្រសិនបើអគ្គនាយកនៃ **គ.ម.ក.** ពិនិត្យឃើញថា ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់ និង ប្រតិបត្តិកររក្សាទុកមូលបត្រ បានបំពានលើលក្ខខណ្ឌនៃការអនុញ្ញាត ឬ លក្ខខណ្ឌរបស់ច្បាប់ និងលក្ខខណ្ឌផ្សេងទៀតដែលបានកំណត់តាមច្បាប់នេះ អគ្គនាយកនៃ **គ.ម.ក.** មានសិទ្ធិចាត់វិធានការដូចខាងក្រោម:

ក-ដឹកនាំកែតម្រង់បុគ្គល ដែលទទួលបានការអនុញ្ញាតឱ្យអនុវត្តតាមលក្ខខណ្ឌតម្រូវ។

ខ-ដាក់លក្ខខណ្ឌ ឬ កំហិតបន្ថែមលើការអនុញ្ញាត។

គ-ព្យួរការអនុញ្ញាតរហូតដល់អ្នកដែលទទួលបានការអនុញ្ញាតនោះអនុវត្តតាមលក្ខខណ្ឌតម្រូវឱ្យបានពេញលេញ។

ឃ-ដកហូតការអនុញ្ញាតនោះមកវិញ។

២-អគ្គនាយកនៃ **គ.ម.ក.** មិនត្រូវចាត់វិធានការស្របតាមកថាខណ្ឌ (១) ដោយមិនបានសុំយោបល់ **គ.ម.ក.** ដោយបើកធ្វើការប្រជុំពេញអង្គជាមុន និង ដោយមិនបានផ្តល់ដល់អ្នកទទួលបានការអនុញ្ញាតនូវមូលហេតុជាលាយលក្ខណ៍អក្សរ និងមិនផ្តល់ឱកាសឱ្យអ្នកទទួលបានការអនុញ្ញាតធ្វើការពន្យល់។

### មាត្រា ២៨.- វិធានប្រតិបត្តិការ និងនីតិវិធីរបស់ទីផ្សារមូលបត្រ ប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ឬសេវារក្សាទុកមូលបត្រដែលមានការអនុញ្ញាត

គ្មានបុគ្គលណា អាចដាក់ឱ្យអនុវត្តនូវវិធានប្រតិបត្តិការ និងនីតិវិធីរបស់ទីផ្សារមូលបត្រ ប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ឬ សេវារក្សាទុកមូលបត្រ លើកលែងតែទទួលបានការ

អនុញ្ញាតពី **គ.ម.ក.**។ វិធានប្រតិបត្តិការ និងនីតិវិធីនោះ ត្រូវចែងអំពីបញ្ញត្តិនានាដែលទាក់ទងនឹងការគ្រប់គ្រងឱ្យបានច្បាស់លាស់ហើយឱ្យស្របតាមច្បាប់នេះ។

**មាត្រា ២៩.- លក្ខខណ្ឌបន្ថែមដែលមានទាក់ទងនឹងការប្រព្រឹត្តទៅរបស់ទីផ្សារបន្ទាប់**

ការលក់ ឬ ការទិញមូលបត្រដែលបោះផ្សាយលក់ អនុលោមតាមច្បាប់នេះ ត្រូវបានគ្រប់គ្រងដោយលក្ខខណ្ឌបន្ថែមដែលកំណត់ដោយ **គ.ម.ក.**។

**មាត្រា ៣០.- ការគោរពលក្ខខណ្ឌ និងលក្ខខណ្ឌបន្ថែមនៃការអនុញ្ញាត**

បុគ្គលដែលបានទទួលការណែនាំពីអគ្គនាយកនៃ **គ.ម.ក.** តាមមាត្រា ២៧(១) នៃច្បាប់នេះ ឱ្យអនុវត្តតាមលក្ខខណ្ឌ ឬ លក្ខខណ្ឌបន្ថែមនៃការអនុញ្ញាត ត្រូវតែគោរពតាមការណែនាំ ក្នុងរយៈពេលជាក់លាក់មួយដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

## ជំពូកទី ៥

## អាជ្ញាប័ណ្ណរបស់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ

**មាត្រា ៣១.- ការផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ**

គ្មានបុគ្គលណាមួយអាចធ្វើអាជីវកម្មមូលបត្រ ឬ តាំងខ្លួនជាអ្នកធ្វើអាជីវកម្មមូលបត្រក្នុងទម្រង់ជាក្រុមហ៊ុនមូលបត្របានទេ លើកលែងតែបុគ្គលនោះទទួលអាជ្ញាប័ណ្ណពីអគ្គនាយកនៃ **គ.ម.ក.** ឬពាណិជ្ជករមូលបត្រអញ្ញត្រកម្ម ឬ ពាណិជ្ជករពាក់ព័ន្ធនឹងប្រតិបត្តិការមូលបត្រអញ្ញត្រកម្មដែលកំណត់ដោយអនុក្រឹត្យ។

គ្មានជនណាមួយអាចធ្វើជាភ្នាក់ងារ ឬ តាំងខ្លួនជាភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រប្រតិស្រុតដើម្បីធ្វើអាជីវកម្មមូលបត្របានទេ លុះត្រាតែជននោះត្រូវបានផ្តល់អាជ្ញាប័ណ្ណដោយអគ្គនាយកនៃ **គ.ម.ក.** ឱ្យធ្វើជាភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រអនុលោមតាមច្បាប់នេះ។

**មាត្រា ៣២.- ការដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ**

ការដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ ត្រូវធ្វើដូចតទៅ :

១-បុគ្គលមួយអាចដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ ដើម្បីធ្វើអាជីវកម្មមូលបត្រ ឬ ធ្វើជាភ្នាក់ងារក្រុមហ៊ុនមូលបត្រទៅអគ្គនាយកនៃ **គ.ម.ក.** តាមទម្រង់បែបបទដែលបានកំណត់ និងដោយបង់ថ្លៃសេវាតាមការកំណត់របស់ **គ.ម.ក.**។

២-អគ្គនាយកនៃ **គ.ម.ក.** អាចតម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំផ្តល់នូវព័ត៌មានបន្ថែមតាមការចាំបាច់ និងអាចបដិសេធមិនពិនិត្យពាក្យស្នើសុំនោះ រហូតដល់អ្នកដាក់ពាក្យស្នើសុំបានផ្តល់ព័ត៌មានគ្រប់គ្រាន់។

**មាត្រា ៣៣.- ការពិនិត្យ និងសម្រេចលើពាក្យស្នើសុំអាជ្ញាប័ណ្ណ**

ការសម្រេចផ្តល់អាជ្ញាប័ណ្ណ និងលក្ខខណ្ឌអាជ្ញាប័ណ្ណ ត្រូវអនុវត្តដូចខាងក្រោម :

១-អគ្គនាយកនៃ **គ.ម.ក.** អាចផ្តល់អាជ្ញាប័ណ្ណដល់អ្នកដាក់ពាក្យស្នើសុំ ដើម្បីធ្វើអាជីវកម្មមូលបត្រ ឬ ធ្វើជាភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ ប្រសិនបើអ្នកដាក់ពាក្យស្នើសុំបានបំពេញតាមលក្ខខណ្ឌ ដែលបានកំណត់ដោយ **គ.ម.ក.**។ នៅក្នុងរយៈពេលដែលអាជ្ញា-ប័ណ្ណនៅមានសុពលភាព ប្រសិនបើលក្ខខណ្ឌដែលបានកំណត់ដោយ **គ.ម.ក.** មានការប្រែប្រួល អ្នកដាក់ពាក្យស្នើសុំដែលបានទទួលអាជ្ញាប័ណ្ណរួចហើយ ត្រូវបន្តបំពេញតាមលក្ខខណ្ឌប្រែប្រួលនោះ។

២-អគ្គនាយកនៃ **គ.ម.ក.** មិនត្រូវបដិសេធក្នុងការផ្តល់អាជ្ញាប័ណ្ណជូនអ្នកដាក់ពាក្យស្នើសុំ ដោយមិនបញ្ជាក់ពីមូលហេតុជាលាយលក្ខណ៍អក្សរជាមុន និងដោយមិនបានផ្តល់ឱកាសដល់អ្នកដាក់ពាក្យស្នើសុំឱ្យធ្វើការពន្យល់ឡើយ។

៣-ប្រសិនបើអគ្គនាយកនៃ **គ.ម.ក.** ផ្តល់អាជ្ញាប័ណ្ណតាមកថាខណ្ឌ (១) :

-អាជ្ញាប័ណ្ណដែលផ្តល់នោះត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិ និងលក្ខខណ្ឌដែលកំណត់ដោយ **គ.ម.ក**

-អាជ្ញាប័ណ្ណដែលផ្តល់នោះត្រូវស្ថិតនៅក្រោមលក្ខខណ្ឌ ឬ ការដាក់កំហិតណាមួយតាមការចាំបាច់ រួមទាំងលក្ខខណ្ឌដែលដាក់កំហិតលើប្រភេទអាជីវកម្មណាមួយដែលមានក្នុងអាជ្ញាប័ណ្ណ និង

-ក្នុងរយៈពេលដែលអាជ្ញាប័ណ្ណនៅមានសុពលភាព អគ្គនាយកនៃ **គ.ម.ក.** អាចកំណត់នូវលក្ខខណ្ឌបន្ថែមលើអាជ្ញាប័ណ្ណ កែប្រែ ឬដកលក្ខខណ្ឌណាមួយមកវិញ ក្រោយទទួលបានការសម្រេចរបស់ **គ.ម.ក.**។

## មាត្រា ៣៤.- ការព្យួរ និងការដកហូតអាជ្ញាប័ណ្ណ

វិធានការចំពោះអ្នកកាន់អាជ្ញាប័ណ្ណមានដូចតទៅ :

១-ក្រោយពេលផ្តល់អាជ្ញាប័ណ្ណក្រោមជំពូកនេះ ប្រសិនបើអគ្គនាយកនៃ **គ.ម.ក.** ពិនិត្យឃើញថា អ្នកកាន់អាជ្ញាប័ណ្ណបានបំពានលើលក្ខខណ្ឌណាមួយនៃអាជ្ញាប័ណ្ណ ឬ លក្ខខណ្ឌណាមួយដែលកំណត់ដោយ **គ.ម.ក.** ឬ បទប្បញ្ញត្តិណាមួយដែលបានកំណត់ដោយអនុលោមតាមច្បាប់នេះ អគ្គនាយកនៃ **គ.ម.ក.** អាចចាត់វិធានការដូចខាងក្រោម :

-ដឹកនាំកែតម្រង់អ្នកកាន់អាជ្ញាប័ណ្ណឱ្យអនុវត្តតាមលក្ខខណ្ឌ ឬ លក្ខខណ្ឌបន្ថែមនោះ

-ដាក់កំហិតលើអាជ្ញាប័ណ្ណ

-ព្យួរអាជ្ញាប័ណ្ណនោះ រហូតដល់អ្នកកាន់អាជ្ញាប័ណ្ណបានគោរពតាមលក្ខខណ្ឌ ឬ លក្ខខណ្ឌបន្ថែមពេញលេញ

-ដកហូតអាជ្ញាប័ណ្ណមកវិញ។

២-អគ្គនាយកនៃ **គ.ម.ក.** មិនត្រូវចាត់វិធានការដូចមានចែងក្នុងកថាខណ្ឌ (១) ដោយមិនបានជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនដល់អ្នកកាន់អាជ្ញាប័ណ្ណ អំពីមូលហេតុនៃការចាត់វិធានការនេះ និងដោយមិនផ្តល់ឱកាសឱ្យអ្នកកាន់អាជ្ញាប័ណ្ណធ្វើការពន្យល់ឡើយ។

## មាត្រា ៣៥.- លក្ខខណ្ឌនៃអាជ្ញាប័ណ្ណ និងការផ្តល់អាជ្ញាប័ណ្ណដល់ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ និងអ្នកចូលរួមដទៃទៀត

លក្ខខណ្ឌនៃអាជ្ញាប័ណ្ណ និងការផ្តល់អាជ្ញាប័ណ្ណដល់ទីប្រឹក្សាវិនិយោគ ពាណិជ្ជករ មូលបត្រ និង អ្នកចូលរួមដទៃទៀតក្នុងទីផ្សារមូលបត្រ ឬ ប្រព័ន្ធជាត់ទាត់និងទូទាត់ ឬ សេវារក្សាទុក

មូលបត្រត្រូវកំណត់ដោយ **គ.ម.ក.**។

**មាត្រា ៣៦.- ការបង្កើត និងការរក្សាបញ្ជីអាជ្ញាប័ណ្ណ**

អគ្គនាយកនៃ **គ.ម.ក.** ត្រូវបង្កើត និងរក្សាបញ្ជីអាជ្ញាប័ណ្ណទាំងអស់ដែលខ្លួនបានផ្តល់តាមទម្រង់បែបបទត្រឹមត្រូវ ដោយចុះបញ្ជាក់នូវព័ត៌មានជាក់លាក់មួយចំនួន។

**មាត្រា ៣៧.- ការគោរពលក្ខខណ្ឌ និងលក្ខខណ្ឌបន្ថែមនៃអាជ្ញាប័ណ្ណ**

បុគ្គលណាដែលបានទទួលការណែនាំពីអគ្គនាយកនៃ **គ.ម.ក.** តាមមាត្រា ៣៤(១) នៃច្បាប់នេះឱ្យអនុវត្តតាមលក្ខខណ្ឌ ឬ លក្ខខណ្ឌបន្ថែមនៃអាជ្ញាប័ណ្ណ ត្រូវតែគោរពតាមការណែនាំក្នុងរយៈពេលជាក់លាក់មួយដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

## ជំពូកទី ៦

## អភិបាលកិច្ច និងការគ្រប់គ្រងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ

**មាត្រា ៣៨.- លក្ខខណ្ឌនៃអភិបាលកិច្ច ចំពោះក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុតដទៃទៀត**

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុតដទៃទៀត ដែលបោះផ្សាយលក់មូលបត្រជាសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់នូវបទប្បញ្ញត្តិនានាជាធរមាន និងរាល់លក្ខខណ្ឌទាំងឡាយស្តីពីអភិបាលកិច្ច ដែលកំណត់ដោយ **គ.ម.ក.** ដើម្បីការពារផលប្រយោជន៍ដល់ការប្រព្រឹត្តទៅនៃទីផ្សារមូលបត្រ និងដើម្បីការពារផលប្រយោជន៍អ្នកវិនិយោគសាធារណៈ។

**មាត្រា ៣៩.- លក្ខខណ្ឌគ្រប់គ្រងសាជីវកម្ម**

លក្ខខណ្ឌគ្រប់គ្រងសាជីវកម្មអាចត្រូវកំណត់ដោយ **គ.ម.ក.** ដើម្បីគ្រប់គ្រងលើ :

-បែបបទក្នុងការទទួលបានសិទ្ធិកាន់កាប់ លើភាគហ៊ុនមានសិទ្ធិបោះឆ្នោតនៅ

ក្នុងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុតដទៃទៀត ដែលបោះផ្សាយលក់ជាសាធារណៈនូវភាគហ៊ុនមានសិទ្ធិបោះឆ្នោត ។ លក្ខខណ្ឌដែលត្រូវបានកំណត់នោះមានគោលបំណងដើម្បីធានាថាការទទួលបានសិទ្ធិគ្រប់គ្រងលើភាគហ៊ុន ដែលមានសិទ្ធិបោះឆ្នោតនៅក្នុងក្រុមហ៊ុន ឬ នីតិបុគ្គលនោះ ធ្វើឡើងប្រកបដោយយុត្តិធម៌ និងតម្លាភាព។

-ការផ្តល់ព័ត៌មានអំពីកម្មសិទ្ធិ នៃការកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើននៅក្នុងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុតដែលបោះផ្សាយលក់ជាសាធារណៈនូវភាគហ៊ុនមានសិទ្ធិបោះឆ្នោត។ លក្ខខណ្ឌដែលត្រូវបានកំណត់នោះមានគោលបំណងដើម្បីធានាថា អ្នកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតនៅក្នុងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុត អាចដឹងពីអត្តសញ្ញាណរបស់អ្នកកាន់កាប់ភាគហ៊ុនចំនួនច្រើននៅក្នុងក្រុមហ៊ុន ឬ នីតិបុគ្គលនោះ។

## ជំពូកទី ៧
## អាកប្បកិរិយាដែលត្រូវបានហាមឃាត់ទាក់ទិននឹងមូលបត្រ

### មាត្រា ៤០.- ការជួញដូរផ្ទៃក្នុង

អ្នកផ្ទៃក្នុងត្រូវបានកំណត់ដូចខាងក្រោម :

-អគ្គនាយក នាយក គណៈគ្រប់គ្រង និងបុគ្គលិករបស់ក្រុមហ៊ុន ឬ របស់នីតិ-បុគ្គលប្រតិស្រុត និងភាគហ៊ុនិកនៅក្នុងក្រុមហ៊ុន ឬ នីតិបុគ្គលប្រតិស្រុតដែលកាន់កាប់យ៉ាងតិច ៥(ប្រាំ) ភាគរយនៃភាគហ៊ុនមានសិទ្ធិបោះឆ្នោត និងបុគ្គលដទៃទៀត ដែលទំនាក់ទំនងរបស់បុគ្គលនោះជាមួយនឹងក្រុមហ៊ុន ឬ នីតិបុគ្គលប្រតិស្រុតផ្តល់ឱ្យខ្លួនមាន ឬ ទទួលបាននូវព័ត៌មានសម្ងាត់ទាក់ទិននឹងសកម្មភាពរបស់ក្រុមហ៊ុន ឬ នីតិបុគ្គលប្រតិស្រុត

-ប្រធាន សមាជិក អគ្គនាយក នាយក និងបុគ្គលិករបស់ **គ.ម.ក.** ទាំងអស់ និង មន្ត្រីពាក់ព័ន្ធដទៃទៀតរបស់រាជរដ្ឋាភិបាល ឬ បុគ្គលិករបស់នីតិបុគ្គលដែលទទួលបានការអនុញ្ញាត ឬ ទទួលបានអាជ្ញាប័ណ្ណពីអគ្គនាយកនៃ **គ.ម.ក.** ឱ្យធ្វើជាអន្តរការីនៅក្នុងទីផ្សារ

មូលបត្រដែលមាន ឬ ទទួលបាននូវព័ត៌មានសម្ងាត់ទាក់ទិននឹងសកម្មភាពរបស់ក្រុមហ៊ុន ឬ នីតិបុគ្គលប្រតិស្រុតដោយសារតែតួនាទីរបស់ខ្លួន។

ព័ត៌មានផ្ទៃក្នុង សំដៅដល់ព័ត៌មានទាំងឡាយណាទាក់ទិននឹងមូលបត្រដែលត្រូវបោះផ្សាយ និង បានបោះផ្សាយ ដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុត ហើយព័ត៌មានទាំងនោះមិនទាន់ផ្សព្វផ្សាយជាទូទៅ ប៉ុន្តែប្រសិនបើព័ត៌មានទាំងនោះដឹងដល់សាធារណជន អាចមានផលប៉ះពាល់ខ្លាំងដល់តម្លៃ ឬ ទិន្នភាពជួញដូរផទៃទៀតរបស់មូលបត្រទាំងនោះ។

អ្នកផ្ទៃក្នុងដូចមានចែងក្នុងកថាខណ្ឌទី ១ មិនត្រូវ :

-ឆ្លៀតប្រើប្រាស់ព័ត៌មានផ្ទៃក្នុងដែលចែងក្នុងកថាខ័ណ្ឌទី២ ខាងលើ ដោយផ្ទាល់ ឬ មិនផ្ទាល់ ដើម្បីជួញដូរមូលបត្ររបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុតក្នុងគោលបំណងរកចំណេញ ឬ បញ្ចៀសការខាតបង់ផ្ទាល់ខ្លួន

-ផ្តល់ព័ត៌មានផ្ទៃក្នុងដល់បុគ្គលផទៃណាមួយ ឬ នីតិបុគ្គលប្រតិស្រុតណាមួយក្នុងគោលបំណងធ្វើឱ្យបុគ្គលនោះ ឬ នីតិបុគ្គលប្រតិស្រុតនោះរកចំណេញ ឬ បញ្ចៀសការខាតបង់។

## មាត្រា ៤១.- ការជួញដូរក្លែងក្លាយ និងការប្រើឧបាយកលក្នុងទីផ្សារ

ទោះបីជាដោយចេតនា ឬ ដោយធ្វេសប្រហែសក្តី បុគ្គលមិនត្រូវ :

១-ធ្វើសកម្មភាពណាមួយ ឬ គេចវេះមិនធ្វើសកម្មភាពដែលបណ្តាលឱ្យ ឬ អាចបណ្តាលឱ្យមានលក្ខណៈក្លែងបន្លំ ឬ នាំឱ្យយល់ខុសចំពោះការជួញដូរមូលបត្រ ដែលគេកំពុងជួញដូរនៅលើទីផ្សារមូលបត្រនៅក្នុងប្រទេសកម្ពុជា ឬ

២-ធ្វើប្រតិបត្តិការ ឬ ធ្វើផែនការជួញដូរដែលមានលក្ខណៈសិប្បនិម្មិតទាក់ទិននឹងមូលបត្រ ហើយប្រសិនបើប្រតិបត្តិការនោះបណ្តាលឱ្យ :

-តម្លៃនៃការជួញដូរមូលបត្រ នៅលើទីផ្សារមូលបត្រ នៅក្នុងប្រទេសកម្ពុជា នៅថេរ កើនឡើង ឬ ស្រុតចុះ និង

-មានចលនាឡើង ចុះតម្លៃនៃការជួញដូរមូលបត្រនៅលើទីផ្សារមូលបត្រ

ក្នុងប្រទេសកម្ពុជា។

**មាត្រា ៤២.- សេចក្តីថ្លែង ឬ ការផ្សព្វផ្សាយព័ត៌មានក្លែងបន្លំ ឬ ដែលនាំឱ្យយល់ខុស**

បុគ្គលមិនត្រូវធ្វើសេចក្តីថ្លែង ឬ ការផ្សព្វផ្សាយព័ត៌មានប្រសិនបើ :

១-សេចក្តីថ្លែង ឬ ការផ្សព្វផ្សាយព័ត៌មាននោះមានលក្ខណៈក្លែងបន្លំ ឬ មានលក្ខណៈនាំឱ្យយល់ខុសធ្ងន់ធ្ងរ។

២-សេចក្តីថ្លែង ឬ ការផ្សព្វផ្សាយព័ត៌មានទាំងនោះអាច :

- បណ្តាលឱ្យសាធារណជននៅក្នុងប្រទេសកម្ពុជា ទិញ ឬ លក់មូលបត្រ ឬ

-បណ្តាលឱ្យមានការកើនឡើង ការថយចុះ ឬ ការនៅថេរចំពោះតម្លៃនៃការជួញដូរមូលបត្រដែលជួញដូរនៅលើទីផ្សារមូលបត្រនៅក្នុងប្រទេសកម្ពុជា។

៣-នៅពេលដែលបុគ្គលនោះធ្វើសេចក្តីថ្លែង ឬ ការផ្សព្វផ្សាយព័ត៌មាន :

-បុគ្គលនោះមិនគិតថា សេចក្តីថ្លែង ឬ ការផ្សព្វផ្សាយព័ត៌មាននោះពិត ឬ ក្លែងបន្លំ ឬ

-បុគ្គលនោះដឹង ឬ គួរដឹងថាសេចក្តីថ្លែង ឬ ការផ្សព្វផ្សាយព័ត៌មាននោះគឺក្លែងបន្លំ និងមានលក្ខណៈធ្វើឱ្យយល់ខុស។

## ជំពូកទី ៨
## ការដោះស្រាយវិវាទ និង វិធានការទណ្ឌកម្ម

**មាត្រា ៤៣.- ការផ្សះផ្សាវិវាទ**

គ្រប់វិវាទដែលពាក់ព័ន្ធនឹងសកម្មភាពអាជីវកម្មមូលបត្រ ភាគីជម្លោះអាចនាំយកវិវាទនោះជូនទៅ**គ.ម.ក.** ដើម្បីធ្វើការផ្សះផ្សាមុននឹងប្តឹងទៅតុលាការ លើកលែងតែរឿងព្រហ្មទណ្ឌ។

**មាត្រា ៤៤.- នីតិវិធីនៃការផ្សះផ្សាវិវាទ និងដោះស្រាយវិវាទ**

**គ.ម.ក.** ក្រោយពីបានទទួលពាក្យប្តឹងហើយ ត្រូវសាកសួរភាគីទាំងសងខាងឱ្យដឹងពីកម្មវត្ថុនៃវិវាទ រួចសាកល្បងផ្សះផ្សាភាគីដោយយកច្បាប់ វិធាន និងបទប្បញ្ញត្តិផ្សេងៗជាមូលដ្ឋាន។

លទ្ធផលផ្សះផ្សា ត្រូវមានចុះក្នុងកំណត់ហេតុធ្វើដោយ **គ.ម.ក.** បញ្ជាក់ការយល់ព្រម ឬមិនយល់ព្រមផ្សះផ្សានៃភាគី។ កំណត់ហេតុត្រូវមានចុះហត្ថលេខាដោយ **គ.ម.ក.** និងភាគីទាំងអស់ និងត្រូវចម្លងជូនគ្រប់ភាគី។

ការព្រមព្រៀងដែលបានធ្វើឡើង នៅចំពោះមុខ **គ.ម.ក.** គឺជាការព្រមព្រៀងដែលមានអានុភាពអនុវត្ត។

ក្នុងករណីដែលគ្មានការសះជានឹងគ្នា សាមីភាគីអាចស្នើសុំឱ្យបញ្ជូនកំណត់ហេតុមិនសះជាទៅវេទិកាមជ្ឈត្តកម្មមានសមត្ថកិច្ច ឬប្តឹងទៅតុលាការមានសមត្ថកិច្ច។ អាជ្ញាយុកាលនៃបណ្តឹងទៅវេទិកាមជ្ឈត្តកម្មមានសមត្ថកិច្ច ឬ ប្តឹងទៅតុលាការមានសមត្ថកិច្ច មានរយៈពេល ៩០(កៅសិប)ថ្ងៃ ពុំនោះទេ សិទ្ធិប្តឹងនេះនឹងត្រូវបាត់បង់។

**មាត្រា ៤៥.- វិធានការបន្ថែមរបស់ គ.ម.ក.**

ដើម្បីបន្ថែមទៅលើវិធានការដែល **គ.ម.ក.** ដាក់ឱ្យអនុវត្តនៅក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ **គ.ម.ក.** អាចចាត់វិធានការដូចខាងក្រោម :

១-ក្នុងករណីដែលមានការប្រព្រឹត្តល្មើសនឹងច្បាប់ ឬ បទប្បញ្ញត្តិ ដែលធ្វើឡើងអនុលោមតាមច្បាប់នេះ ឬ រំលោភលើច្បាប់ដែលពាក់ព័ន្ធផ្សេងទៀត អគ្គនាយកនៃ **គ.ម.ក.** អាច :

-ចេញលិខិតព្រមានទៅបុគ្គលដែលពិនិត្យឃើញថា បានប្រព្រឹត្តល្មើសនឹងច្បាប់នេះ ឬ ច្បាប់ដែលពាក់ព័ន្ធផ្សេងទៀត

-ចេញបទបញ្ជាឱ្យបុគ្គលដែលពិនិត្យឃើញថា បានប្រព្រឹត្តល្មើសនឹងច្បាប់

នេះ ឬ ច្បាប់ដែលពាក់ព័ន្ធផ្សេងទៀត ធ្វើការជួសជុលសំណងព្យសនកម្ម ស្របតាមច្បាប់នេះ និងច្បាប់ដទៃទៀត ទៅតាមអំពើល្មើសដែលបុគ្គលនោះ បានប្រព្រឹត្តនៅកាលបរិច្ឆេទជាក់លាក់មួយ

-ស្នើសុំទៅតុលាការមានសមត្ថកិច្ច ដើម្បីចេញដីកាតម្រូវឱ្យបុគ្គលដែលពិនិត្យឃើញថា បានប្រព្រឹត្តិល្មើសនឹងច្បាប់នេះ ឬ ច្បាប់ពាក់ព័ន្ធផ្សេងទៀតឱ្យអនុវត្តតាមច្បាប់ និង ឱ្យជួសជុលសំណងព្យសនកម្មតាមការកំណត់របស់តុលាការដែលមានអំណាចឆន្ទានុសិទ្ធិសម្រេច

-ចាត់វិធានការផាកពិន័យអន្តរការណ៍ ឬ ដាក់ទណ្ឌកម្មរដ្ឋបាលលើបុគ្គលដែលពិនិត្យឃើញថា បានប្រព្រឹត្តល្មើសនឹងលក្ខខណ្ឌនៃច្បាប់។ ការដាក់ទណ្ឌកម្មរដ្ឋបាលត្រូវកំណត់ដោយ **គ.ម.ក.**

-ព្យួរជាបណ្ដោះអាសន្ន ឬ បញ្ឈប់ការងាររបស់អគ្គនាយក នាយក សមាជិកគណៈគ្រប់គ្រង ឬ បុគ្គលិកជាន់ខ្ពស់របស់នីតិបុគ្គលមានអាជ្ញាប័ណ្ណ ឬ នីតិបុគ្គលប្រតិស្រុត

-ជ្រើសរើស និង ផ្ដល់អំណាចដល់បុគ្គលដែលមានសមត្ថកិច្ចសមស្របដើម្បីពិនិត្យមើលសកម្មភាពអាជីវកម្ម ឬ សកម្មភាពពាក់ព័ន្ធផ្សេងទៀតរបស់នីតិបុគ្គលមានអាជ្ញាប័ណ្ណ ឬ នីតិបុគ្គលប្រតិស្រុត។ បុគ្គលនោះត្រូវធ្វើរបាយការណ៍ទៅឱ្យអគ្គនាយក **គ.ម.ក.** តាមលក្ខខណ្ឌដែលមានក្នុងកិច្ចសន្យាជាមួយអគ្គនាយកនៃ **គ.ម.ក.** និង

-ដាក់កំហិត ឬ បញ្ឈប់សកម្មភាពជាក់លាក់ ឬ ទូទៅដែលធ្វើឡើងដោយនីតិបុគ្គលមានអាជ្ញាប័ណ្ណ ឬ នីតិបុគ្គលប្រតិស្រុត ទោះបីជាសកម្មភាពទាំងនោះ ត្រូវបានធ្វើឡើងស្រប ឬ មិនស្របតាមលក្ខខណ្ឌនៃអាជ្ញាប័ណ្ណ ឬ នៃការអនុញ្ញាតដែលអគ្គនាយកនៃ **គ.ម.ក.** ផ្ដល់ឱ្យក៏ដោយ។

២-ក្នុងករណីដែល **គ.ម.ក.** ពិនិត្យឃើញថា នីតិបុគ្គលមានអាជ្ញាប័ណ្ណ ឬ នីតិបុគ្គលប្រតិស្រុត អាចជាអសាធនីយ ឬ មានបញ្ហាផ្នែកហិរញ្ញវត្ថុ អគ្គនាយកនៃ **គ.ម.ក.** អាចប្រើប្រាស់អំណាចរបស់ខ្លួនដើម្បីតែងតាំង ឬ ស្នើសុំទៅតុលាការ ដើម្បីតែងតាំងបុគ្គលដែល

មានសមត្ថភាពសមស្របឱ្យធ្វើជាអភិបាលបណ្តោះអាសន្នដើម្បីគ្រប់គ្រង និងរៀបចំឡើងវិញ ឬ ជម្រះបញ្ជីនីតិបុគ្គលនោះ ស្របតាមច្បាប់ស្តីពីក្ស័យធននៃព្រះរាជាណាចក្រកម្ពុជា ឬ បទប្បញ្ញត្តិផ្សេងៗទៀតដែលមានចែងក្នុងអនុក្រឹត្យ ដោយអនុលោមតាមច្បាប់នេះ។ ក្នុងករណីដែលមានទំនាស់រវាងបទប្បញ្ញត្តិនៃច្បាប់នេះ និងបទប្បញ្ញត្តិនៃច្បាប់ក្ស័យធន ត្រូវយកបទប្បញ្ញត្តិនៃច្បាប់នេះមកអនុវត្ត។

**មាត្រា ៤៦.- សិទ្ធិប្តឹងតវ៉ាចំពោះសេចក្តីសម្រេចរបស់ គ.ម.ក.**

បុគ្គលដែលទទួលរងការខូចខាតដោយវិធានការ ឬ សេចក្តីសម្រេចណាមួយរបស់ **គ.ម.ក.** អាចប្តឹងតវ៉ាទៅតុលាការមានសមត្ថកិច្ច ដើម្បីសុំឱ្យពិនិត្យឡើងវិញនូវវិធានការ ឬ សេចក្តីសម្រេចនោះ។

## ជំពូកទី ៩

## ទោសប្បញ្ញត្តិ

**មាត្រា ៤៧.- ការបោះផ្សាយ និងលក់មូលបត្រដោយខុសច្បាប់**

បុគ្គលណាដែលបោះផ្សាយ និងលក់មូលបត្រជាសាធារណៈដោយគ្មានការអនុញ្ញាតពី **គ.ម.ក.** ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ដល់ ១០.០០០.០០០ (ដប់លាន) រៀល។

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី២០.០០០.០០០(ម្ភៃលាន)រៀល ដល់៥០០.០០០.០០០(ប្រាំរយលាន)រៀល។

**មាត្រា ៤៨.- សំណើលក់មូលបត្រជាសាធារណៈដោយខុសច្បាប់**

បុគ្គលណាដែលធ្វើសំណើលក់មូលបត្រជាសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនគោរពតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ១៦ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ឆ្នាំ ដល់ ៥(ប្រាំ)ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ដល់ ១០.០០០.០០០ (ដប់លាន) រៀល។

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ដល់ ៥០០.០០០.០០០ (ប្រាំរយលាន) រៀល។

**មាត្រា ៤៩.- អំពើផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មានបន្ថែម ឬឯកសារផ្តល់ព័ត៌មានជំនួស**

បុគ្គល ឬ ក្រុមហ៊ុនស្នើសុំចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ឬ ក្រុមហ៊ុនបោះផ្សាយមូលបត្រដែលមិនបំពេញកាតព្វកិច្ចតាមកថាខណ្ឌទី ១នៃមាត្រា ២០នៃច្បាប់នេះ ឬដែលផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មានបន្ថែម ឬ ឯកសារផ្តល់ព័ត៌មានជំនួសជាសាធារណៈ ដោយគ្មានការអនុញ្ញាតពី និងចុះបញ្ជីនៅ **គ.ម.ក.** ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ឆ្នាំ ដល់ ៥(ប្រាំ)ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ដល់ ១០.០០០.០០០(ដប់លាន) រៀល។

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ដល់ ៥០០.០០០.០០០ (ប្រាំរយលាន) រៀល។

**មាត្រា ៥០.- ការធ្វើប្រតិបត្តិការទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់ ឬ សេវារក្សាទុកមូលបត្រដោយខុសច្បាប់**

បុគ្គលណាដែលធ្វើប្រតិបត្តិការទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់ ឬ សេវារក្សាទុកមូលបត្រ ដោយគ្មានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** ដោយអនុលោមតាមច្បាប់នេះ ឬ ច្បាប់ផ្សេងៗទៀតជាធរមាន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ឆ្នាំ ដល់ ៥(ប្រាំ)ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០(ពីរលាន)រៀល ដល់ ១០.០០០.០០០(ដប់លាន)រៀល។

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ដល់ ៥០០.០០០.០០០ (ប្រាំរយលាន) រៀល។

**មាត្រា ៥១.- វិធានប្រតិបត្តិការ និងនីតិវិធីរបស់ទីផ្សារមូលបត្រ ប្រព័ន្ធផាត់ទាត់និងទូទាត់ និង សេវារក្សាទុកមូលបត្រដោយខុសច្បាប់**

បុគ្គលណាដែលដាក់ឱ្យអនុវត្តនូវវិធានប្រតិបត្តិការ និង នីតិវិធីរបស់ទីផ្សារមូលបត្រ ប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ឬ សេវារក្សាទុកមូលបត្រដោយគ្មានការអនុញ្ញាតពី **គ.ម.ក.** ត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ដល់ ២០០.០០០.០០០ (ពីររយលាន) រៀល។

**មាត្រា ៥២.- ការធ្វើអាជីវកម្មមូលបត្រដោយគ្មានអាជ្ញាប័ណ្ណ**

លើកលែងតែពាណិជ្ជករមូលបត្រអញ្ញត្រកម្ម ឬ ពាណិជ្ជករពាក់ព័ន្ធនឹងប្រតិបត្តិការមូលបត្រអញ្ញត្រកម្ម បុគ្គលណាដែលធ្វើអាជីវកម្មមូលបត្រ ឬ តាំងខ្លួនជាអ្នកធ្វើអាជីវកម្មមូលបត្រក្នុងទម្រង់ជាក្រុមហ៊ុនមូលបត្រ ឬ ជនណាដែលធ្វើជា ឬ តាំងខ្លួនជាភ្នាក់ងារក្រុមហ៊ុនមូលបត្រ ដើម្បីធ្វើអាជីវកម្មមូលបត្រ ដោយគ្មានអាជ្ញាប័ណ្ណពីអគ្គនាយកនៃ **គ.ម.ក.** ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ឆ្នាំ ដល់ ៥(ប្រាំ)ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ដល់ ១០.០០០.០០០ (ដប់លាន) រៀល។

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ដល់ ៥០០.០០០.០០០ (ប្រាំរយលាន) រៀល។

**មាត្រា ៥៣.- ការមិនគោរពតាមការណែនាំរបស់ គ.ម.ក.**

បុគ្គលដែលមិនគោរពតាមបញ្ញត្តិនៃមាត្រា ៣០ និងមាត្រា ៣៧ នៃច្បាប់នេះ ត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាប្រាក់ :

ក-ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ចំពោះរូបវន្តបុគ្គល។

ខ-ពី ២០.០០០.០០០(ម្ភៃលាន)រៀល ទៅ ២០០.០០០.០០០(ពីររយលាន)រៀល ចំពោះនីតិបុគ្គល។

**មាត្រា ៥៤.- បទល្មើសជួញដូរផ្ទៃក្នុង ជួញដូរក្លែងក្លាយ និងប្រើឧបាយកលក្នុងទីផ្សារ សេចក្ដីថ្លែង ឬ ការផ្សព្វផ្សាយព័ត៌មានក្លែងបន្លំ ឬ នាំឱ្យយល់ខុស**

បុគ្គលដែលប្រព្រឹត្តដោយចេតនាល្មើសនឹងបញ្ញត្តិនៃមាត្រា ៤០ កថាខណ្ឌទី ៣ មាត្រា ៤១ និងមាត្រា ៤២ នៃច្បាប់នេះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៥(ប្រាំ)ឆ្នាំ ដល់ ១០(ដប់)ឆ្នាំ និងផ្ដន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០(ម្ភៃលាន) រៀល ដល់ ១០០.០០០.០០០(មួយរយលាន)រៀល។

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើ ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ៥០.០០០.០០០(ហាសិបលាន) រៀល ដល់ ១.០០០.០០០.០០០ (មួយពាន់លាន) រៀល។

**មាត្រា ៥៥.- ទោសបន្ថែមអនុវត្តចំពោះរូបវន្តបុគ្គល**

ចំពោះបទល្មើសដូចមានចែងនៅក្នុងច្បាប់នេះ ទោសបន្ថែមមួយឬច្រើន ដូចខាងក្រោម អាចត្រូវបានប្រកាស :

១-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈជាស្ថាពរ ឬ សម្រាប់រយៈពេលមិនលើសពី ៥(ប្រាំ)ឆ្នាំ កាលបើបទល្មើសនេះ បានប្រព្រឹត្តក្នុងការប្រកបវិជ្ជាជីវៈ ឬ ក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ។

២-ការហាមឃាត់ការបើកបរយានយន្តគ្រប់ប្រភេទ សម្រាប់រយៈពេលមិនលើសពី ៥(ប្រាំ)ឆ្នាំ។

៣-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅ សម្រាប់រយៈពេលមិនលើសពី ១០ (ដប់)ឆ្នាំ ចំពោះបទល្មើសឧក្រិដ្ឋ និងសម្រាប់រយៈពេលមិនលើសពី ៥(ប្រាំ)ឆ្នាំ ចំពោះបទល្មើសមជ្ឈិម។

៤-ការហាមឃាត់ទណ្ឌិតបរទេសនូវការចូលមក និងស្នាក់អាស្រ័យនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាជាស្ថាពរ ឬ សម្រាប់រយៈពេលមិនលើសពី ៥(ប្រាំ)ឆ្នាំ។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស។

៦-ការរឹបអូសវត្ថុ ឬ មូលនិធិ ដែលជាគោលដៅនៃបទល្មើស។

៧-ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស។

៨-ការរឹបអូសនូវឧបភោគភណ្ឌ សម្ភារៈ និងគ្រឿងសង្ហារឹមតែងលម្អទីតាំងដែលក្នុងទីតាំងនោះបទល្មើសត្រូវបានប្រព្រឹត្ត។

៩-ការរឹបអូសនូវយានយន្តរបស់ទណ្ឌិតមួយគ្រឿង ឬ ច្រើនគ្រឿង។

១០-ការបិទគ្រឹះស្ថានដែលត្រូវបានប្រើប្រាស់ សម្រាប់ត្រៀមរៀបចំបទល្មើស ឬ ប្រព្រឹត្តបទល្មើសជាស្ថាពរ ឬ សម្រាប់រយៈពេលមិនលើសពី ៥(ប្រាំ)ឆ្នាំ។

១១-ការហាមឃាត់ ការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកជាសាធារណៈ ឬ ដែលប្រើប្រាស់ដោយសាធារណជនជាស្ថាពរ ឬ សម្រាប់រយៈពេលមិនលើសពី ៥(ប្រាំ)ឆ្នាំ។

១២-ការបណ្តេញចេញពីទីផ្សារមូលបត្រ។

១៣-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេលមិនលើសពី ២(ពីរ)ខែ។

១៤-ការចេញផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ។

១៥-ការចាក់ផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេលមិនលើសពី ៨(ប្រាំបី)ថ្ងៃ។

**មាត្រា ៥៦.- ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល**

ចំពោះបទល្មើសដូចមានចែងក្នុងច្បាប់នេះ នីតិបុគ្គលត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌ ចំពោះបទល្មើសដែលប្រព្រឹត្តដោយអង្គការ ឬ អ្នកតំណាង ដើម្បីជាប្រយោជន៍នៃនីតិបុគ្គលនោះ។

ការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់នីតិបុគ្គល មិនលើកលែងនូវការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលក្នុងអំពើដដែលនោះទេ។

**មាត្រា ៥៧.- ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល**

នីតិបុគ្គលដែលបានប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងច្បាប់នេះ ត្រូវទទួលទោសបន្ថែមមួយ ឬ ច្រើន ដូចខាងក្រោម :

-ការរំលាយចោល

-ការដាក់ឱ្យនៅក្រោមការតាមដានរបស់តុលាការ

-ការហាមចំពោះការអនុវត្តសកម្មភាពមួយ ឬ ច្រើន

-ការបណ្តេញចេញពីទីផ្សារមូលបត្រ

-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃ

-ការរឹបអូសវត្ថុ ឬ មូលនិធិ ដែលជាគោលដៅនៃបទល្មើស

-ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស

-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស

-ការចេញផ្សាយសេចក្តីសម្រេចផ្តន្ទាទោស នៅក្នុងសារព័ត៌មានសរសេរ ឬ ការចាក់ផ្សាយសេចក្តីសម្រេចផ្តន្ទាទោសតាមគ្រប់មធ្យោបាយគមនាគមន៍ សោតទស្សន៍។

# ជំពូកទី ១០
## អវសានប្បញ្ញត្តិ

**មាត្រា ៥៨.- បទប្បញ្ញត្តិដែលផ្ទុយនឹងច្បាប់នេះ**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៧

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

ពរល.០៧១០.៥៥៥

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ហត្ថលេខា**

**គាត ឈន់**

លេខ : ៥០២ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៧

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
# សទ្ទានុក្រមសម្រាប់ប្រើប្រាស់ក្នុងច្បាប់នេះ

- **ការកាន់កាប់ភាគហ៊ុនចំនួនច្រើន** (Substantial Share Holding) សំដៅដល់ការកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់បុគ្គលម្នាក់ ឬ ភាគីពាក់ព័ន្ធ ឬ សមាការីរបស់បុគ្គលនោះដែលមានចំនួនចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅ នៅក្នុងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុត។

- **កិច្ចសន្យាធានាទិញ** (Underwriting Agreement) សំដៅដល់កិច្ចព្រមព្រៀងដែលធ្វើឡើងដើម្បីធានាទិញមូលបត្រទាំងអស់ ឬ មួយផ្នែកដែលលក់មិនអស់ តាមនីតិវិធីនៅកាលបរិច្ឆេទផុតកំណត់នៃសំណើលក់ជាសាធារណៈ។ កិច្ចសន្យាធានាទិញនោះ គឺរាប់បញ្ចូលទាំងកិច្ចសន្យាធានាទិញបន្តដែលធ្វើឡើងដោយបុគ្គលដែលមានការអនុញ្ញាតតាមច្បាប់នេះ។

ផុតរយៈពេលនោះឯកជនត្រូវផ្ទេរនូវសិទ្ធិ សិទ្ធិកាន់កាប់ និងផលប្រយោជន៍ទាំងអស់លើសំណង់ហេដ្ឋារចនាសម្ព័ន្ធដែលមានលក្ខណៈល្អ តាមលក្ខខណ្ឌនៃកិច្ចសន្យាមកឱ្យស្ថាប័នមានសមត្ថកិច្ចវិញ។

- **ក្រុមហ៊ុនមូលបត្រ** (Securities Firm) សំដៅដល់ក្រុមហ៊ុន ឬ ក្រុមហ៊ុនសហកម្មសិទ្ធិដែលទទួលបានអាជ្ញាប័ណ្ណ ដើម្បីធ្វើអាជីវកម្មមូលបត្រ ដោយស្របទៅតាមច្បាប់នេះ។

- **ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត** (Public Limited Company) សំដៅដល់ក្រុមហ៊ុនដែលបង្កើតឡើង និងចុះបញ្ជីតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ក្នុងគោលបំណងបោះផ្សាយលក់មូលបត្រជាសាធារណៈ។

- **ក្រុមហ៊ុនសហកម្មសិទ្ធិ** (Partnership) សំដៅដល់សមាគមជំនួញ ដែលធ្វើអាជីវកម្មទទួលខុសត្រូវទូទៅ ឬ ទទួលខុសត្រូវមានកម្រិត ដែលត្រូវបានបង្កើតឡើងដោយរួបរួមបុគ្គលរួមគ្នា និងចុះបញ្ជីតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។

- **ក្រុមហ៊ុន** (Company) សំដៅដល់ក្រុមហ៊ុនឯកជន ឬ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតដែលបានបង្កើត ឬ ចុះបញ្ជីតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។

- **គណៈកម្មការមូលបត្រកម្ពុជា** (Securities and Exchange Commission of Cambodia) សំដៅដល់នីតិបុគ្គលដែលបង្កើតឡើងដោយច្បាប់នេះ ដើម្បីគ្រប់គ្រង និង ត្រួតពិនិត្យប្រតិបត្តិការមូលបត្រ។

- **តុលាការ** (Court) សំដៅដល់តុលាការមានសមត្ថកិច្ច ដែលត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីបើកសវនាការ និងសម្រេចសេចក្តីដែលបណ្តឹងតាមច្បាប់នេះ។

- **ភ្នាក់ងារក្រុមហ៊ុនមូលបត្រ** (Securities Representative) សំដៅដល់បុគ្គលដែលបំពេញនូវមុខងារ ឬ សកម្មភាពតាមការឯកភាពរបស់ក្រុមហ៊ុនមូលបត្រដែលតម្រូវឱ្យមាន និង ត្រូវមានអាជ្ញាប័ណ្ណដោយអនុលោមតាមច្បាប់នេះ។ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ត្រូវរាប់បញ្ចូល ទាំងអគ្គនាយក នាយក បុគ្គលិក ឬ និយោជិតរបស់ក្រុមហ៊ុន ឬ សហកម្មសិទ្ធិករដែលបំពេញមុខងារទាំងនេះក្នុងនាមក្រុមហ៊ុនមូលបត្រ។

- **ទីផ្សារមូលបត្រ** (Securities Market) សំដៅដល់ទីផ្សារ ឬ ទីកន្លែងជួញដូរមូលបត្រ ឬ ប្រព័ន្ធដែលផ្តល់មធ្យោបាយនៃការធ្វើសំណើលក់ ផ្ទេរ ឬ ស្នើការទិញ-លក់មូលបត្រ។

- **ទម្រង់អរូបីនៃមូលបត្រ** (Dematerialized Form) សំដៅដល់ទម្រង់កត់ត្រាកម្មសិទ្ធិស្របច្បាប់នៃមូលបត្រ ដែលធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិក ឌីជីថល ឬ កុំព្យូទ័រ ដែលអាចបើកមើលបាន និងបោះពុម្ពជាទម្រង់ដែលអាចអានបាន។

- **ទិញ** សំដៅដល់ការទិញតាមគ្រប់រូបភាព ដូចជាទិញដោយផ្ទាល់ ឬ ទិញតាមប្រព័ន្ធអេឡិចត្រូនិច ឬ ចុះឈ្មោះសុំទិញ (ធ្វើបរិវិសកម្ម)។

- **នីតិបុគ្គលប្រតិស្រុត** (Permitted Entity) សំដៅដល់នីតិបុគ្គលដែលត្រូវបានអនុញ្ញាតឱ្យបោះផ្សាយ និងធ្វើសំណើលក់មូលបត្រជាសាធារណៈក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងៗ។ នីតិបុគ្គលនេះ មិនមែនជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលត្រូវបានបង្កើតឡើងនៅព្រះរាជាណាចក្រកម្ពុជា។

- **បុគ្គល** (Person) សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គល រួមទាំង ក្រុមហ៊ុន និង ក្រុមហ៊ុនសហកម្មសិទ្ធិ។

- **បុគ្គលពាក់ព័ន្ធ** (Related Entity) ទាក់ទិននឹងក្រុមហ៊ុនដែលធ្វើសំណើលក់មូលបត្រជាសាធារណៈ សំដៅដល់បុគ្គលណាមួយដូចខាងក្រោម :

ក-ភាគទុនិកដែលជាស្ថាបនិកក្រុមហ៊ុន។

ខ-សាច់ញាតិផ្ទាល់របស់ភាគទុនិកជាស្ថាបនិកក្រុមហ៊ុន។

គ-នាយកក្រុមហ៊ុន ឬ សាខាក្រុមហ៊ុន ឬ ក្រុមហ៊ុនហូលឌីង។

ឃ-សាច់ញាតិផ្ទាល់របស់នាយកក្រុមហ៊ុនទាំងនេះ។

ង-សាខាក្រុមហ៊ុន ឬ ក្រុមហ៊ុនហូលឌីង ឬ សាខាក្រុមហ៊ុនហូលឌីង។

ច-រូបវន្តបុគ្គលឬនីតិបុគ្គលផ្សេងទៀតដែលត្រូវបានចែងក្នុងបទប្បញ្ញត្តិ ឬអនុក្រឹត្យ។

- **ប្រតិបត្តិកររក្សាទុកមូលបត្រ** (Securities Depository) សំដៅដល់បុគ្គលមួយយល់ព្រមជាមួយបុគ្គលមួយផ្សេងទៀត ដែលជាអតិថិជនរបស់ខ្លួនថាផ្តល់សេវាកម្ម ដូចខាងក្រោមនេះ ទោះបីជាអតិថិជននោះធ្វើសកម្មភាពក្នុងនាមខ្លួនឯង ឬ ធ្វើសកម្មភាពក្នុងនាមបុគ្គលផ្សេងទៀតក៏ដោយ :

ក-កាន់កាប់ ឬ ចុះបញ្ជីសិទ្ធិស្របច្បាប់លើមូលបត្រ ឬ ឧបករណ៍ហិរញ្ញវត្ថុដទៃទៀត ក្នុងនាមអតិថិជន ឬ បុគ្គលផ្សេងទៀតដែលអតិថិជនតែងតាំង។

ខ-ទទួលរក្សាទុកនូវមូលបត្រ ឬ ឧបករណ៍ហិរញ្ញវត្ថុដទៃទៀត ទោះបីមានរូបភាពជាវិញ្ញាបនប័ត្រកម្មសិទ្ធិ ឬ ជាទម្រង់អរូបីក្តី ដោយស្របទៅតាមវិធានប្រតិបត្តិការរក្សាទុកមូលបត្រ ក្នុងនាមអតិថិជន ឬ បុគ្គលផ្សេងទៀតដែលអតិថិជនតែងតាំង។

គ-ផ្តល់សេវាកម្ម និងលក្ខណៈងាយស្រួលផ្សេងៗទៀត ដែលទាក់ទិននឹងការផ្តល់សេវាកម្មដូចមានចែងក្នុងកថាខណ្ឌ (ក) និង (ខ)។

- **ប្រតិបត្តិការមូលបត្រអញ្ញត្រកម្ម** (Exempt Securities Transaction) សំដៅដល់ប្រតិបត្តិការមូលបត្រដែលធ្វើដោយបុគ្គលជាក់លាក់ណាមួយ ឬ ដោយបុគ្គលផ្សេងទៀត ដើម្បីចុះឈ្មោះសុំទិញ ទិញ បោះផ្សាយលក់ ឬ ផ្ទេរមូលបត្រ ដោយមិនចាំបាច់បំពេញតាមលក្ខខណ្ឌនៃច្បាប់នេះ។

- **ប្រព័ន្ធជាត់ទាត់ និងទូទាត់** (Clearance and Settlement Facility) សំដៅដល់ប្រព័ន្ធដែលផ្តល់លទ្ធភាពដល់ភាគីធ្វើប្រតិបត្តិការជួញដូរមូលបត្រ បំពេញកាតព្វកិច្ចរបស់ខ្លួនទៅវិញទៅមកបាន ដោយធ្វើការផ្ទៀងផ្ទាត់ប្រតិបត្តិការឱ្យបានច្បាស់លាស់ និងធានាឱ្យមានការទូទាត់ថ្លៃទិញជូនអ្នកលក់ ដែលជាថ្នូរនឹងការផ្ទេរកម្មសិទ្ធិមូលបត្រទៅឱ្យអ្នកទិញ។

- **ផលប្រយោជន៍ក្នុងគម្រោងវិនិយោគរួម** (Interest in a Managed Investment Scheme) សំដៅដល់ផលប្រយោជន៍ស្របច្បាប់ទោះបីដោយផ្ទាល់ ឬ ដោយប្រយោលនៅក្នុងគម្រោងវិនិយោគដែលមានលក្ខណៈដូចតទៅ:

១-បុគ្គលផ្តល់វិភាគទានជាសាច់ប្រាក់ ឬ ផ្តល់វត្ថុមានតម្លៃ ដើម្បីមានសិទ្ធិទទួលផលកម្រៃដែលបានមកពីគម្រោងវិនិយោគ។

២-រាល់វិភាគទានដែលប្រមូលបានហើយត្រូវបានយកទៅប្រើប្រាស់នៅក្នុងគម្រោងវិនិយោគ ដើម្បីបង្កើតផលកម្រៃហិរញ្ញវត្ថុ ឬ ផលកម្រៃដែលបានមកជាសិទ្ធិ ឬជាផលប្រយោជន៍លើទ្រព្យសម្បត្តិ សម្រាប់សមាជិកដែលមានផលប្រយោជន៍ក្នុងគម្រោងវិនិយោគនោះ ទោះបីសមាជិកនោះមិនគ្រប់គ្រងលើប្រតិបត្តិការប្រចាំថ្ងៃនៃគម្រោងវិនិយោគនោះក៏ដោយ។

- **ពាណិជ្ជករមូលបត្រ** (Securities Dealer) សំដៅដល់ពាណិជ្ជករដែលធ្វើអាជីវកម្មមូលបត្រ។

- **ពាណិជ្ជករមូលបត្រអញ្ញត្រកម្ម** (Exempt Securities Dealer) សំដៅដល់បុគ្គលដែលធ្វើអាជីវកម្មមូលបត្រ ដោយមិនចាំបាច់បំពេញតាមលក្ខខណ្ឌនៃច្បាប់នេះ។ ពាណិជ្ជករមូលបត្រអញ្ញត្រកម្មនេះ នឹងមានចែងដោយអនុក្រឹត្យ ឬ ប្រកាស។

- **ភាគហ៊ុនមានសិទ្ធិបោះឆ្នោត** (Voting Share) សំដៅដល់ភាគហ៊ុនរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុត ដែលផ្តល់សិទ្ធិបោះឆ្នោតទៅឱ្យអ្នកកាន់កាប់ភាគហ៊ុនដែលបានចុះបញ្ជី។

- **មូលបត្រមហាជន** (Non-government Securities) សំដៅដល់មូលបត្រដែលបោះផ្សាយដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលផ្សេងទៀត ដែលត្រូវបានអនុញ្ញាតឱ្យបោះផ្សាយលក់មូលបត្រជាសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមច្បាប់។ មូលបត្រទាំងនោះមានៈ

ក-មូលបត្រកម្មសិទ្ធិរាប់បញ្ចូលទាំងភាគហ៊ុន។

ខ-មូលបត្របំណុល រាប់បញ្ចូលទាំងសញ្ញាប័ណ្ណ។

គ-ផលប្រយោជន៍ក្នុងគម្រោងវិនិយោគរួម។

ឃ-ឧបករណ៍និស្សន្ទ ឬ ឧបករណ៍ដេរីវេទីវ ដែលទាក់ទងនឹងមូលបត្រមួយគឺយោងទៅលើចំណុច(ក) (ខ) ឬ (គ) ខាងលើ។

ង-ឧបករណ៍ហិរញ្ញវត្ថុ ដទៃទៀតដែលកំណត់ថាជាមូលបត្រ។

- **មូលបត្រកម្មសិទ្ធិ** (Equity Securities) សំដៅដល់ផលប្រយោជន៍ ឬ សិទ្ធិស្របច្បាប់លើមូលបត្រនៃក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលបរទេសប្រហាក់-ប្រហែល ហើយរាប់បញ្ចូលទាំងភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត និងគ្មានសិទ្ធិបោះឆ្នោត ភាគហ៊ុនមិនបង់ថ្លៃគ្រប់ និងភាគហ៊ុនបុរិមា។

- **មូលបត្រគាហក** (Bearer Securities) សំដៅដល់មូលបត្រ ដែលកម្មសិទ្ធិនៃមូលបត្រនោះត្រូវបានកំណត់ដោយការកាន់កាប់ជារូបវន្ត មិនមែនតាមរយៈការចុះបញ្ជីនៃកម្មសិទ្ធិករនៅក្នុងបញ្ជីមូលបត្រដែលរក្សាទុកដោយ ឬ រក្សាទុកសម្រាប់ក្រុមហ៊ុនបោះផ្សាយមូលបត្រ។

- **មូលបត្រថ្មី** (New Securities) សំដៅដល់មូលបត្រដែលមិនធ្លាប់បានបោះផ្សាយ ឬធ្វើសំណើលក់ជាសាធារណៈពីមុនមកដោយក្រុមហ៊ុនបោះផ្សាយមូលបត្រ ដែលមានចែងក្នុងច្បាប់។

- **មូលបត្របំណុល** (Debt Securities) សំដៅដល់ឧបករណ៍ហិរញ្ញវត្ថុដែលបោះផ្សាយដោយបុគ្គលណាមួយ ដោយបញ្ជាក់ ឬ ទទួលស្គាល់នូវបំណុលរបស់ខ្លួនចំពោះបុគ្គលមួយទៀតដែលបានឱ្យប្រាក់ខ្ចី ឬ ដាក់ជាប្រាក់បញ្ញើជាមួយបុគ្គលនោះ ឬ បុគ្គលនោះជំពាក់តាមវិធីផ្សេងពីនេះ ហើយទោះបីជាមាន ឬ គ្មានទ្រព្យដាក់ធានាក្តី។

- **រដ្ឋមន្ត្រី** សំដៅដល់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

- **វិធានប្រតិបត្តិការនៃទីផ្សារមូលបត្រ ឬ នៃប្រព័ន្ធផាត់ទាត់និងទូទាត់ ឬ នៃសេវារក្សាទុកមូលបត្រ** (Operating Rules of a securities market, clearance and settlement facility ,or Securities Depository) សំដៅដល់វិធាន និង នីតិវិធី ដែលគ្រប់គ្រងសមាជិកភាព និង ការចូលរួមក្នុងទីផ្សារ ឬ ប្រព័ន្ធផាត់ទាត់និងទូទាត់ ឬ សេវារក្សារទុកមូលបត្រ ដែលរួមទាំង:

(១)លក្ខន្តិកៈរបស់ប្រតិបត្តិករទីផ្សារមូលបត្រ ឬ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់ ឬ ប្រតិបត្តិកររក្សាទុកមូលបត្រ។

(២)វិធាននៃការចុះបញ្ជីនៅទីផ្សារមូលបត្រ។

- **សមាគមី** (Associate) សំដៅដល់បុគ្គលដែលកំពុងមានទំនាក់ទំនងអាជីវកម្មជាមួយបុគ្គលមួយផ្សេងទៀត។

- **សមាជិកគ្រួសារផ្ទាល់** (Close relative) សំដៅដល់ទំនាក់ទំនងជាប្តី ប្រពន្ធ កូន ឪពុកម្តាយ បងប្អូនប្រុស ឬបងប្អូនស្រី របស់បុគ្គលណាម្នាក់។

- **ស្វ័យនិយ័តករ** (Self Regulatory Organization) សំដៅដល់ស្ថាប័នដែលគ្រប់គ្រងសមាជិករបស់ខ្លួនតាមរបៀបដែលសមាជិកនោះធ្វើអាជីវកម្ម។

- **សំណងព្យសនសកម្ម** (Damage) សំដៅដល់ការទូទាត់សងការខូចខាត។

- **សំណើលក់មូលបត្រជាសាធារណៈ** (Public Offer) សំដៅដល់ការអញ្ជើញសាធារណជនឱ្យដាក់ពាក្យសុំទិញ ឬ ទិញមូលបត្រ។ សំណើលក់នេះរួមមាន:

(១)សំណើដាក់លក់ ឬ ទិញមូលបត្រដែលធ្វើឡើងចំពោះមជ្ឈដ្ឋានសាធារណជនជាក់លាក់ណាមួយដែលត្រូវបានជ្រើសរើសឡើងតាមរបៀបណាក៏ដោយ

(២)សំណើដាក់លក់ ឬ ទិញមូលបត្រដែលធ្វើឡើង តាមរបៀបចៃដន្យចំពោះសមាជិកនៃមជ្ឈដ្ឋានសាធារណៈដែលបានជ្រើសរើស

(៣)សំណើដាក់លក់ ឬ ទិញមូលបត្រដែលធ្វើឡើង ចំពោះបុគ្គលដែលស្គាល់ពីមុនតាមរយៈការផ្សាយពាណិជ្ជកម្មសំណើដាក់លក់ ឬ ទិញ ឬ តាមរយៈការអញ្ជើញបុគ្គលនោះឱ្យមកសាកសួរព័ត៌មាន ឬ សុំការពិគ្រោះយោបល់អំពីការធ្វើវិនិយោគលើមូលបត្រ

(៤)ការចែកអត្ថបទផ្សាយពាណិជ្ជកម្ម ឯកសារផ្តល់ព័ត៌មាន ឬ ពាក្យស្នើសុំដែលទាក់ទងនឹងការដាក់ពាក្យសុំទិញ ការទិញ ឬ ការលក់មូលបត្រ។

ប៉ុន្តែសំណើលក់ជាសាធារណៈមិនរាប់បញ្ចូលនូវៈ

- សំណើលក់ជាឯកជន ដែលធ្វើឡើងចំពោះបុគ្គលដែលមានទំនាក់ទំនងជាមួយនឹងបុគ្គលធ្វើសំណើលក់ ឬ សហការី។

- សំណើលក់ជាឯកជនដែលធ្វើឡើង ចំពោះបុគ្គលដែលមានចំនួនមិនលើសពី ៣០ (សាមសិប) រូប។

- ការអញ្ជើញបុគ្គលណាមួយឱ្យធ្វើកិច្ចព្រមព្រៀងធានាទិញ ឬ កិច្ចព្រមព្រៀងធានាបន្តដែលទាក់ទិននឹងការបោះផ្សាយមូលបត្រ។

- **សំណើលក់មូលបត្រជាឯកជន** (Private or Personal Offer) សំដៅដល់សំណើលក់ដែលៈ

១-ត្រូវបានធ្វើស្ទីការដោយបុគ្គលដែលជាអ្នកទទួលសំណើ។

២-ត្រូវបានធ្វើឡើងចំពោះបុគ្គល ដែលមានការចាប់អារម្មណ៍ចំពោះសំណើលក់ដោយពិចារណាលើ

(ក)ទំនាក់ទំនងពីមុនរវាងបុគ្គលដែលធ្វើសំណើ និង អ្នកដែលទទួលសំណើនោះ

(ខ)ទំនាក់ទំនងវិជ្ជាជីវៈ ឬ ទំនាក់ទំនងផ្សេងទៀតរវាងបុគ្គលដែលធ្វើសំណើ និង អ្នកទទួលសំណើនោះ

(គ)សេចក្តីប្រកាស ឬ អំពើរបស់បុគ្គលណាមួយដែលបង្ហាញថាខ្លួនចាប់អារម្មណ៍នឹងសំណើនោះ។

- **សំណើលក់អញ្ញត្រកម្ម** (Exempt Offer) សំដៅដល់សំណើលក់មូលបត្រជាសាធារណៈដោយមិនចាំបាច់បំពេញតាមលក្ខខណ្ឌនៃច្បាប់។ សំណើលក់អញ្ញត្រកម្មនេះមានចែងដោយអនុក្រឹត្យ ឬ ប្រកាស។

- **អសាធនីយ** (Insolvent) សំដៅដល់ការមិនមានប្រាក់គ្រប់គ្រាន់ សម្រាប់ទូទាត់សងបំណុលដែលជំពាក់គេ។

- **អ្នកវិនិយោគសាធារណៈ** (Public Investor) សំដៅដល់សាធារណជននៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមទាំងរូបវន្តបុគ្គល និង នីតិបុគ្គលដែលមានសិទ្ធិទិញ ឬ លក់មូលបត្រដែលបានបោះផ្សាយ និង ធ្វើសំណើលក់ជាសាធារណៈក្នុងព្រះរាជាណាចក្រកម្ពុជាដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុត ដែលមិនមែនជាសមាការី ឬ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬ នីតិបុគ្គលពាក់ព័ន្ធរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុតនោះ។

- **អាជីវកម្មមូលបត្ររបស់បុគ្គលមួយ** (Securities Business of a Person) ត្រូវគិតទាំងសកម្មភាពដូចខាងក្រោម :

ក-ការទិញ ឬ លក់មូលបត្រក្នុងនាមជាភ្នាក់ងាររបស់បុគ្គលផ្សេងទៀត។

ខ-ការទិញ ឬ លក់មូលបត្រដោយប្រើប្រាស់មូលនិធិរបស់ខ្លួន និង ក្នុងនាមខ្លួនឯង។

គ-ការផ្តល់ប្រឹក្សាអំពីវិនិយោគមូលបត្រ ឬ ការបោះពុម្ពផ្សាយសេចក្តីវិភាគអំពីការវិនិយោគមូលបត្រជូនអ្នកវិនិយោគសាធារណៈ។

ឃ-ចុះកិច្ចព្រមព្រៀងធានាជាមួយក្រុមហ៊ុនដែលធ្វើសំណើលក់ ឬ ទិញមូលបត្រ ឬ ចុះកិច្ចព្រមព្រៀងធានាទិញ ឬ លក់បន្ត ។

- **ឯកសារផ្តល់ព័ត៌មានជាប្រចាំ** (Continuous Disclosure Document) សំដៅដល់ឯកសារផ្តល់ព័ត៌មានដែលពិពណ៌នាអំពីព្រឹត្តិការណ៍ ដែលកើតឡើងនៅពេលណាមួយក្នុងអាយុកាលរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុត។

- **ឯកសារផ្តល់ព័ត៌មាន** (Disclosure Document) សំដៅដល់លិខិតជូនដំណឹង ឬ សេចក្តីប្រកាសជាលាយលក្ខណ៍អក្សរ ដែលអធិប្បាយអំពីប្រវត្តិក្រុមហ៊ុនរបាយការណ៍ហិរញ្ញវត្ថុ ឬ ជាការអញ្ជើញឱ្យទិញ ឬ សំណើឱ្យគេដាក់ពាក្យសុំទិញ ឬ ទិញមូលបត្រ ឬ ប្រកាសអំពីការដាក់លក់ ឬ ការលក់មូលបត្រ និង រាប់បញ្ចូលទាំងឯកសារផ្តល់ព័ត៌មានជាប្រចាំ ឬ ឯកសារផ្តល់ព័ត៌មានជំនួសផងដែរ។

- **ឧបករណ៍និស្សន្ទ ឬ ឧបករណ៍ដេរីវេទីវ** (Derivative Instrument) សំដៅដល់កិច្ចសន្យាដែលផ្តល់សិទ្ធិ ឬ កាតព្វកិច្ចនៃមូលបត្រដើមទៅឱ្យបុគ្គលណាមួយ ដោយរាប់បញ្ចូលទាំងសិទ្ធិ ឬ កាតព្វកិច្ចទិញ លក់ ឬ ដាក់ពាក្យសុំទិញមូលបត្រក្នុងពេលអនាគត ដោយមិនគិតថាបុគ្គលនេះមានបំណងប្រើសិទ្ធិ ឬ មិនប្រើប្រាស់សិទ្ធិនេះក៏ដោយ។

# ឧបសម្ព័ន្ធទី២៖

# ប្រកាសស្តីពីការដាក់ឲ្យអនុវត្ត
# វិធានប្រតិបត្តិការប្រព័ន្ធផាត់ទាត់
# និងទូទាត់មូលបត្រ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**
លេខៈ ០០៤/១៧ ......គ.ម.ក. /ប្រ.ក.

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្រ

*****

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុថ្ងៃះទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០១១ គ.ម.ក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់ការអនុញ្ញាតធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០៤ គ.ម.ក.ប្រ.ក. ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្តីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia
ទូរសព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh Website : www.secc.gov.kh

- បានឃើញប្រកាសលេខ ០០៥/១១ គ.ម.ក.ប្រក. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្ត វិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្រ
- យោងសំណើសុំវិសោធនកម្មប្រកាសលេខ ០០៥/១១ គ.ម.ក.ប្រ.ក. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៧
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជានាថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៧។

## សម្រេច

**ប្រការ ១.-**

ដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ២.-**

ប្រកាសលេខ ០០៥/១១ គ.ម.ក.ប្រ.ក. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្រ និងប្រការ ២ នៃប្រកាសលេខ ០០៣/១៧ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ត្រូវទុកជានិរាករណ៍។

**ប្រការ ៣.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ប្រធាននាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត ប្រធាននាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិក និងអ្នកចូលរួមក្នុងទីផ្សារមូលបត្រ ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៣
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធប្រកាសលេខ ០១៨/១៣

ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៣

ស្តីពី

# វិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-គោលបំណង**

គោលបំណងនៃវិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្រនេះ គឺដើម្បីកំណត់នូវគោលការណ៍នានាដែលចាំបាច់សម្រាប់ការផាត់ទាត់និងទូទាត់មូលបត្រ នៅក្នុងប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (សរសេរកាត់ថា **ផ.ម.ក**) ស្របតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ ២.-និយមន័យ**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងវិធាននេះ ត្រូវបានកំណត់នៅក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ច្បាប់ស្តីពីមូលបត្ររដ្ឋ និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

-**សមាជិក** សំដៅដល់ក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពីគណៈកម្មការមូលបត្រកម្ពុជា (សរសេរកាត់ថា **គ.ម.ក**) ដោយមានសិទ្ធិប្រើប្រាស់ទាំងស្រុងនូវប្រព័ន្ធរបស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក**។

-**អ្នកចូលរួម** សំដៅដល់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ បុគ្គលបោះផ្សាយលក់មូលបត្រ បុគ្គលចុះបញ្ជីលក់មូលបត្រជាដើម ដែលមានសិទ្ធិប្រើប្រាស់តែមួយផ្នែកនូវប្រព័ន្ធរបស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក**។

-**ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ** សំដៅដល់ធនាគារពាណិជ្ជដែលបានការទទួលស្គាល់ពី **គ.ម.ក** ដូចមានចែងក្នុងប្រកាសស្តីពីការទទួលស្គាល់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

**ប្រការ៣.-ប្រតិបត្តិការផាត់ទាត់និងទូទាត់**

ការជួញដូរមូលបត្រចុះបញ្ជី ត្រូវតែប្រតិបត្តិតាមការទូទាត់ធម្មតា។ ការទូទាត់ធម្មតា គឺជាការទូទាត់ដែលត្រូវធ្វើឡើងពីរថ្ងៃបន្ទាប់ពីថ្ងៃជួញដូរ (T+2)។

## ជំពូកទី២

## ការទូទាត់រវាងប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងសមាជិក ឬអ្នកចូលរួម

**ប្រការ ៤.-ភាគព្វកិច្ចទូទាត់របស់សមាជិក ឬអ្នកចូលរួម**

សមាជិក ឬអ្នកចូលរួមនៃប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** ត្រូវធ្វើការទូទាត់លើប្រតិបត្តិការដែលបានជួញដូរឱ្យបាននៅកាលបរិច្ឆេទទូទាត់។

សមាជិក ឬអ្នកចូលរួមនៃប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** មិនអាចប្រគល់ភារកិច្ចទូទាត់ប្រតិបត្តិការរបស់ខ្លួនទៅឱ្យសមាជិក ឬអ្នកចូលរួមដទៃទៀតឡើយ។

**ប្រការ ៥.-កាលបរិច្ឆេទផាត់ទាត់និងទូទាត់រវាងសមាជិក ឬអ្នកចូលរួម**

លើកលែងតែមានការកំណត់ផ្សេងពីនេះដោយ **គ.ម.ក.** ការទូទាត់ត្រូវធ្វើឡើងពីរថ្ងៃនៃថ្ងៃជួញដូរបន្ទាប់ពីថ្ងៃដែលមូលបត្រនោះត្រូវបានជួញដូរ (T+2)។ ថ្ងៃបិទទីផ្សារមិនត្រូវបានរាប់បញ្ចូលក្នុងចំនួនថ្ងៃអាជីវកម្មទេ។

**ប្រការ ៦.-ការជ្រើសរើសភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ**

សមាជិក ឬអ្នកចូលរួមត្រូវជ្រើសរើសភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** សម្រាប់បំពេញកាតព្វកិច្ចទូទាត់សាច់ប្រាក់។

**ប្រការ ៧.-ការបើកគណនីទូទាត់សម្រាប់ការទូទាត់សាច់ប្រាក់**

សមាជិក ឬអ្នកចូលរួមនៃប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** ត្រូវបើកគណនីសាច់ប្រាក់ក្នុងនាមខ្លួនផ្ទាល់ នៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដូចមានចែងក្នុងប្រការ ៦ នៃវិធាននេះ ដើម្បីបំពេញកាតព្វកិច្ចទូទាត់សាច់ប្រាក់។

បន្ទាប់ពីបានបើកគណនីសាច់ប្រាក់ ឬមានការផ្លាស់ប្តូរគណនីសាច់ប្រាក់ សមាជិក ឬអ្នកចូលរួមត្រូវរាយការណ៍អំពីឈ្មោះនៃភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្ររបស់ខ្លួន និងលេខគណនី ជូនដល់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** យ៉ាងហោចណាស់ ៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការមុនថ្ងៃចាប់ផ្តើមការជួញដូរ។

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** ត្រូវបើកគណនីទូទាត់សាច់ប្រាក់នៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដើម្បីបំពេញកាតព្វកិច្ចទូទាត់សាច់ប្រាក់។

ការទូទាត់សាច់ប្រាក់ត្រូវបានធ្វើឡើង តាមរយៈការផ្ទេរសាច់ប្រាក់ពីគណនីសាច់ប្រាក់របស់សមាជិក ឬអ្នកចូលរួម ទៅគណនីទូទាត់សាច់ប្រាក់របស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.**។ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** ត្រូវផ្ទេរសាច់ប្រាក់ដែលទទួលបាននេះ ទៅសមាជិក ឬអ្នកចូលរួមដែលត្រូវទទួលបានការទូទាត់សាច់ប្រាក់។

## ប្រការ ៨.-ការបើកគណនីមូលបត្រសម្រាប់ការទូទាត់មូលបត្រ

សមាជិក ឬអ្នកចូលរួមត្រូវបើកគណនីមូលបត្រ ស្របតាមវិធានប្រតិបត្តិការរក្សាទុកមូលបត្រ នៃប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីបំពេញកាតព្វកិច្ចទូទាត់មូលបត្រ។

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** ត្រូវបើកគណនីទូទាត់មូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីបំពេញកាតព្វកិច្ចទូទាត់មូលបត្រ។

ការទូទាត់មូលបត្រត្រូវធ្វើឡើង តាមរយៈការផ្ទេរក្នុងបញ្ជី (Book-EntryTransfer) ពីគណនីមូលបត្ររបស់សមាជិក ឬអ្នកចូលរួម ទៅគណនីទូទាត់មូលបត្ររបស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.**។ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** ត្រូវផ្ទេរមូលបត្រដែលទទួលបាននេះទៅសមាជិក ឬអ្នកចូលរួម ដែលត្រូវទទួលបានការទូទាត់មូលបត្រ។

## ប្រការ ៩.-ការតម្កល់ធានាការជួញដូរ

មុនអនុវត្តបញ្ជាសម្រាប់គណនីអតិថិជន ឬសម្រាប់គណនីផ្ទាល់ខ្លួន សមាជិកត្រូវពិនិត្យការតម្កល់ធានាការជួញដូរមូលបត្រឱ្យបានត្រឹមត្រូវ ដូចតទៅ÷

១- សម្រាប់បញ្ជាទិញមូលបត្រ ត្រូវមានការតម្កល់ធានាការជួញដូរយ៉ាងតិច ១០០% (មួយរយភាគរយ) ជាសាច់ប្រាក់។ ចំពោះបញ្ជាទិញមូលបត្រកម្មសិទ្ធិ សាច់ប្រាក់តម្កល់ធានាការជួញដូរនេះ អាចគិតបញ្ចូលផងដែរនូវសាច់ប្រាក់ត្រូវទទួលបានពីបញ្ជាលក់ដែលបានផ្គូផ្គងដោយជោគជ័យ។

២- សម្រាប់បញ្ជាលក់មូលបត្រ ត្រូវមានការតម្កល់ធានាការជួញដូរយ៉ាងតិច ១០០% (មួយរយភាគរយ) ជាមូលបត្រដែលត្រូវដាក់លក់នោះ។ ចំពោះបញ្ជាលក់មូលបត្រកម្មសិទ្ធិ មូលបត្រតម្កល់ធានាការជួញដូរអាចគិតបញ្ចូលផងដែរនូវមូលបត្រដូចគ្នាត្រូវទទួលបានពីបញ្ជាទិញដែលបានផ្គូផ្គងដោយជោគជ័យ។

សមាជិកត្រូវធានាឱ្យបានថា ការតម្កល់ធានាការជួញដូរត្រូវបានរក្សាទុក ឬបង្កកសម្រាប់ការទូទាត់ ឬរហូតដល់បញ្ជានោះអស់សុពលភាព។

**ប្រការ ១០.-នីតិវិធីនៃប្រតិបត្តិការផាត់ទាត់និងទូទាត់**

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** ត្រូវគណនាចំនួនមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ចុងក្រោយដោយសមាជិក ឬអ្នកចូលរួម ដោយធ្វើការបន្សុទ្ធ ឬកាត់កង (Netting) ចំនួនមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ក្នុងថ្ងៃដូចគ្នា របស់សមាជិក ឬអ្នកចូលរួម នីមួយៗ។

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** ត្រូវជូនដំណឹងអំពីព័ត៌មានដូចខាងក្រោមដល់សមាជិក ឬអ្នកចូលរួម នៅកាលបរិច្ឆេទផាត់ទាត់ និងកាលបរិច្ឆេទទូទាត់÷

១-កាលបរិច្ឆេទផាត់ទាត់ និងកាលបរិច្ឆេទទូទាត់។

២-បរិមាណនៃមូលបត្រនីមួយៗ ដែលត្រូវទូទាត់ដោយសមាជិកផ្ទាល់ ឬអ្នកចូលរួម ឬក្នុងនាមអតិថិជន។

៣-ទឹកប្រាក់ដែលត្រូវទូទាត់ដោយសមាជិក ឬអ្នកចូលរួមផ្ទាល់ ឬក្នុងនាមអតិថិជន។

បរិមាណមូលបត្រ និងចំនួនសាច់ប្រាក់ដែលនឹងត្រូវទូទាត់ ត្រូវគណនាស្របតាមវិធីសាស្ត្រនីមួយៗដូចខាងក្រោម÷

១-ចំពោះមូលបត្រ÷ ត្រូវបានគណនាដោយធ្វើការផាត់ទាត់បរិមាណលក់សរុប និងបរិមាណទិញសរុបនៃមូលបត្រនីមួយៗ សម្រាប់សមាជិក ឬអ្នកចូលរួម ដែលពាក់ព័ន្ធ។

២-ចំពោះសាច់ប្រាក់÷ ត្រូវបានគណនាដោយធ្វើការផាត់ទាត់តម្លៃទិញសរុប និងតម្លៃលក់សរុប សម្រាប់សមាជិក ឬអ្នកចូលរួម នីមួយៗដែលពាក់ព័ន្ធ។

សមាជិក ឬអ្នកចូលរួម ត្រូវផ្ទេរមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ ទៅគណនីរបស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** នៅមុនម៉ោង ៨:៣០ ព្រឹក នៅកាលបរិច្ឆេទទូទាត់ (Settlement Date) ហើយប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** ត្រូវធ្វើការទូទាត់មូលបត្រនិងសាច់ប្រាក់បន្តទៅឱ្យសមាជិក ឬអ្នកចូលរួម ដែលត្រូវទទួលការទូទាត់ បន្ទាប់ពីម៉ោង ៨:៣០ ព្រឹក នៅថ្ងៃដដែលនៅកាលបរិច្ឆេទទូទាត់។

**ប្រការ ១១.-ការប្រគល់ឯកសារទូទាត់**

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** ត្រូវផ្តល់នូវឯកសារបង្គាប់ទូទាត់ ដែលរួមមានព័ត៌មានលម្អិតលើមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ជូនដល់សមាជិក ឬអ្នកចូលរួម ក្រោយការបិទទីផ្សារ តាមរយៈប្រព័ន្ធកុំព្យូទ័រ។

សមាជិក ឬអ្នកចូលរួម ត្រូវពិនិត្យអំពីមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ នៅលើឯកសារបង្គាប់ទូទាត់ និងត្រូវធ្វើការទូទាត់ទៅតាមពេលវេលាកំណត់។

សមាជិក ឬអ្នកចូលរួម ត្រូវប្រគល់ឯកសារទូទាត់ ដែលមានព័ត៌មានលម្អិត និងពេលវេលានៃការទូទាត់ជាដើម ជូនដល់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. ក្រោយពីការទូទាត់។

**ប្រការ ១២.-វិធានការវិន័យចំពោះការបរាជ័យនៃការទូទាត់**

ក្នុងករណីដែលសមាជិក ឬអ្នកចូលរួមណាមួយគ្មានលទ្ធភាពធ្វើការទូទាត់ការជួញដូររបស់ខ្លួន ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. អាចលុបចោលនូវការជួញដូរដែលបានប្រតិបត្តិហើយទាំងស្រុង ឬមួយផ្នែកនៅក្នុងប្រតិបត្តិករទីផ្សារនៃ ផ.ម.ក. ឬ/និងព្យួរការជួញដូររបស់សមាជិក ឬអ្នកចូលរួមនោះក្នុងរយៈពេលកំណត់មួយ។

ក្នុងករណីដែលមានកង្វះខាតសាច់ប្រាក់ក្នុងការទូទាត់ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. អាចប្រើប្រាស់មធ្យោបាយផ្សេងៗ ដើម្បីធានាការទូទាត់ លើកលែងតែមានការកំណត់ផ្សេងទៀត។

ក្នុងករណីដែលមានកង្វះខាតមូលបត្រសម្រាប់ទូទាត់ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. ត្រូវធ្វើការទូទាត់ ដោយសុំខ្ចីនូវមូលបត្រប្រភេទដូចគ្នាពីសមាជិក ឬអ្នកចូលរួមផ្សេងទៀត។ ប្រសិនបើការសុំខ្ចី និងការឱ្យខ្ចីមិនអាចធ្វើទៅបាន ការទូទាត់នឹងត្រូវលុបចោល។

ប្រសិនបើ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. មិនអាចរកមធ្យោបាយដើម្បីធ្វើការទូទាត់ ដូចមានចែងក្នុងកថាខណ្ឌទី ២ និងទី ៣ ខាងលើ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. អាចចាត់វិធានការ ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ។

**ប្រការ ១៣.- អ្នកតំណាងទូទាត់**

សមាជិក ឬអ្នកចូលរួមនីមួយៗ ត្រូវតែងតាំង និងចុះឈ្មោះអ្នកតំណាងទូទាត់យ៉ាងហោចណាស់ ១ (មួយ) រូប ដែលត្រូវទទួលការបណ្តុះបណ្តាលពីប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. និងដែលមានសិទ្ធិធ្វើប្រតិបត្តិការទូទាត់ឱ្យសមាជិក ឬអ្នកចូលរួមនោះ ជាមួយប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក.។

អ្នកតំណាងទូទាត់របស់សមាជិកនោះ អាចជាអ្នកតំណាងទីផ្សារដែលត្រូវបានតែងតាំងដោយសមាជិកស្របតាមវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ ផ.ម.ក.។

## ជំពូកទី ៣
## ថ្លៃសេវាផាត់ទាត់និងទូទាត់

**ប្រការ ១៤.-ថ្លៃសេវាផាត់ទាត់និងទូទាត់មូលបត្រ**

សមាជិក ឬអ្នកចូលរួមត្រូវបង់ថ្លៃសេវាផាត់ទាត់និងទូទាត់ ជូនប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. តាមអត្រា និងពេលវេលាដូចខាងក្រោម÷

១-ថ្លៃសេវាសម្រាប់សេវាផាត់ទាត់និងទូទាត់មូលបត្រ ត្រូវយកលើតម្លៃជួញដូរដែលត្រូវបានទូទាត់ (ប្រាក់សេវាត្រូវកាត់កៀសមកត្រឹមមួយខ្ទង់) តាមអត្រា ២,៥/១០.០០០ (ពីរក្បៀសប្រាំភាគមួយម៉ឺន) ឬ០,០២៥% (សូន្យក្បៀសសូន្យម្ភៃប្រាំភាគរយ) ចំពោះមូលបត្រកម្មសិទ្ធិ និង ១,២៥/១០.០០០ (មួយក្បៀសម្ភៃប្រាំភាគមួយម៉ឺន) ឬ ០,០១២៥% (សូន្យក្បៀសសូន្យមួយរយម្ភៃប្រាំភាគរយ) ចំពោះមូលបត្របំណុល។

២-អ្នកបង់ថ្លៃសេវា គឺសមាជិក ឬអ្នកចូលរួមនៃប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.**។

៣-ពេលវេលានៃការបង់ថ្លៃសេវា គឺនៅម៉ោង ៨:៣០ ព្រឹក នៃកាលបរិច្ឆេទទូទាត់។

* * *

# ឧបសម្ព័ន្ធទី៣៖

# គោលការណ៍ណែនាំស្តីពី នីតិនៃ

# ការទូទាត់សាច់ប្រាក់នៅក្នុង

# ទីផ្សារមូលបត្រ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មការមូលបត្រកម្ពុជា**

លេខ: ០០៣/១២ គ.ម.ក /សរ.ណ.លា.

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០១២

## គោលការណ៍ណែនាំ
## ស្តីពី
## នីតិវិធីនៃការទូទាត់សាច់ប្រាក់នៅក្នុងទីផ្សារមូលបត្រ

រាជរដ្ឋាភិបាលកម្ពុជាបានកំណត់នូវគោលនយោបាយពាក់ព័ន្ធនឹងការកំណត់រូបិយវត្ថុ ឬរូបិយបណ្ណ សម្រាប់ចារឹកលើមូលបត្របោះផ្សាយលក់ជាសាធារណៈ និងសម្រាប់ការជួញដូរនៅក្នុងទីផ្សារមូលបត្រកម្ពុជា ដូចខាងក្រោម÷

១-មូលបត្រដែលបោះផ្សាយលក់ជាសាធារណៈ ត្រូវចារឹកជាប្រាក់រៀល។

២-ការដាក់តម្លៃលើមូលបត្រ (Quotation) នៅក្នុងប្រព័ន្ធជួញដូររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (Cambodia Securities Exchange-CSX) ត្រូវធ្វើជាប្រាក់រៀល។

៣-ការទូទាត់នៅក្នុងទីផ្សារដំបូង (Primary Market) និងនៅក្នុងទីផ្សារបន្ទាប់ (Secondary Market) ត្រូវធ្វើជាប្រាក់រៀល។ ប៉ុន្តែបើភាគីអ្នកទិញ និងអ្នកលក់មូលបត្រមានការឯកភាពគ្នាក្នុងការទូទាត់ជាប្រាក់ដុល្លារអាមេរិក នោះការទូទាត់អាចធ្វើឡើងជាប្រាក់ដុល្លារអាមេរិក។ ការទូទាត់ជាប្រាក់ដុល្លារអាមេរិកនេះ ត្រូវបានអនុញ្ញាតឱ្យធ្វើក្នុងរយៈពេល ០៣ (បី) ឆ្នាំដំបូង ចាប់ពីទីផ្សារមូលបត្រត្រូវបានបង្កើត។

ដើម្បីសម្រួលដល់ការអនុវត្តគោលនយោបាយខាងលើនេះ គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) សូមចេញនូវគោលការណ៍ណែនាំដូចខាងក្រោម÷

### I-ការទូទាត់សាច់ប្រាក់នៅក្នុងទីផ្សារដំបូង

#### ១-ក្រុមហ៊ុនធានាទិញមូលបត្រ

ដើម្បីឱ្យវិនិយោគិនដែលធ្វើបរិវិសកម្មក្នុងទីផ្សារដំបូងអាចទូទាត់ជាប្រាក់រៀល ឬប្រាក់ដុល្លារអាមេរិកបាន ក្រុមហ៊ុនធានាទិញមូលបត្រត្រូវមានគណនី ០២ (ពីរ) ជាគណនីប្រាក់រៀលផង និងប្រាក់ដុល្លារអាមេរិកផងនៅក្នុងភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដើម្បីទទួលបង្កកសាច់ប្រាក់របស់អ្នកធ្វើបរិវិសកម្ម ។

#### ២-អ្នកធ្វើបរិវិសកម្ម

ក្នុងករណីដែលអ្នកធ្វើបរិវិសកម្មមានបំណងទូទាត់ជាប្រាក់រៀល ត្រូវដាក់បង្កកសាច់ប្រាក់ជាប្រាក់រៀលចំនួនយ៉ាងតិច ១០០% នៃទំហំបរិវិសកម្មដែលត្រូវធ្វើ។ ក្នុងករណីដែលអ្នកធ្វើបរិវិសកម្មមានបំណងទូទាត់ជាប្រាក់ដុល្លារអាមេរិក ត្រូវដាក់បង្កកសាច់ប្រាក់ជាប្រាក់ដុល្លារអាមេរិកចំនួនយ៉ាងតិច ១១០% នៃទំហំបរិវិសកម្មដែលត្រូវធ្វើ ដោយយកតាមអត្រាប្តូរប្រាក់ផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា នៅ ០១ (មួយ) ថ្ងៃនៃថ្ងៃធ្វើការ មុនកាលបរិច្ឆេទចាប់ផ្តើមទទួលពាក្យស្នើសុំធ្វើបរិវិសកម្ម។

#### ៣-ការទូទាត់

ក្រោយពេលធ្វើបរិវិសកម្មបានសម្រេច អ្នកធ្វើបរិវិសកម្មដែលមានបំណងធ្វើការទូទាត់ជាប្រាក់ដុល្លារអាមេរិក ត្រូវរកការព្រមព្រៀងជាមួយក្រុមហ៊ុនបោះផ្សាយលក់មូលបត្រលើអត្រាប្តូរប្រាក់ ដោយអត្រានេះត្រូវស្ថិតក្នុងរង្វង់

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh

±១% នៃអត្រាប្តូរប្រាក់ផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា នៅកាលបរិច្ឆេទនៃការព្រមព្រៀងគ្នា ឬយ៉ាងយូរត្រឹម ០២ (ពីរ) ថ្ងៃនៃថ្ងៃធ្វើការ មុនកាលបរិច្ឆេទទូទាត់។ ក្នុងករណីដែលអ្នកធ្វើបរិវិសកម្មដាក់បង្កកសាច់ប្រាក់ជាប្រាក់ដុល្លារអាមេរិក មិនអាចរកបានកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ដើម្បីទូទាត់ជាប្រាក់ដុល្លារអាមេរិក នោះអ្នកធ្វើបរិវិសកម្មអាចរកប្រាក់រៀលដើម្បីទូទាត់ មុននឹងអាចដកសាច់ប្រាក់ជាប្រាក់ដុល្លារអាមេរិក ដែលបានបង្កក ឬប្តូរសាច់ប្រាក់ដុល្លារដែលបានបង្កក ទៅជាប្រាក់រៀលដើម្បីទូទាត់។

**II-ការទូទាត់សាច់ប្រាក់នៅក្នុងទីផ្សារបន្ទាប់**

**១-ក្រុមហ៊ុនមូលបត្រ**

ដើម្បីផ្តល់ជម្រើសដល់វិនិយោគិនក្នុងការទូទាត់សាច់ប្រាក់ជាប្រាក់រៀល ឬជាប្រាក់ដុល្លារអាមេរិក ក្រុមហ៊ុនមូលបត្រ ត្រូវបើកគណនីសាច់ប្រាក់នៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រជាគណនីប្រាក់រៀលផង និងគណនីប្រាក់ដុល្លារអាមេរិកផង។

**២-ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ**

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ត្រូវបើកគណនីទូទាត់សាច់ប្រាក់នៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រជាគណនីប្រាក់រៀល ដើម្បីធ្វើការទូទាត់សាច់ប្រាក់ជាប្រាក់រៀល តាមប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

**៣-អ្នកបញ្ជាលក់/ទិញមូលបត្រ**

ការបញ្ជាលក់/ទិញ ការជួញដូរ និងការទូទាត់តាមរយៈក្រុមហ៊ុនមូលបត្រ ទៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ត្រូវធ្វើឡើងជាប្រាក់រៀល។ អ្នកបញ្ជាទិញមូលបត្រត្រូវដាក់បង្កកសាច់ប្រាក់ជាប្រាក់រៀលចំនួនយ៉ាងតិច ១០០% នៃទំហំបញ្ជាទិញ។ ប៉ុន្តែអ្នកលក់និងអ្នកទិញ ដោយមានការជ្រោមជ្រែងពីក្រុមហ៊ុនមូលបត្រ ឬ/និងភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ អាចរកកិច្ចព្រមព្រៀងទូទាត់សាច់ប្រាក់ជាប្រាក់ដុល្លារអាមេរិក បន្ទាប់ពីការទូទាត់ជាប្រាក់រៀល តាមរយៈប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

**៤-ការទូទាត់**

ក្រុមហ៊ុនមូលបត្រត្រូវចាត់ចែងរៀបចំបង្វែរសាច់ប្រាក់ដែលត្រូវទូទាត់ តាមរយៈភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ យ៉ាងយូរត្រឹមម៉ោង ៨:៣០ នាទីព្រឹក នៃកាលបរិច្ឆេទទូទាត់ (T+2) ទៅគណនីទូទាត់សាច់ប្រាក់របស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ។ បន្ទាប់ពីម៉ោង ៨:៣០ នាទីព្រឹក នៅថ្ងៃដដែល នៅកាលបរិច្ឆេទទូទាត់ (T+2) ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ត្រូវបង្វែរសាច់ប្រាក់បន្តទៅឱ្យសមាជិកដែលត្រូវទទួលការទូទាត់ យ៉ាងយូរត្រឹមម៉ោង ១០:៣០ នាទីព្រឹក នៃកាលបរិច្ឆេទទូទាត់ (T+2)។ បន្ទាប់ពីម៉ោង ១០:៣០ នាទីព្រឹក ក្រុមហ៊ុនមូលបត្រត្រូវផ្ទេរសាច់ប្រាក់ទៅគណនីអតិថិជនរបស់ខ្លួនឱ្យចប់សព្វគ្រប់ ក្នុងកាលបរិច្ឆេទទូទាត់ (T+2) នេះ។

ដោយការជួញដូរ និងការទូទាត់ត្រូវធ្វើឡើងជាប្រាក់រៀល តាមរយៈប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា អតិថិជនដែលមានបំណងធ្វើការទូទាត់ជាប្រាក់ដុល្លារអាមេរិក ត្រូវបញ្ជាក់ទៅក្រុមហ៊ុនមូលបត្រ ឬ/និងភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដើម្បីរកកិច្ចព្រមព្រៀងលើអត្រាប្តូរប្រាក់ជាមួយសមភាគី សម្រាប់ធ្វើការទូទាត់ជាប្រាក់ដុល្លារអាមេរិក។

**គណៈកម្មការមូលបត្រកម្ពុជា**